# វចនប្រឹង

## វិធីរៀនភាសា នឹង ការប្រើពាក្យពេច




បណ្ណ DU VOCABULAIRE

A LA COMPOSITION DES PHRASES KHMERES

៣២៤.
៣៨

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥000ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្លៅ ឃុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥000ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh        www.elibraryofcambodia.org**

# បទប្បញ្ញត្តិ

ស្នាដៃ ជួន-ណាត លេខ១

ផ្ញើប្រើ

ការណាត្រូវធ្វើ ពាក្យ-ឧត្តិ និងពិធីសមាធការព្រះភិក្ខុ

របៀបសូត្រក៏ដូច បទកិច្ចក-លេខគណនា

ភាគ១

ពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ-ខែមីនា

ឆ្នាំ

www.budinst.gov.kh www.elibraryofcambodia.org

៣២៤.៣៧

# វចនប្រទីប

ព្រះមហា សុង-ស៊ីវ សិទ្ធត្ថោ

រៀបរៀង

សម្តេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ

សង្ឃនាយកគណៈមហានិកាយ បានពិនិត្យសម្រេច

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

ការផ្សាយរបស់

បណ្ណាគារ សុមនសុខផ្ស លេខ ៩៥

វិថីហង់រី - រុស្ស៊ីយេរ

ភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# អាទ្យារម្ភបទ

ខ្ញុំបានដកស្រង់ពាក្យខ្លះពីវចនានុក្រម នឹងការរកពាក្យខ្លះដែលពុំទាន់មានក្នុងវចនានុក្រម យកមករៀបរៀង បង្កើតជាច្បាប់នេះឡើង ឲ្យឈ្មោះថា វចនប្បទីប (គ្រឿងបំភ្លឺពាក្យ) ទុកជាប្រទីបមួយ ផ្នែកខាងអក្សរសាស្ត្រខ្មែរ នឹងជាវត្ថុរបស់ជាតិ, ដោយយល់ឃើញថា មនុស្សក្នុងលោក ទោះជាតិណា ៗ ក៏ដោយ ដែលអ្នកផងអាចស្គាល់បានថាយ៉ាងណា ៗ គឺស្គាល់បានដោយសំដីភាសាឬអក្សរ; បើសំដីចេញមកយ៉ាងណា, គេអាចស្គាល់បានយ៉ាងនោះ, ដូចភាសិតបុរាណថា "សំដីសជាតិ... ឬសំដីជាឯក ..."; ព្រោះសំដីភាសាឬអក្សរទុកជាវិជ្ជាទីឡូយក្នុងពិភពលោក ។

លុះខ្ញុំរៀបរៀងចប់ហើយ ខ្ញុំយកទៅជូនព្រះតេជព្រះគុណ ឈឹម - ស៊ុម សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ដែលជាសាស្ត្រាចារ្យរបស់ខ្ញុំ ដើម្បីពិនិត្យផ្ទៀងផ្ទាត់; លុះលោកពិនិត្យហើយ ខ្ញុំយកទៅប្រគេន សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ផ្ទៀងផ្ទាត់សម្រេច ។ សម្តេចក៏មានព្រះទ័យសោមនស្សចំពោះសៀវភៅនេះ ទោះបីកំពុងមានរវល់ក្នុងសង្ឃកិច្ចយ៉ាងណា ក៏សម្តេចឆ្លៀតបិទឱកាស ពិនិត្យកែសម្រួលជាបងល់បានសម្រេច ។ ទើបខ្ញុំយកមកជូនព្រះតេជព្រះគុណ ឈឹម-ស៊ុម វិញ ដើម្បីចាត់ការបោះពុម្ពផ្សាយតាមត្រូវការ ទុកជាសម្បត្តិរបស់បណ្ណាគារសុមនសុវត្ថិតទៅ ។

វត្តលង្កា ថ្ងៃទី ២០ កក្កដា $\frac{២៤៩៣}{១៩៥០}$

មហា សុង-ស៊ីវ (សំវុត្តោ)

សិស្សសាលាបាលីជាន់ខ្ពស់ ភ្នំពេញ

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# អាទិសង្កេត

ពួកអក្សរសង្ខេប ដែលប្រើក្នុងសៀវភៅវចនប្រូទីបនេះ

| | | |
|---|---|---|
| កិ. | គឺ | កិរិយាសព្ទ |
| កិ.វិ. | " | កិរិយាវិសេសន៍ |
| គុ. | " | គុណសព្ទ |
| ន. | " | នាមសព្ទ |
| និ. | " | និបាតសព្ទ |
| ប. | " | បរិវារសព្ទ |
| ប.សំ. | " | បកតិសំខ្យា |
| បុ. | " | បុរិសសព្ទនាម |
| វិ.ស. | " | វិសេសនសព្ទនាម |
| សព្ទ. | " | សព្ទនាម |
| សំខ្យា.ស. | " | សំខ្យាសង្គ្រោះ |
| អា.និ. | " | អាយតនិបាត |

គ្រឿងសំគាល់

\+ សំគាល់ថា "នឹង" ឬ "ហើយនឹង"

> សំគាល់ថា "ទៅជា" ឬ "កើតទៅជា";

វណ្ណយុត្តិក្រៅពីនេះ ពុំបានពន្យល់ទេ ព្រោះធ្លាប់បាន ប្រើថ្មីកមកហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

# ចែនប្រទីប

## វគ្គទី ១

### វិធីអានអក្សរខ្មែរ

ដើម្បីអានឲ្យបានត្រឹមត្រូវ តាមសម្ផស្សព្យញ្ជនៈ ឬតាមលំនាំភាសាខ្មែរនោះ អ្នកអានគួរចេះនូវលក្ខណៈ ៣ យ៉ាងគឺៈ

១– ត្រូវដឹងកំណើតព្យញ្ជនៈ

២– ត្រូវស្គាល់ព្យញ្ជនៈឃោសាឃោសៈ

៣– ត្រូវចេះភាសានិយម ។

(ក) កំណើតព្យញ្ជនៈ

ព្យញ្ជនៈមាន ៣៣ តួ គឺៈ

កខគឃង, ចឆជឈញ, ដឋឌឍណ, តថទធន, បផពភម, យរលវសហឡ និង ំ (អំ) ។

ព្យញ្ជនៈជាធនិត មានសំឡេងតឹង ១០ តួគឺៈ ខ, ឃ, ឆ, ឈ, ឋ, ឍ, ថ, ធ, ផ, ភ កើតមកអំពីព្យញ្ជនៈជាសិថិល មានសំឡេងធូរ ទាំង ១០ តួគឺៈ ក, គ, ច, ជ, ដ, ឌ, ត, ទ, ប, ព ដែលផ្សំនឹងអក្សរ "ហ", ត្រូវអានធក់ក្រសោបសំឡេងទាំង ២ តួឲ្យរួមគ្នាជាសំឡេងមួយ ។

www.budinst.gov.kh www.elibraryofcambodia.org

មន្ត្រីតដូច្នេះ

ក + ហ > ខ អានថា ក្ហ,

គ + ហ > ឃ " គ្ហ,

ច + ហ > ឆ " ច្ហ,

ជ + ហ > ឈ " ជ្ហ,

ដ + ហ > ឋ " ដ្ហ,

ឌ + ហ > ឍ " ឌ្ហ,

ត + ហ > ថ " ត្ហ,

ទ + ហ > ធ " ទ្ហ,

ប + ហ > ផ " ប្ហ,

ព + ហ > ភ " ព្ហ;

អានដូច្នេះទើបត្រឹមត្រូវតាមសម្ពស្សព្យញ្ជនៈ ។

(១) ព្យញ្ជនៈឃោសាឃោសៈ

ព្យញ្ជនៈទាំង៣៣តួនោះ បែកជាពីរពួកគឺៈ

១– ព្យញ្ជនៈ ដែលមានសំឡេងមិនគឹកកង ហៅថា អឃោសៈ មាន១១តួគឺៈ កខ, ចឆ, ដឋ, តថ, បផ, សៈ

www.budinst.gov.kh www.elibraryofcambodia.org

២– ព្យញ្ជនៈដែលមានសំឡេងគឹកកងហៅថា ឃោសៈ មាន២១តួគឺៈ គឃង, ជឈញ, ឌឍណ, ទធន, ពភម, យរលវហឡ, ◌ំ(អំ)ជាឃោសាៈឃោសវិមុត្ត(១) ។

លំនាំអានៈ

ព្យញ្ជនៈដែលជាទ្វេព្យាង្គដូច "សាលា, វិហារ" ជាដើម បើព្យញ្ជនៈខាងដើមជាឃោសៈ ឬ អៈឃោសៈ ព្យញ្ជនៈខាងចុងជាវគ្គន្តៈ៥តួគឺៈ ង, ញ, ណ, ន, ម និងសេសវគ្គ៦ តួគឺៈ យ, រ, ល, វ, ហ, ឡ ត្រូវអានផ្តួលតាមព្យញ្ជនៈខាងដើម ដូចពាក្យថាៈ

ងៈ ប្រងាង (ប្រជាអឃោសៈ,ងាងជាឃោសៈ) អានថា ប្រង៉ាង;
ញៈ កំញម (កំ " ", ញម " ") " កំញ៉ម;
ណៈ ពាណិជ (ពាជាឃោសៈ, ណិជ " ") " ពានិច;
នៈ សំនឹក(២) (សំជាអឃោសៈ, នឹក " ") " សំណឹក;
មៈ ប្រមុះ (ប្រ " ", មុះ " ") " ប្រម៉ុះ ;
យៈ ស្រយាល (ស្រ " ", យាល " ") " ស្រយ៉ាល;

(១) ◌ំ នេះតាមលទ្ធិខាងភាសាសំស្ក្រឹត រាប់បញ្ចូលក្នុងពួកឃោសៈ, លទ្ធិខាងភាសាបាលីចាត់ជាឃោសាឃោសវិមុត្ត គឺផុតអំពីឃោសៈនិងអឃោសៈ ។ (២) កន្លែងដែលសឹក, កន្លែងដែលរលឹង ។

www.budinst.gov.kh www.elibraryofcambodia.org

រៈ ឥរាប (ឥជាអឃោសៈ,រាបជាឃោសៈ)អានថា ឥរ៉ាប ;

លៈកំលាប (កំ " ", លាប " ") " កំល៉ាប;

វៈ ក្រវាត់ (ក្រ " ", វាត់ " ") " ក្រវ៉ាត់:

ហៈ ជំហាន (ជំជាឃោសៈ, ហាន " ") " ជំហ៊ាន;

ឡៈ គុឡិកា (គុ " ", ឡិ " ") " គុលិកា;

ដូច្នេះជាដើម ។

វៀរលែងតែព្យញ្ជនៈជាវគ្គ១៦ តួគឺៈ ក,ខ,គ,ឃ,ច,ឆ, ជ, ឈ, ដ, ឋ, ឌ, ឍ, ត, ថ, ទ, ធ នឹងសេសវគ្គ១តួ គឺៈស ដែលមានសំឡេងរឹងផ្លូលទៅតាមព្យញ្ជនៈខាងដើមពុំបាន ហើយមិនត្រូវផ្លូលផង ដូចពាក្យថាៈ

កៈ និកាយ ផ្លូលទៅជា និគាយ ពុំបាន ;

ខៈ ទក្ខិណា " " ទគឃិណា " ;

គៈ ឥង្គត់ " " ឥង់កត់ " ;

ឃៈ សង្ឃឹម " " សង់ខឹម " ;

ចៈ វិចិត្រ " " វិជិត្រ " ;

ឆៈ គូឆាយ " " គូឈាយ " ;

www.budinst.gov.kh www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| ជៈ | បញ្ជាក់ | ផ្លូវទៅជា | បញ្ចាក់ | ពុំបាន | ; |
| ឈៈ | បញ្ឈរ | ” | ” បញ្ចរ | ” | ; |
| ជៈ | ពិជារ | ” | ” ពិចោរ | ” | ; |
| បៈ | ទាភោ | ” | ” ទាជា | ” | ; |
| ឱៈ | ប្រឹឌិត | ” | ” ប្រឌិត | ” | ; |
| ឈៈ | អត្ថមាស | ” | ” អ័ត-ប៉ះមាស | ” | ; |
| តៈ | ជាតស្រៈ | ” | ” ជាទៈស្រៈ | ” | , |
| បៈ | ពូជៅ | ” | ” ពូជៅ | ” | ; |
| ទៈ | បន្ទាយ | ” | ” បន់តាយ | ” | ; |
| ធៈ | កន្ថាយ | ” | ” កន់ថាយ | ” | ; |
| សៈ | ពំសា | ” | ” ពំសា | ” | ; |

ដូច្នេះជាដើម សូមពិនិត្យតាមលំនាំនេះជាឯរាប ។

(គ) ភាសានិយម :

ភាសាខ្មែរ ប្រើនជាប់ទាក់ទងដោយភាសាបាលីនឹងសំ-ស្ក្រឹត; ដែលជាបាលីឬសំស្ក្រឹតនោះ ដូចកាលអានតាមលំនាំភាសានោះៗក៏មាន, ដូចកាលអាននិយមមកតាមលំនាំភាសា

www.budinst.gov.kh www.elibraryofcambodia.org

ខ្មែរក៏មាន; ភាសាខ្មែរ នឹងភាសាខ្មែរ អាចភ្ជាប់នឹងសំឡេង "ហ" ក៏មាន តាមទំនងសេចក្ដី ដូចសរសេរថា:

លោកអើយ អាចថា លោកហ្អើយ,

នាងអើយ " នាងហ្អើយ,

សំឡាញ់អើយ " សំឡាញ់ហ្អើយ,

ព្រះអង្គអើយ " ព្រះអង្គហ្អើយ,

ទុក្ខអើយ " ទុក្ខហ្អើយ,

ព្រះពុទ្ធអើយ " ព្រះពុទ្ធហ្អើយ:

ដូច្នេះជាដើម ។

ម្យ៉ាងទៀតអាចភ្ជាប់សំឡេងគ្នាក៏មាន ដូចជា

លោកអើយ អាចថា លោកកើយ;

បងអើយ " បងងើយ;

នាងអើយ " នាងងើយ;

យាយអើយ " យាយយើយ;

ម្ចាស់អើយ " ម្ចាស់សើយ;

សំឡាញ់អើយ " សំឡាញ់ញើយ;

www.budinst.gov.kh www.elibraryofcambodia.org

បើអក្សរប្រកបផ្សំវ្យល់សំឡេងមិនស្រួលស្តាប់ ដូចជា ព្រះអង្គអើយ, ភិក្ខុអើយ, ទុក្ខអើយ, ព្រះពុទ្ធអើយ យ៉ាងនេះ ត្រូវឋាបានតែ "អ្ហើយ" ជាដាច់ខាត (កុំឋា ព្រះអង់គើយ, ភិកខ្វើយ, ទុកខើយ, ព្រះពុតធើយ) ។

មា្យ៉ាងវិញទៀត បើពាក្យដែលឥតអក្សរប្រកប ដូចជា តាអើយ, មាអើយ, ពូអើយ យ៉ាងនេះក៏ត្រូវឋាបានតែ "អ្ហើយ" ដែរ (កុំឋា តារើយ, មារើយ, ពូរើយ) ។

ឯរបៀបអានភាសាបាលី ឬសំស្ក្រឹត ដែលនិយមមក តាមលំនាំភាសាខ្មែរនោះ មានគ្រឿងចំណាំ ៤ យ៉ាងគឺ:

១– និយមដោយយុគលពិន្ទុ;

២– និយមដោយសំយោគសញ្ញា;

៣– និយមដោយបដិសេធ;

៤– និយមដោយសម្រួលភាសា ។

(ក) និយមដោយយុគលពិន្ទុ:

សញ្ញា (:) នេះហៅថា យុគលពិន្ទុ សម្រាប់ប្រើសម្រួល ពាក្យឲ្យងាយអាន, បើពាក្យនោះមានយុគលពិន្ទុនៅខាង ចុង, ត្រូវអានឲ្យបញ្ចេញសំឡេងអក្សរខាងចុងបំផុត, ប៉ុន្តែកុំឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

អក្សរនោះមានសូរជាតួប្រកប, បើអក្សរចុងបំផុតនោះ ជាស្រៈ អៈ ត្រូវអានឲ្យឮសូរជាអៈ (សំឡេងបាលី នឹងសំស្ក្រឹត ពេញទី) ដូចពាក្យថា៖

| | | |
|---|---|---|
| លក្ខណៈ | កុំអានថា | ល័ក—ខន |
| ភារៈ | „ | ភា |
| យុគៈ | „ | យុក |
| និយមៈ | „ | និយំ |
| បក្កៈ | „ | ប័ក |
| កាលៈ | „ | កាល |
| ទេសៈ | „ | ទេស |
| លាភៈ | „ | លាប |
| សិរៈ | „ | សិរ |
| សកលៈ | „ | សៈកលឬសៈកល់ |
| សូបៈ | „ | សូប |
| ញាណៈ | „ | ញាន |
| វិហារៈ | „ | វិហា ។ |

www.budinst.gov.kh www.elibraryofcambodia.org

បើពាក្យនោះមានទីបំផុតជាស្រៈ អា, អេ, អែ, អោ ត្រូវអានផ្អប់សំឡេងទីយៈ ឲ្យប្លែកពី អា, អេ, អែ, អោ ធម្មតា, ប៉ុន្តែកុំឲ្យមានសូរអក្សរប្រែកបខាងចុងឡើយ, ដូចពាក្យថាៈ

| | | | | |
|---|---|---|---|---|
| អ្ហាៈកុំទៅ | កុំអានថា | អ្ហា– | ឬ | អ្ហាក– |
| អ្ហាៈខុសទេ | " | "– | " | "– |
| មែនអឺហៈ | " | –អឺហ | ឬ | –អឺហាក |
| ខ្ញុំហាអឺហៈ | " | –" | " | "– " |
| អេៈឈប់សិន | " | អេ– | ឬ | អេក– |
| រអេៈរអុ | " | រអេរអុ | ឬ | រអេករអុ |
| អ្ហេៈៗ | " | អ្ហេៗ | ឬ | អ្ហេកៗ |
| អេៈអុៗ | " | អេអុៗ | ឬ | អេកអុៗ |
| នែៈមើលវា | " | នែ– | ឬ | នែក– |
| អែៈដល់ខ្ញុំ | " | អែ– | ឬ | អែក |
| អ្ហែៈកុហក | " | អ្ហែ– | ឬ | អ្ហែក |
| ហែៈហ៍ | " | ហែហក | ឬ | ហែកហក |
| ឱៈបេញហើយ | " | ឱ– | ឬ | ឱក– |

www.budinst.gov.kh www.elibraryofcambodia.org

ណោះឮទេ? កុំអានថា ណោ-ឬ ណោក-;

អ្នោះមែនហើយ " កុំអានថា អ្នោ- ឬ អ្នោក- ។

មួយវិញទៀត ត្រូវប្រយ័ត្ន កុំសរសេររូបយុគលពិន្ទុ បំណុបពីរនេះ (:) ឲ្យប្រទាំនឹងរិសជ៌នីយ រង្វង់មូលពីរ (ះ) នេះឡើយ ។

(១) និយមដោយសំយោគសញ្ញា:

សញ្ញានេះ (៎) ហៅថាសំយោគសញ្ញា សម្រាប់ដាក់លើពាក្យបាលីឬសំស្ក្រឹតពួកខ្លះ ដើម្បីបំប្លែងសំឡេង ឲ្យក្លាយស្ញៀងពីសូរដើម, ដូចពាក្យថា: អធ្យាស្រ័យ, អនាម័យ, ជ័យ, ន័យ, ភ័យ, រហ័ស, សម័យ, ក្ស័យ, ពិប័យ, អាល័យ, និស្ស័យ, វិន័យ, អ្រ័ក្សណ៍, ល័ក្ខ ល័ន្ធ, អភ័ព្វ, ព័ណ៌, ព័ទ្ធ, ឧបនិស្ស័យ, បច្ច័យ, ពិភាល័យ, ពិន័យ, វិជ័យ, វេស្ម័ន, នង្គ័ល, ដូច្នេះជាដើម ។

ក្នុងភាសាខ្មែរក៏មានប្រើខ្លះ ដូចជា: ទូន៎រ, ទន៎រ, ញ៉ែរ, ជ៌រ, ខ្ញុំរ, ទំព័រ, ភ្ញ៉ែរ, ដើមសំព៌រ, ផ្លែសង្ស៊ូរ, ស្លាតជ៌រ, សូរប៉ុង ៗ, ទ័ល, ដូច្នេះជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

(ក) និយមដោយបដិសេធ:

សញ្ញា ( ៍ ) នេះ ហៅថា បដិសេធ ឬ ទណ្ឌឃាដ សម្រាប់ប្រើបំបាត់សូរព្យញ្ជនៈហោល ដូចពាក្យថា:

| | | |
|---|---|---|
| គោឃាតក៍ | អានថា | គោឃាត; |
| ប្រវ៉ាញ្ចន៍ | " | ប្រវ៉ាញ; |
| ការណ៍ | " | ការ; |
| និមន្ត៍ | " | និមន់; |
| ប្រយោជន៍ | " | ប្រយោជ; |
| បារាយណ៍ | " | បារ៉ាយ; |
| នព្វរត្ន៍ | " | នប់-ព:រ៉ាត់; |
| មហាជាតក៍ | " | មហាជាត; |
| ប្រសាសន៍ | " | ប្រសាស; |
| ភេរីបរណ៍ | " | ភេរីបរ; |

ប៉ុណ្ណោះជាដើម; សូមអានតាមលំនាំនេះជាដរាប ។

(ក) និយមដោយសម្រួលភាសា

ក្នុងប្រយោគខ្មែរបើមានបាលីឬសំស្ក្រឹត ជាសព្ទមួយ ៗ

www.budinst.gov.kh www.elibraryofcambodia.org

BUDDHIST INSTITUTE LIBRARY



ដែលមិនមានយុគលពិន្ទុនៅខាងចុង ត្រូវអានប្រកបនឹងព្យញ្ជនៈ ចុងសព្ទរបស់ខ្លួន. ពាក្យខ្លះដូចជាអក្សរប្រកបដែលមានសង្កត់ មួយពីលើក៏មានតាមទំនងសេចក្ដី. ដូចជា:

ខ្ញុំជានាយកលើអ្នករាល់គ្នា អានថា – នាយក់ – ;
ថ្ងៃនេះកើតចលាចលខ្លាំង " – ចៈល៉ា-ចល់ – ;
ម្ដាយខ្ញុំមានសុនខញីមួយ " – សុ-ណាក់ – ;
កូនខ្ញុំវិកលភ្នែកម្ខាង " – វិ-កល់ – ;
ខ្ញុំមានវិតក្កដេកពុំលក់ " – វិ-តុក – ;
ឮពេញសកលឥតចន្លោះ " – សៈកល់ – ;
ខ្ញុំកាន់ពាក្យសត្យយូរហើយ " – សាត់ – ;
មនុស្សអធម្មខ្ញុំខ្លាចណាស់ " – អៈធ័ម –

ចំណោះជាដើម ។

ម្យ៉ាងទៀត បើពាក្យនោះមានច្រើនសព្ទ តភ្ជាប់គ្នាជាបទសមាស, សព្ទខាងដើមត្រូវអានឱ្យគ្រប់តួព្យញ្ជនៈ, សព្ទខាងចុងត្រូវអានប្រកបតាមវិធីខាងលើ. ដូចពាក្យថា:

www.budinst.gov.kh www.elibraryofcambodia.org

| | | |
|---|---|---|
| ឧដ្ឋានសម័យ | អានថា | អុត-ឋាន:ស:ម័យ; |
| អធម្មកម្ម | " | អ:ធ័ម-ម:ក័ម: |
| សច្ចប្បណិធាន | " | ស័ច,ច័ប-ប៉:ណិធាន; |
| សញ្ញវដ្ឋន | " | ស័ញ-ប:វុត-ឋាន; |
| សកលលោក | " | ស:ក:ល៉:លោក; |
| វិកប្បសន្ធាន | " | វិ-ក័ប-ប៉:សន់-ធាន; |
| វិតក្កបរិត | " | វិ-ត័ក-ក:ប:រិត; |
| ស្ថាពរព័ស្តុ | " | ស្ថា-ព:រ:ព័ស្តុ; |
| រាជប្រកាស | " | រា-ជ:ប្រកាស. |

ប៉ុណ្ណោះជាដើម; សូមពិនិត្យតាមលំនាំនេះជាដរាប ។

ម្យ៉ាងវិញទៀត ពាក្យខ្លះមានប្រើនសព្ទ ជាបទសមាសដែរ តែជាបទបំប្លែង គឺបទដែលត្រឡប់យកសព្ទខាងចុងមកដាក់ខាងដើមឲ្យផ្ទុយពាការបៀបវេយ្យាករណ៍ សំស្ក្រឹតឬបាលី, បែបនេះតាមទម្លាប់ ឲ្យអានបញ្ចេញសំឡេងបទកណ្ដាលផង គឺត្រង់ជំណាសព្ទ ក៏ឲ្យមានសំឡេងប្រកប, ដូចពាក្យថា: សាមញ្ញជន (អានថា សាម៉ុញ-ញ៉:ជន់) នេះតាមរបៀប-

www.budinst.gov.kh www.elibraryofcambodia.org

វេយ្យាករណ៍; លុះយក " ជន " ដែលជាសព្ទខាងចុងមកដាក់ខាងដើម "សាមញ្ញ" វិញ ជាជនសាមញ្ញ. (អានថា ជន់សាម័ញ), មិនត្រូវអានថា (ជៈនៈសាម័ញ) ឡើយ ។

ពាក្យបែបនេះមានច្រើន, ដូចតទៅនេះ ៖

| បទវេយ្យាករណ៍ | បទចំខ្មែរ |
|---|---|
| រូបសណ្ឋាន | សណ្ឋានរូប; |
| ពេទ្យមន្ទីរ | មន្ទីរពេទ្យ; |
| មន្ទីរនាយក | នាយកមន្ទីរ; |
| អាស្រមដ្ឋាន | ឋានអាស្រម; |
| លាមកជន | ជនលាមក; |
| បាបមិត្រ | មិត្របាប; |
| សីលសមាទាន | សមាទានសីល; |
| ឧបោសថសីល | សីលឧបោសថ; |
| សីលវិបត្តិ | វិបត្តិសីល; |
| អាកាសធាតុ | ធាតុអាកាស; |
| អសុរវិមាន | វិមានអសុរ; |

www.budinst.gov.kh www.elibraryofcambodia.org

| បទវេយ្យាករណ៍ | បទបំប្លែន |
|---|---|
| បណ្ឌិតបរិត | បរិតបណ្ឌិត ; |
| យក្ខពល | ពលយក្ខ ; |
| ទុព្វលភាព | ភាពទុព្វល ; |
| សម្ពន្ធមិត្រ | មិត្រសម្ពន្ធ ; |
| ទុគ្គតបុរស | បុរសទុគ្គត ; |
| អកុសលកម្ម | កម្មអកុសល ; |
| មនុស្សសម្បត្តិ | សម្បត្តិមនុស្ស ; |
| តិរច្ឆានជាតិ | ជាតិតិរច្ឆាន ; |
| សប្បុរិសចិត្ត | ចិត្តសប្បុរស ; |
| អកុសលចិត្ត | ចិត្តអកុសល ; |
| មិត្តសមាគម | សមាគមមិត្ត ; |
| ជាតិរស | រសជាតិ ; |
| ទិព្វវិមាន | វិមានទិព្វ ; |
| មនុស្សរូប | រូបមនុស្ស ; |
| បុរាណធន | ធនបុរាណ |

ដូច្នេះជាដើម; សូមពិនិត្យតាមលំនាំនេះទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

មានពាក្យខ្លះ ដែលពុំមែនជាបទបំប្លែង ក៏មានអានដូចជាបទបំប្លែង ខាងលើនេះដែរ, ប៉ុន្តែមានតិចណាស់ ដូចជា: កិត្តិយសសមាជិក ជាបទវេយ្យាករណ៍ (អានជាកិត-តិ-យស់សៈម៉ាជិក) ពុំដែលជា (កិត-តិ-យៈ ស: សៈ ម៉ាជិក) ដូច្នេះទេ, ប៉ុណ្ណោះជាដើម ; សូមពិនិត្យតាមលំនាំនេះថែមទៀត ។

ភាសានិយមនេះលំបាកសំគាល់បន្តិច បំពោះអ្នកដែលពុំបានរៀនភាសាសំស្ក្រឹតនិងបាលី. តែបើបានពិនិត្យសង្កេតឲ្យជាក់ច្បាស់តាមវិធីដែលបានពណ៌នាមកនេះហើយ អាចនឹងអានភាសារបស់ជាតិបានដោយត្រឹមត្រូវ ។

វគ្គទី ២

ការប្រើពាក្យ

ដើម្បីប្រើពាក្យឲ្យបានត្រឹមត្រូវ គួរតែស្គាល់លក្ខណៈអក្សរដែលមានសំឡេងដូចគ្នាឲ្យប្រាកដ, ព្រោះក្នុងភាសាខ្មែរមានពាក្យខ្លះមានសំឡេងដូចគ្នា តែវិគ្គផ្សេងគ្នា, សូមសំគាល់តាមលេខរៀង, បើលេខដូចគ្នា, សំគាល់ថាអក្សរនោះមានសំឡេងដូចគ្នាឬស្រដៀងគ្នាខ្លះ, ដូចតទៅនេះ :

www.budinst.gov.kh www.elibraryofcambodia.org

## "ក, កំ, ករ"

១ – ក (ន.) បំពង់ក, គល់ក, កដៃ, កជើង, កស្រូវ . . . ។

១ – ក (កិ.) តាំងផ្ដើម, តាំងធ្វើ, កសាង, កកើត, កភូមិ, ករត្ន . . . ។

១ – កំ (និ.) ពាក្យមានសំឡេងកញ្ចក់ខ្លី សម្រាប់និយាយតប្រយោគដោយខ្សែក ហៅថាសន្ធាន : ខ្នងកំកោង, សក់កំស្កូវ, អ្នកកំទៅ, ខ្ញុំកំទៅ, ស្រុកកំក្រ, អង្គរកំថ្មី . . ។

១ – ករ (ន.) ភាសាសំស្ក្រឹតឬបាលី ប្រែថាដៃ : លើកករប្រណម្យ គឺលើកដៃប្រណម្យសំពះ ។

និទានរឿង ទី ១

មានតាព្រឹទ្ធាចារ្យម្នាក់ជាមនុស្សកំសត់ អត់អាហារមានតែកដៃកជើងស្គម ជុកជប តែគាត់កកវែង ខ្នងកំកោង ហោះនឹកកំស្លៀក ក្អកកំទងើត អន្ទុងដៃក្បៀវ លើកករប្រណម្យសូមទានគេ, ព្រោះគាត់ពុំបានកសាងកុសលពីជាតិមុនមក ។

## "កល, កល់"

២ – កល (ន.) ភាសាសំស្ក្រឹតឬបាលី ប្រែថា : ល្បោស, ល្បោសវៃ, ឧបាយយ៉ាងល្អិត . ល្បិច : ឧបាយកល, បាញ់កល, កលមិតល្បះគិត . . . ។

២ – កល់ (កិ.) សើមទ្រទ្រង់ពីក្រោមឲ្យស្មើ ឬឲ្យហើបខ្ពស់ : កល់គុ, កល់គ្រែ, កល់ស្ពាន, កល់ទូ . . . ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ២

*កំណល់ដែលកល់ស្ពាននេះ ជាឧបាយកលទេ! កុំជាន់ប្រយ័ត្ន ធ្លាក់ជួលចាញ់កលគេ ។*

## "កប្ប. កាប់"

៣ — កប្ប (ន.) កាលតាំងនៅយូរអង្វែង : ម្ហូបកប្ប, អស់កប្ប, ភទ្ទកប្ប, ភ្លើងប្រល័យកប្ប ... ។

៣ — កាប់ (កិ.) សម្រេច, ផ្តាច់, ប្រហារដោយគ្រឿងមានមុខមុត មានដាវនឹងកាំបិតជាដើម : កាប់ដី, កាប់ព្រៃ, កាប់ឈើ ... ។

ឧទាហរណ៍ ទី ៣

*ព្រៃធំយ៉ាងហ្នឹង អ្នកឯងកាប់មួយថ្ងៃខាន ១០ ថ្ងៃយ៉ាងនេះ កាប់អស់មួយកប្បផង ក៏មិនហើយ ។*

## "កម្ម. កាំ"

៤ — កម្ម (ន.) អំពើ : កម្មជាកុសល, កម្មជាផៅពង្ស, កម្មជាពូជ, រងកម្ម, ទទួលកម្ម, តាមយថាកម្ម, យើងអស់កម្មនឹងគ្នាហើយ ... ។

៤ — កាំ (ន.) អ្វីៗដែលគេរៀបជាថ្នាក់ជាជាន់ សម្រាប់ទល់ទ្រ, សម្រាប់រង, កាំជណ្តើរ, កាំរទេះ ។ ឈើឬដែកតូចស្រួចដែលដោតនៅចុងនឹម ក៏ហៅថា "កាំ" ដែរ: កាំនឹម ។ ឫស្សីញកក៏គេហៅថា "កាំ" ដែរ: កាំស្នា, កាំធ្នូ ។ គ្រាប់រន្ទះក៏គេហៅថា "កាំ" ដែរ : កាំរន្ទះ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៤

ទន្ទមាណពធ្វើកម្មផ្សាមក ចំពោះនាងឧប្បលវណ្ណាថេរី លុះចុះពីកុដិនាងមកវិញ គ្រាន់តែផុតកាំជណ្ដើរ ក៏ដួលស្រូលដូចជាត្រូវកាំខ្ទុះប្រហារ ព្រះធរណីក៏ស្រូបទម្លាក់ទៅមហានរក ទៅរងកម្មតែសព្វថ្ងៃ ។

“ក័ណ្ឌ, ក័ណ្ឋ, កាន់”

៥– កណ្ឌ (ន.) ប្រួញ, គ្រាប់កាំភ្លើង, ទង, ដើម, សេចក្តីកំណត់, បរិច្ឆេទ, វគ្គ; ខ្សែ: សាស្ត្រាមួយកណ្ឌ ... ។

៥– ក័ណ្ឋ (ន.) អវយវៈតពីក្បាលភ្ជាប់ទៅស្មា (ក): ព្រះបាទទសកណ្ឋ អ្នកដែលមានក ១០ គឺរាពណ៍ (ក្នុងរឿងរាមកេរ្តិ៍) ។

៥– កាន់ (កិ.) ចាប់ខ្ជាប់: កាន់ដំបង, កាន់ឆត្រ, កាន់បាន ... ។

ឧទាហរណ៍ ទី ៥

មានសាស្ត្រាមួយកណ្ឌ និយាយថា: ព្រះបាទទសកណ្ឋ កាលទៅច្បាំងនឹងព្រះរាម បាននិម្មិតខ្លួនយ៉ាងធំ មានក ១០ ក្បាល ១០ ដៃម្ភៃពាន់ ដៃខ្លះកាន់ដំបង, ដៃខ្លះកាន់ចក្រ, ដៃខ្លះកាន់លំពែង ... ។

“កល្ប, កាល់”

៦– កល្ប (ន.) ដូចពាក្យ (កប្ប) ដែរ: មួយកល្ប, ភ្លើងឆេះកល្ប, រស់នៅគិតបអស់អាយុមួយកល្ប ... ។

www.budinst.gov.kh www.elibraryofcambodia.org

៦- កាល់ (កិ.) ពានគ្នា, ទាស់ទាំងឬជំរឹម : គោកាល់ញី, ឆ្កែកាល់អណ្តើក, កាល់ជើងសក់, កោរកាល់ ... ។

ឧទាហរណ៍ ទី ៦

នែនាង! កុំគិតតែកាលដើងសក់តេក យើងពុំមែនរស់នៅគស់មួយកល្បទេ, ចូរខំកសាងកុសលធ្វើបុណ្យសុទ្ធទានទៅ ប្រយ័ត្នមិនរួចពីភ្លើងឆេះកល្ប ។

"កា, ការ, ការិ, ការណ៍"

៧- កា (ន.) ជាឈ្មោះប៉ុតង់ទឹកមួយបែប ធ្វើដោយលោហធាតុ ឬធ្វើដោយជាតិដី : កាដាក់ទឹក, កាមាស ... ។

៧- កា (កិ.) សរសេរចុះឈ្មោះ ទីលំនៅអ្នកទទួលសំបុត្រលើខ្នងស្រោម ឬសរសេរផ្សេងទៀតថែម : កាខ្នងសំបុត្រ, កាជើងក្អែក ... ។

៧- ការ (ន.) កិច្ចឬអំពើដែលត្រូវធ្វើ : ធ្វើការ, មានការ, ខូចការ, ការល្អ, ត្រូវការ ... ។

៧- ការ (កិ.) បិទបាំង, រាំងរា, ឃាត់ទាំង : ការពារខ្លួន, ការសត្រូវ, មូរសរសៃសូត្រឬអំបោះដោយក្ងារ : ការអំបោះ, ការសូត្រ ។

៧- ការិ (ន.) ភាសាសំស្ក្រឹត ប្រែថា ត្រចៀក, សព្វថ្ងៃប្រើជារាជសព្ទ : ព្រះអង្គម្ចាស់អង្គនេះមានព្រះការិល្អណាស់ ។

៧- ការណ៍ (ន.) ហេតុ, ដំណើរ : ទាស់ការណ៍ហើយ! ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៧

ពីព្រេងនាយមានព្រះរាជាមួយព្រះអង្គដូចព្រះកាណ៌ ទ្រង់ព្រះសណ្ដាប់អ្វី ៗ ពុំសូវបាន ។ ថ្ងៃមួយអាមាត្យចូលទៅគាល់ទូលពីការធ្វើសង្គ្រាម ស្ដេចទ្រង់ព្រះសណ្ដាប់ពុំច្បាស់ បែរជាលើកកាមាស ហុចទៅអាមាត្យឲ្យយកទៅឲ្យស្រីស្នំដែលកំពុងការសូត្រនៅក្រោយដំណាក់ ។ អាមាត្យនឹកក្នុងចិត្តថា "ទាស់ការណ៍ហើយអញ ! ពុំបានសម្រេចការនោះ" ក៏សរសេរសំបុត្រមួយច្បាប់កាខ្ចង់ផ្ញើទៅអាមាត្យទី ២ ឲ្យចូលមកគាល់ព្រះរាជាម្ដងទៀត ។

"កាប, កាព្យ"

៨-កាប (ន.) ឈ្មោះសម្រាប់រឹតគាប : កាបរទេះ; ជាងទានសព្ទកំមាន, សូរសម្រែកថា : ទាស្រែកកាបៗ... ។

៨-កាព្យ (ន.) ដំណើរពាក្យប្អូនមានឃ្លោងឃ្លា : ពាក្យកាព្យ, មេកាព្យ, តែងកាព្យ... ។

ឧទាហរណ៍ ទី ៨

ជាងរទេះគិតតែធ្វើកាបរទេះ មិនដេញតាមផងសោះ ឲ្យកាស្រែក កាបៗ ជូនគេស្ដាប់ពាក្យកាព្យពុំបាន ។

"កិរ្ដិ៍ = កេរ្ដ៍, កេរ, កេ, កេហ៍"

៩-កិរ្ដិ៍ (ន.) សេចក្ដីសរសើរ, របស់តំណាង, របស់ដំណែលពីដូនតា ទុកឲ្យកូនចៅថែរក្សា : ស្រែរកិរ្ដិ៍ពីម្ដាយ, ដីកិរ្ដិ៍ពីឪពុក, ផ្ទះកិរ្ដិ៍ពីជីដូន... ។

www.budinst.gov.kh www.elibraryofcambodia.org

៩–កេរ (ន.) រឿង, ហេតុអ្វីៗ របស់អ្នកឯទៀតដែលផ្ដាំផ្ដង មិនសមគួរ ឬអាក្រក់; បើមានអ្នកណាមួយនាំហេតុនោះមកនិយាយប្រាប់អ្នកដទៃតទៅទៀត, នោះហៅថា និយាយកេរគេ (ប្រើក្លាយពីពាក្យកិរ្តិមក) ។

៩–គេ (ឫ.) ពាក្យសម្រាប់និយាយឥតចេញឈ្មោះអ្នកដទៃ, មិនចេញឈ្មោះចំៈ ខ្ញុំខ្លាចគេ, រកខ្ចីប្រាក់គេ, ផ្ទះរបស់គេ, ចាំគេសិន... ។

៩– គេហ៍ (ឫ.) ពាក្យសម្រាប់ប្ដីប្រពន្ធហៅគ្នាទៅវិញទៅមកដោយស្មោះស្មើៈ គេហ៍អើយគេហ៍, គេហ៍ឆាប់ឡើង, គេហ៍អើលបាយឆ្អែតហើយឬនៅ?, នៅទេគេហ៍!... ។

ឧទាហរណ៍ ទី ៩

*តានតាម្នាក់និយាយហាមឃាត់ប្រពន្ធគាត់ថា: គេហ៍អើយគេហ៍, កុំនិយាយកេរគេពេក! ខ្លួនឯងណាញ់ល្បែងលក់ក្អមម្ដាយអស់ក៏ពុំគិត!*

"ក៏ពី ក៏ប៉=ក៏ពិ"

១០– ក្ពិ (កិ.) ធ្វើឲ្យស្លាប់សាច់, ធ្វើឲ្យរាបទាប : កួតអម្បោះ, ដើមឈើកួតគ្នា, កួតសម្បកថ្មៃ... ។

១០– គ្បិ (ន.) អាចម, ឧច្ចារៈ, លាមក; អវយវៈចំណែកក្រោយវច្ចទ្វារ[(១)] : ដាក់គូថ[(២)]អង្គុយ (ខ្មែរបុរាណហៅត្រពោក, គេនិយាយថា: ដាក់ត្រពោកអង្គុយ (អ្នកចាត់ដំបងនឹងសៀមរាបនៅប្រើពាក្យនេះ) ។

---

១-២ ក្នុងវចនានុក្រមខ្មែរ ឲ្យសរសេរ គូថ តាមទម្លាប់ដែលធ្លាប់ប្រើយ៉ាងនេះមកយូរអង្វែងហើយ, ប៉ុន្តែសំស្ក្រឹតនឹងបាលី គូធ ឬគូទ "អាចម, ឧច្ចារៈ ; គុទ (ទីឃៈឧជាគូទ) សម្គាល់សេចក្ដីក្លាយមកជា "អវយវៈភាគខាងក្រោយវច្ចទ្វារ" : ដាក់គូទអង្គុយ, ដំបៅសាច់គូទ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ទី១០

ខ្ញុំទើបនឹងមកពីក្តួតអម្បោះ អម្បាញ់មិញ ពុំទាន់ដាក់គូថអង្គុយផង ស្រាប់តែឃើញតូចកផល់ ។

"កោដិ, កោដ្ឋ, កោត"

១១- កោដិ (សំ.) បំនួន ១០ លាន : មួយកោដិ... ។

១១- កោដ្ឋ (ន.) ជង្រុក, របស់សម្រាប់ដាក់សព, ដាក់ធាតុ កោដ្ឋប្រាក់, កោដ្ឋមាស កោដ្ឋស្ពាន់... ។

១១- កោត (កិ.) ស្ងើច, ស្ញែង, ខ្លាច, ញញើត, ខាម : គួរកោតគេដែរ, កោតខ្លាច, កោតក្រែង... ។

ឧទាហរណ៍ ទី ១១

- ម្សិលមិញមនុស្សប្រហែលជានមួយកោដិ ទៅមើលបុណ្យហែសពព្រះបរមចក្រពត្រោធិកជ, កោតតែជាងដែលធ្វើកោដ្ឋដម្កល់សពនោះ បេះធ្វើដូចមេ្តចក៏ល្អម្ល៉េះ, គួរឲ្យកោតស្នាដៃជាងដែលធ្វើកោដ្ឋនោះណាស់ ។

"ក្រិត, ក្រិត្យ=ក្រឹត្យ"

១២- ក្រិត (កិ.) លាក់អ្វីៗឲ្យមានស្នាមជាសំគាល់, វាក់ចំណាំ, ក្រិតថ្មចំណាំ, ក្រិតឈើចំណាំ... ។

១២- ក្រិត្យ (ន.) ភាសាសំស្ក្រឹត (កូត្យ=ក្រឹត្យ) ប្រែថា ច្បាប់ : កាន់តាមក្រិត្យក្រម, កាន់ក្រិត្យវិន័យ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១២

អ្នកកាន់ក្រិត្យវិន័យ ត្រូវបេះចាំវិន័យឲ្យច្បាស់ ដូចគេក្រិតថ្នាំចំណាំ កុំឲ្យក័ន្ទប្រែប្រួលខុសជាត្រូវ នាំឲ្យសាប់សូន្យព្រះពុទ្ធសាសនា ។

"ក្រម, ក្រំ"

១៣– ក្រម (ន.) លំដាប់, បែប, ប៉ែក, ពួក, ក្បួន : ក្រមព្រហ្មទណ្ឌ, ក្រមវេជ្ជបវេណី; នាមងារក្នុងដំណែងរាជការឃុំ ក៏ហៅថាក្រមដែរ (ក្លាយមកពីក្រមការ): ក្រមស៊ុន, ក្រមអ៊ាង ។

១៣– ក្រំ (កិ.) ប្រក់ប, បញ្ចុះលោហធាតុផ្សេងៗនឹងដែក : ក្រំមាស គឺយកមាសមកប្រក់ប ឬបញ្ចុះនឹងដែក ។

១៣– ក្រំ (គុ.) ថ្លាំ, ស្ងួតស្ងប់, អន់, សៅហ្មង : ក្រំខ្លួន, ក្រំចិត្ត... ។

ឧទាហរណ៍ ទី ១៣

ក្រមស៊ុននៅភូមិក្បាលពង បេះក្រមវេជ្ជបវេណីយ៉ាងចំណាន គាត់មានកាំបិតក្រំមាសមួយ សៀតបង្កេះដើរទៅលេងបុណ្យកឋិន ស្រាប់តែជ្រុះបាត់រកពុំឃើញ ក៏មានទឹកមុខក្រៀមក្រំពុំសប្បាយ ។

"ក្លិង្គ, ក្លឹង្គ"

១៤– ក្លិង្គ (ន.) ឈ្មោះដែនមួយនៅក្នុងមជ្ឈិមប្បទេស, អ្នកនៅក្នុងដែននោះក៏ហៅក្លិង្គដែរ ។

១៤– ក្លឹង្គ (កិ.) បងទប់, បងឥតកំរើក : ក្លឹង្គរទូត... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៤

មានកុលិន្ទម្នាក់និយាយប្រាប់ថា : នៅស្រុកភ្នំ គេមិនបេះក្លិនខ្ទូត នោបដូចខ្មែរទេ ។

"ខណ្ឌ, ខន្ធ, ខាន់=ខ័ន"

១៥– ខណ្ឌ (ន.) សង្កាត់, ប៉ែក, កំណត់, ប៉ែកអាណាខេត្ត, កំរិត, បំរាមផ្តាច់មិនឲ្យធ្វើ : ទៅមកបានឥតមានខណ្ឌទេ, ខ្ញុំនៅខណ្ឌដីក្រែង ... ។

១៥– ខន្ធ (ន.) ក, ដើម, ពួក, គំនរ, កង, ប្រជុំ, សេចក្តីកំណត់ : ខន្ធ ៥ រូបក្ខន្ធ...., ទំលាយខន្ធ, រំលត់ខន្ធ ... ។

១៥– ខាន់ (ន.) គ្រឿងសាស្ត្រាសម្រាប់កាប់ មានសណ្ឋានដូចលំពែង តែមានដងខ្លី : ព្រះខាន់រាជ្យ ... ។

ឧទាហរណ៍ ទី ១៥

មានលោកគ្រូបាអង្គនៅខណ្ឌពួក លោកសំដែងប្រៀបធៀបខន្ធទាំង ៥ ថាដូចជាព្រះខាន់ដ៏មុះមុត ។

"ខោ, ខោរ"

១៦– ខោ (ន.) សំលៀកធ្វើដោយសំពត់ មានសណ្ឋានច្រើនយ៉ាង មានជើង មានបង្កេះ : ខោជើងវែង, ខោស្នាប់ភ្លៅ, ខោទ្រនាប់ ... ។

១៦– ខោរ (ន.) ឈ្មោះស្វាមួយពួកសម្បុរខ្មៅប្រផេះមាឌធំជាងស្វាក្រុះ មុខខ្លី : ស្វាខោរ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៦

*ជាតិស្វាខោរ បើទុកជាយកមកដាំកើត ចំពាក់អាវខោឲ្យ ក៏នៅតែជាកញ្ចាយ ។*

" គ, គរ"

១៧– គ (គុ.) ឥតសំដី, ឥតសូរ : មនុស្សគ, ប្រាកដ ។

១៧– គរ (ន.) ឈ្មោះឈើស្រុកមួយយ៉ាងឥតខ្លឹម មានសម្លីក្នុងផ្លែ យកសម្លីនោះមកញាត់ពូក ញាត់ខ្នើយ : ដើមគរ, ផ្កាគរ, ផ្លែគរ ... ។

១៧– គរ (កិ.) ដាក់ប្រមូលគ្នាធ្វើឲ្យជាគំនរ : គរក្បាលលើគ្នា, គរឈើក្បែរផ្ទះ, គប្នរក្បែរចិញ្ចើមថ្នល់ ... ។

ឧទាហរណ៍ ទី ១៧

*ម្នាលកូន! ឯងឃើញមនុស្សគ កំពុងអង្គុយលើគំនរឈើ ដែលគេគរទុកក្រោមដើមគរនោះឬទេ? មនុស្សដែលឥតចំណេះវិជ្ជាក៏ដូចជាគរដែរ ។*

" គិល គឹល"

១៨– គិល (ន.) គន្លាក់, ឆល់ : គិលធន្លល, គិលជន្លួញ, គិលមែកឈើ គឺកាត់មែកបាស់បោលដើម្បីឲ្យលាស់ថ្មី ឬគិលមែកទម្លាក់មកដើម្បីបេះផ្លែ, (ប្រើក្នុងពាក្យរាសត្រែមផង) ។

១៨– គឹល (កិ.) សូរសន្ធឹកឮដោយផ្អើល ដោយសំណើច : ចាបផ្អើលគឹល, សើចឮគឹល ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៨

ខ្ញុំចាក់គោមួយដើមទ្រូងលិចដល់គល់ គោស្ទុះធ្លាក់ទៅក្នុងត្រពាំង ក្លុកផ្ដើលគល ។

"គុណ, គុន"

១៩– គុណ (ន.) ដំណើរធ្វើឲ្យចំរើនកើនឡើង : លេខគុណ, គុណ ១០ ជា ២០ ... ។

១៩– គុណ (គុ.) សេចក្ដីចំរើន, ថ្នាក់, ជាន់, លក្ខណៈ, បំណែក, សេចក្ដីល្អ, សភាវៈដែលចំរើនឡើងដោយលក្ខណៈរបស់ខ្លួន : គុណមាតាបិតា, គុណគ្រូ.. ។

១៩– គុន (ន.) ឈ្មោះសិល្បខាងគ្រឿងអាវុធ សម្រាប់ចូលប្រយុទ្ធផ្ទាល់ខ្លួន, ជាបំណោះវិសេសម្យ៉ាងរបស់អ្នកចម្បាំង ក្នុងសម័យបុព្វបុរសរបស់ប្រទេស : គុនដំបង, គុនដាវ, គុនលំពែង ... ។

ឧទាហរណ៍ ទី ១៩

អ្នកដឹងគុណមាតាបិតា តែងមានជ័យជំនះជាដរាប ដូចវៀនបុរស បេះគុនដំបងទំនង់ស្ដេចចោរ ។

"គុម = គុំ, គុម្ព"

២០– គុម (កិ.) ប៉ងដោយអាក្រក់, បងធ្វើការពុំគួរ, ប៉ងគឹងបៀតបៀនបំផ្លាញ, បងគំនុំ : គុមចាក់គ្នា, គុមសម្លាប់សត្រូវ ... ។

២០– គុម្ព (ន. ម. ឋ. គំ = គម់) ពួក, ប្រជុំ, បន, ប្រជុំដើមឈើឬដំណាំផ្សេង ៗ គុម្ពស្មៅ, ពោត ១ គុម្ព ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ២០

*ទេវទត្តគុមសម្លាប់ព្រះសម្ពុទ្ធ បានឡើងទៅលើកំពូលភ្នំគិជ្ឈកូដ រុញថ្មប្រមៀលបន្ទម្លាក់មកលើព្រះសម្ពុទ្ធ ។*

"គូ, គូរ"

២១— គូ (ន.) ស្នាមគោះព័ទ្ធជុំវិញបន្ទាយឬកំពែង, ពាក្យបុរាណហៅថា រសិណា : ជីកគូ ; ចំនួនពីរផ្គុំគ្នា ក៏ហៅថាគូដែរ : មួយគូ, ពីរគូ, បីគូ, គូស្រករ គូស្នេហា ... ។

២១— គូរ (កិ.) ធ្វើឲ្យកើតជារូបភាពសព្វសារពើ ដោយដីខ្មៅ, ប៉ាកកា ឬដក់ : គូររូប, គូរគំនូរ ... ។

ឧទាហរណ៍ ទី ២១

*ក្បាច់ចម្លាក់ នៅប្រាសាទអង្គរវត្ត ដែលជាស្នាដៃរបស់បុព្វបុរសខ្មែរ ជាក្បាច់ល្អអស្ចារ្យ ពុំអាចគូរប្ដូរតាមឲ្យដូចបាន, នៅខាងក្រៅប្រាសាទនោះមានជីកគូព័ទ្ធជុំវិញ ។*

"គ្រា, គ្រាហ៍"

២២— គ្រា (ន.) កាល, សម័យ : គ្រាក្រ, គ្រាកើតទុក្ខ, គ្រានេះ, គ្រានោះ, គ្រាមុន, គ្រាក្រោយ ... ។

២២— គ្រាហ៍ (ន.) ដំណើរអង, អបអង, កៀកអង : ប្រើក្លាយជាកិរិយា : គ្រាហ៍មនុស្សប្រុស, គ្រាហ៍មនុស្សផង, គ្រាហ៍មនុស្សស្រីវង ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ២២

គាស់ចិត្តពុកណាថា : " ជនគ្នាក្នុងគ្រោក សម្បូរណ៍ក្នុងខែកក្ដិក " . ដែលជនគ្នាក្នុងក្រោក្រនោះ ដូចជាមាត្តរមាណព ដែលលិចសំពៅ កណ្ដាលសមុទ្រ ខំហែលយោនគ្រាហ៍មាតាបស់ខ្លួន ដកចមាខខេទ-តាមកដ្ឋាយ ។

" ង, ងរ "

២៣– ង (គុ.) ដែលមានរំពត់ខាងលើ ឬខាងចុងហើយស្ដើងឡើង: ដងកាំបិតបន្ទោះង គួចង, ក្ដារង, ឈើង, មុខង ... ។

២៣– ងរ (កិ.) សំដែងអាការមាយា ដោយធ្វើឲ្យស្រឡាញ់ ឬដោយអាក់អន់ចិត្ត : ងរចុះងរឡើង ... ។

ឧទាហរណ៍ ទី ២៣

គាមាក់ជាមនុស្សចិត្តស្រាល តែនិយាយតាស់ចិត្តធំក្រអឺម, គាត់ចិញ្ចឹមជីវិត តែនឹងកាំបិតបន្ទោះមួយមានចងខ្សែបែកនេះ ។

" ងា, ងារ "

២៤– ងា (កិ.) លើកដៃដន្ទ ឬលើកដៃភសះង៉, សំនាំគុខ : ងាដៃ, ងាដៃដន្ទ ... ។

២៤– ងារ (ន.) មុខការ, ដំណែងរាជការតាមបណ្ដាស័ក្តិ, តាមក្រសួង, យសស័ក្តិ ; ងារជាមេឃុំ, ងារជាព្រះគ្រូ ...; ឬភាគដីល្មមកំលាំងបុរសធ្វើមួយពេលហើយ : ដីមួយងារ ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ២៤

ពូប្រញាប់ការជាមេឃុំ គាត់មានគោលៀនមួយទឹម គោនោះស្រៀវ ណាស់ត្រាន់តែឆៃផនុ សុះស្ទើរចង់មិនឈ្នះ គាត់ក្លាស្រែមួយព្រឹក បានប្រញាប់ការ ។

"បិ, បិរ"

២៥– បិ (កិ.) ពុះឈើបំបែកជាពីរៈដោយដំងភ្លុក : មនុស្សជាន់ដើម ច្រើនបេះឈើធ្វើការ ។

២៥–បិ (ន.) ស្បែប្រហុាំង គឺស្បែរសដែលគេធ្វើជាងបញ្ហាំងស្រមោលរូប ស្បែកជាប់រហោក : បហ្វាំង ឬបណាំង; ឈ្មោះឆ្នាំទី ១១ : ឆ្នាំប ។

២៥– បិរ (កិ.) ប្រព្រឹត្ត, ដើរ, ទៅ, ត្រេច : បរនាអាកាស ... ។

ឧទាហរណ៍ ទី ២៥

មនុស្សជាន់ដើមគានណាវេទ គេយកដំងភ្លុកបះឈើធ្វើការ, ច្រើន តែនាំគ្នាទៅដំងពូជេបរទៅកាន់គលឈើដែលរលំ កាបបជាបន្ទះតូចៗ ឬជាគ្នារ ទើបគេដឹកជញ្ជូនយកមកផ្ទះ ។

"បក្ក=បក្រ, បាក់"

២៦–បក្រ (ន.) កង់, កង់អាចកាំ, អាវុធមានសណ្ឋានជារង្វង់មូលមាន ធ្មេញជាប់គ្នាជុំវិញមានមុខមុត, មណ្ឌល, រង្វង់មូល, ប្រទេស, អាណាខេត្ត, ពួក, ហ្វូង, កងទ័ព : ចក្ររបស់ស្តេចចក្រពត្រាធិរាជ ។

www.budinst.gov.kh www.elibraryofcambodia.org

២៦– ចាក់ (កិ.) ចុះដោយគ្រឿងប្រហារមានមុខស្រួច, យកអ្វីៗ ក្រោអំពីគ្រឿងប្រហារចុះឬរុក : ចាក់មួយកាំបិត; ចាក់ទឹកចោល ... ។

ឧទាហរណ៍ ទី ២៦

អាវុធមួយប្រភេទសំរាប់ដាក់ជណ្ដោះបង្អួចស្រុក ចក្រនេះមានមហិទ្ធិឫទ្ធិណាស់ បើគេបោះទៅទិសណាអាចចាក់គាត់ខ្មាំង ឬចាក់កំពែងទិសនោះឲ្យរលំលោះបាន ។

"ប័ណ្ណ=បណ្ណ.ចាន់=ច័ន បន្ទុ=ប(ន្ទ.បន្ទ័"

២៧– ប័ណ្ណ (ន.) ពាប, ក្ដា, ហិរ : មនុស្សប័ណ្ណ ។

២៧– ប័ណ្ណ (ន.) កំណាច, សេចក្ដីក្រោធ, កំហឹង : ទឹកប័ណ្ណធំសុក (ពាក្យហៅដោយសន្ធិតបញ្ចៀសឈ្មោះស្រា) ។

២៧– ចាន់ (ន.) ឈ្មោះឈើមានផ្លែ កាលនៅខ្ចីមានរសចត់ លុះគល់ទុំមានរសផ្អែមក្លិនប្រេះហើរឈ្ងប់ : ផ្លែចាន់, ស្ពឹកចាន់, ចាន់ទុំ ... ។

២៧– បន្ទុ (ន.) សភាវៈសម្រាប់បំភ្លឺលោកក្នុងវេលាយប់ : ព្រះចន្ទ, ដំណើរព្រះចន្ទ ឬថ្ងៃចន្ទ ... ។

២៧– បន្ទន៍ (ន.) ឈ្មោះឈើមានក្លិនក្រអូប : ចន្ទន៍ស, ចន្ទន៍ក្រហម, លំអិតខ្លឹមចន្ទន៍ ... ។

ឧទាហរណ៍ ទី ២៧

កាលពីព្រេងនាយមានរឿងដំណាលថា : បើគល់ថៃ្ងពេញបូណ៌មី

www.budinst.gov.kh www.elibraryofcambodia.org

វែកត្តិករហើយ នៅវេលាយប់ដែលមានព្រះចន្ទពេញវង់ ស្តេចរមៀ

តែងលាបស្រលាបកាយដោយល័អិតខ្មៅខ្ចូនក្រហម ហើយសោយទឹក

ចំណាស្រើនផ្ទួលនៅក្រោមដើមតាទ ។

“ថារ, ថារ៍”

២៨- ថារ (កិ.) ធ្វើរបងតាប ៗ ដោយដោតចម្រឹងឲ្យជាថារឹក : ថារ

ចំណារ, ថារសាស្ត្រ, ថាររបង ... ។

២៨- ថារ (ន.) ឈ្មោះឈើមានផ្កាក្រហមក្លិនឆ្អាប : ដើមថារ,

ផ្កាថារ, ... ។

២៨- ថារ៍ (ន.) បំពង់ឬឡូតម្ជួល ធ្វើដោយមាស ឬប្រាក់ដោត

នឹងខ្សែ សម្រាប់ពួកស្ត្រីក្នុងកម្ពុជរដ្ឋពាក់ដើម : ថារ៍មាស, ពាក់ថារ៍ ... ។

ឧទាហរណ៍ ទី ២៨

ថារ៍មាសរបស់កូនខ្ញុំសុទ្ធល្អណាស់ ពណ៌ក្រហមទុំ ដូចផ្កាថារ ។

“បិត, បិត្ត”

២៩- បិត (កិ.) កាត់ជាចំណិត : បិតបន្លែ, បិតឡើងនៃ ... ។

២៩- បិត្ត (ន.) ធម្មជាតិសម្រាប់សន្សំអារម្មណ៍, សម្រាប់គិត : បិត្ត

ល្អ, ...បិត្តអាក្រក់, សប្បាយបិត្ត ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ទី ២៩

មានឧបាសិកាម្នាក់ជាអ្នកមានចិត្តជ្រះថ្លាក្នុងការកុសល វេលាមាន
បុណ្យទានម្ដងៗ ច្រើនចូលចិត្តក្នុងការដាំស្ល មានចិតថ្លៃជាដើម ។

"បើក, បើប"

៣០–បើក (ន.) ឈ្មោះដំណាំមានស្លឹកប្រើការ មានផ្លែជាអាហារ:
បេកណាំភី, បេកស្ងួន, បេកពងមាន់ បេកអង្គ្លង, បេកខ្លួន, បេកជ្វា ... ។

៣០–បើប (ន.) ស្នូរសម្រែកមួយបែប : ក្មេងស្រែកបេប, កណ្ដុរ
ស្រែកបេបៗ... ។

ឧទាហរណ៍ ទី ៣១

កណ្ដុរស្លេះដណ្ដើមបេកគ្នាស៊ីត្មាត់បេប ។

"ហោត, ហោទ, ហោទក៍"

៣១–ហោត (គុ.) ទីទៃពីទេរតីចំហុង : ប្រាំងហោត ; ឈ្មោះក្ដាម
សមុទ្រមួយពួក ហៅក្ដាមហោត ... ។

៣១–ហោទ (កិ.) តៀន, ដាស់តៀន ; ស្នូរដំណឹង ; ដាក់ទោស
ណោទ ; ប្ដឹង, ប្ដឹងប្រកាន់ ; ហោទជាល្មួច, ហោទឡើក, ហោទប្រកាន់ ... ។

៣១–ហោទក៍ (ន.) អ្នកហោទ : ខាងហោទក៍អាងជាឃើញ ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៣១

គាម្នាក់ក្នាត់ដើរធ្លាក់ទៅក្នុងជ្រោះបោក គាត់បោចថាខ្ញុំប្រែរានគាត់;

ខាងបោទក៍ បោចថែបនេះ គឺបោចដោយក់ហាង ។

" ប្បា, ប្បារ "

៣២– ប្បា (ន.) ឈ្មោះឈើផ្កាមួយប្រភេទ ផ្កាឥតក្លិន : ផ្កាប្បា ,

ដើមប្បា ... ។

៣២– ប្បារ (ន.) សួនដំណាំផ្កា, ទីដីដាំបន្លែឬដំណាំភាយរង

ផ្សេង ៗ : ប្បារផ្កា, ប្បារអំពៅ ... ។

ឧទាហរណ៍ ទី ៣២

នៅមុខវិហារវត្តប្បាអំពៅ មានសួនប្បារមួយធំទេរដាសដោយ

ផ្កាប្បានិងផ្កាចំប៉ី; ខាងក្រោយវត្តនោះ មានប្បារដំណាំដាច្រើន ។

" ប្បុត, ប្បុតិ "

៣៣– ប្បុត (កិ.) ឃ្លាត, របូត, ស្លាប់, ដែលស្លាប់ហើយ, ច្រើន

និយាយចំពោះទេវតាអស់ជីវិត : ទេវតាប្បុត, ទេព្វប្បុត ... ។

៣៣– ប្បុតិ (ន.) កិរិយាឃ្លាត, សេចក្ដីស្លាប់ : ការប្បុតិ, ដំណើរ

ប្បុតិ ... ។

ឧទាហរណ៍ ទី ៣៣

កិរិយាប្បុតិរបស់នាងមហាមាយា ចាំទុកជាការប្បុតិ របស់ទេវ-

តាទាំងឡាយដែលប្បុតក្នុងកាលទាំងពួង ។

## "ឆន, ឆាន"

៣៤-ឆន្ទ (ន.) ឈ្មោះដំណើរពាក្យឃ្លោង មានកំណត់ដោយអក្សរដែលត្រូវរៀបរៀង តែងឆន្ទ ... ។

៣៤-ឆាន់ (កិ.) បរិភោគ, ស៊ី : និមន្តលោកឆាន់, ឆាន់បបរ, ឆាន់បារី, ឆាន់ភេសជ្ជៈ ... ។

៣៤-ឆាន់ (វ្យ.) ពាក្យសម្រាប់ព្រះថេរៈនិយាយចេញឈ្មោះខ្លួនថាខ្ញុំទៅកេកិច្ចទីវស្សាឬសាមណេរ : ឆាន់មិនសូវស្រួល ... ។

ឧទាហរណ៍ ទី ៣៤

*បើព្រះតេជព្រះគុណឆាន់ហើយ មេត្តាតែងឆន្ទមួយឲ្យខ្ញុំព្រះករុណា ។ លោកឆាន់រលាស់ ។*

## "ឆា, ឆា"

៣៥-ឆា (ន.) ឈ្មោះសម្លមួយយ៉ាងឬដោយមានសាច់ក្ដាញ់ ឬក្ដាញ់ចម្រាញ់ឮស្ងួតឆា ១ : ឆាមី, សម្លឆា, ឆាបន្លែក, ឆាទឹក, ឆាគោក ... ។

៣៥-ឆា (កិ.) ធ្វើសម្លឆា, ស្ងួឆា ; ពាក្យប្រៀបគ្រោងមើលមុន, ល្បងមើលមុនដើម្បីឲ្យដឹងទំនង : ឆាតាលមួយលើកទៅចុះ ... ។

៣៥-ឆា (គុ.) ដែលប្រែះស្រាំ : បានឆា, ផ្តិលឆា ...; ពាក្យប្រៀប ប្រែះឆាគឺ:មោះមៃនឹងក្ដាបត្តិចបន្តួច : នាំឲ្យប្រែះឆាចិត្ត, ធ្វើសង្ស័យឲ្យប្រែះឆា ... ។

៣៥-ឆា (កា.) ឮស្ងួតឆា ដោយ ឆាក្ដាញ់ ។

www.budinst.gov.kh www.elibraryofcambodia.org

៣៥- ឆ៊ា (ម.) ពាក្យបន្ទរក្នុងបទច្រៀង, ទទួលសង្វាក់ភ្លេង ។

ឧទាហរណ៍ ទី ៣៥

តែឮសំឡេងអ្នកទទួលសង្វាក់ភ្លេង ស្រែកឆ៊ា ៗ វេលាណា នាំឲ្យ

ប្រែះធាចិត្តខ្ញុំ ទោះទិទទួលមានសុខតែសម្ងំ កំពុំសប្បាយចិត្ត ។

"ឆ្មា, ឆ្មារ"

៣៦- ឆ្មា (ន.) បសុសត្វចតុប្បាទមួយយ៉ាង ជាសត្រូវនឹងកណ្ដុរ :

សព្វឆ្មា, ឆ្មាខ្មៅ ... ។

៣៦- ឆ្មារ (គុ.) តូចបំផុត, សម្រាប់ហៅវត្ថុដែលតូចវែង ឬសំឡេង

តូចស្រួច : អម្បោះឆ្មារ, សំឡេងឆ្មារ, សក់ម្ជុលឆ្មារ ... ។

ឧទាហរណ៍ ទី ៣៦

ខ្ញុំមានឆ្មាឈ្មោលមួយ រោមវាល្អិតឆ្មារ ដូចសរសៃសូត្រ, សំឡេង

វា កំពុងស្ងួតឆ្មារពិរោះគួរឲ្យស្ដាប់ ។

"ឆ្ដោ, ឆ្ដោរ"

៣៧- ឆ្ដោ (ន.) ឈ្មោះត្រីស្រែកាមួយយ៉ាងពួកត្រីរ៉ស់, កាលនៅ

តូចហៅត្រីផ្ទក់, ធំតទៅទៀតហៅត្រីឆ្ដោ, ទៅពីត្រីឆ្ដោទៅទៀតហៅរាហូ ។

៣៧- ឆ្ដោរ (ន.) មាសតាន់ដែលពុំទាន់របនាធ្វើអ្វី ១, មាសដុំ :

មាសឆ្ដោរ, ឆ្ដោរមាស ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៣៧

មានរឿងព្រេងមួយដំណាលថា : មានយាយចាស់ម្នាក់ ចាប់បានត្រីឆ្តោមាសមួយ ដែលព្រះឥន្ទ្រនិម្មិត, គាត់យកទៅថ្វាយព្រះរាជា, ព្រះអង្គបានព្រះរាជទានមាស ៧ ឆ្តោរឲ្យជារង្វាន់ ។

" ជន់, ជន, ជន្ម "

៣៨– ជន់ (កិ.) ឡើងដោយសាយភាយ : ទឹកជន់ ; ពាក្យប្រៀបបរិបូរ ពោរពាស, ច្រើននិយាយតែអំពីភោជនាហារ : ថ្ងៃនេះក៏ជន់ពោរពាសម៉្លេះ រកតែទទួលទានពុំអស់ ។

៣៨– ជន (ន.) ភាសាបាលី សព្វសត្វដែលកើតក្នុងលោក, មនុស្ស, អ្នកផង: បណ្ដាជន, ពួកជន, ជនពីរនាក់ ... ។

៣៨– ជន្ម (ន.) ភាសាសំស្ក្រឹត កំណើត, ជីវិត : ព្រះជន្ម, ជីពជន្ម, ទ្រង់ព្រះជន្មនៅ ... ។

ឧទាហរណ៍ ទី ៣៨

លោកគ្រូខ្ញុំបានថេរដីកាថា " កាលលោកមានព្រះជន្ម ២៥ ឆ្នាំ មានទឹកជន់លិចភូមិនេះម្ដង, ពួកបណ្ដាជន ធ្វើស្រែពុំកើតសោះ ក្នុងឆ្នាំនោះ " ។

" ជប, ជប់ "

៣៩– ជប (កិ.) ខ្ជុំប, ស្វាធ្យាយខ្ជុំបៗ, សូត្រភាវនាមន្តអាគម

www.budinst.gov.kh www.elibraryofcambodia.org

ខ្សឹប ៗ ឬសូត្រដោយនឹកតែក្នុងចិត្ត : ឥសីជប គឺឥសីសូត្រភាយមន្តខ្សឹប ៗ ឲ្យកើតជាអ្វី ៗ តាមបំណង ។

៣៩– ជប (ន.) កិរិយាខ្សឹប, ដំណើរខ្សឹប : ការជបរបស់ពួកឥសី, ព្រះរាជជប ... ។

៣៩– ជប់ (ន.) កន្លែង, ប្រទេស ឬអាកាដែលបិទ : ជប់ភ្នំ. ធ្វើស្រែដោយសារទឹកហូរមកពីជប់ ។

៣៩– ជប់ (កិ.) ដញ្ជក់ ស្រូប, បិតដោយផ្អប់បបូរមាត់ទាំងពីរខ្ទប់គ្នា : ម្ដាយជប់បង្អើយកូន ... ។

ឧទាហរណ៍ ទី ៣៩

*ឈុតក្បាលតាឡូវ៉ែកយក្ស ដែលព្រះឥសូរជបឲ្យ បោះទៅឰដ៏អាកាស អាចជប់ស្រូបធាតុទឹកបណ្ដាលឲ្យរាំងភ្លៀងអស់ ១២ ឆ្នាំ ។*

## "ជាត, ជាតិ"

៤០– ជាត (គុ.) ដែលកើតហើយ, ដែលមាន, ដែលប្រាកដហើយ : ជាតឲ្យបីជំហាន, ជាតឲ្យរត់មុន ១៥ នាទី, ដែលមានរសជាតិ ..... ។

៤០– ជាតិ (ន.) កំណើត, ការកើត : មួយជាតិ, ពីរជាតិ, រសជាតិ, ជាតិជូរ. ជាតិហឹរ ... ។

ឧទាហរណ៍ ទី ៤០

*ខ្ញុំកើតក្នុងជាតិនេះឥតខ្លាចនរណាទេ ខាងការដើរប្តូរគេ ខ្ញុំហ៊ាន ជាតឲ្យដើរឲ្យគេមុនជានិច្ច ។*

## " ជី, ជីរ, ជីវ៍ "

៤១- ជី (ប.) អ្នក; ឯង, ពាក្យគួរសមសម្រាប់ហៅក្មេងប្រុសដែលទើបសឹកពីសាមណេរ ឬសម្រាប់អ្នកធំ, អ្នកចាស់ហៅអ្នកតូចជាង ឬក្មេងជាងដោយរាប់អាន : ជីឯងទៅណា ... ។

៤១- ជី (ន.) ស្ត្រីដែលកោរសក់ស្លៀកដណ្តប់សំពត់ស កាន់សីល : ដូនជី, យាយជី ...; អ្វីៗដែលមានរសជាតិធ្វើឲ្យដំណាំលូតលាស់ល្អ : ជីដី; ទម្ងន់អនុភាគអំពីជម្លឹង : មាសទម្ងន់ពីរជី ... ។

៤១- ជីរ (ន.) ឈ្មោះដំណាំមួយពួកសម្រាប់ប្រើស្លឹកជាររបោយ ឬបង់បំបាត់ក្លិនឆ្អាប : ជីរនាងវង, ជីរអង្កាម, ជីរស្លឹកគ្រៃ ... ។

៤១- ជីវ៍ (ន.) ក្លាយមកពីជីវៈ ; ពាក្យសម្រាប់ហៅព្រះពុទ្ធរូបអង្គធំ ៗ ដោយសន្មតថាដូចជាព្រះអង្គមានព្រះជន្មនៅ : ព្រះជីវ៍ ។

ឧទាហរណ៍ទី ៤១

*យាយជីនៅវត្តអង្គរ មានចៅប្រុសម្នាក់ ទើបនឹងសឹកពីសាមណេរ ឈ្មោះជី មុំ គាត់ប្រើឲ្យទៅកើបអាចម៍ប្រចៀវ ក្នុងប្រាសាទនគរវត្ត ត្រង់កន្លែងដម្កល់ព្រះជីវ៍ធំៗ យកមកធ្វើជីដំណាំ ព្រោះគាត់ស្រឡាញ់ដាំជីរណាស់ ។*

## " ជូ, ជូរ "

៤២- ជូ (គុ.) ដែលឆ្គងមិនសូវមានក្តីគួរសម : មនុស្សជូ, ជូជង, ជូជាតិ, ជូរ ... ។

www.budinst.gov.kh www.elibraryofcambodia.org

៤២- ផ្លូវ (ន.) របៀបរៀបរៀងតគ្នា : ឈរជាផ្លូវ, ពោត ៦០ ផ្លូវ ; ដំណារវង្សត្រកូលនៃបុព្វបុរស, ជំហួរ, ផ្លូវខាងម្ដាយ, ផ្លូវខាងឪពុក... ។

ឧទាហរណ៍ ទី ៤២

បណ្ដាសិស្សដែលឈរជាផ្លូវនេះ មានសិស្សម្នាក់ជាគេងអាក្រក់ផ្ងាត, គេងនេះត្រូវជាញាតិផ្លូវខាងឪពុកខ្ញុំ ។

"ជោក, ជោគ"

៤១- ជោក (កិ. ឬ កិ. វិ.) ទទឹកជ្រាបសព្វ : ភ្លៀងជោកដី ទទឹកជោក; ពាក្យប្រៀបៈ ជ្រាបសព្វសាច់, ស៊ប, ជ្រុល : ជោកចិត្ត, ស្រវឹងជោក, ស្គាល់ជោកជាំ ... ។

៤៣- ជោគ (ន.) សេចក្ដីសុខស្រួល, សេចក្ដីសមប្រកប, សេចក្ដីកើតការ : ថ្ងៃមានជោគ, មនុស្សមានជោគ, អ្នកមានជោគ, ព្រះមានជោគ : ជោគជ័យ ... ។

ឧទាហរណ៍ ទី ៤៣

ខ្ញុំជាមនុស្សអត់ពូតជោគ មានគូនពីអ្នកនៃវ សុខ្វៃជាអ្នកស្រវឹងជោក, ម្សិលមិញភ្លៀងខ្ទទឹកជោកមុងកខ្លួនកាសំ កំពុំគិត ។

"ញាត, ញាតិ"

៤៤- ញាត (ន.) ដែលញ៉ាំកដុកដិត ដោយស្មោះឬស្បូវនឹងឈើតូចៗ: ញាតញ៉ាក, ព្រៃនុះ ញាតណាស់ ; ប្រើផ្សំនឹងស្បាតក៏មាន : ព្រៃញាតស្បាត ។

www.budinst.gov.kh www.elibraryofcambodia.org

៤៤– ញាតិ (ន.) អ្នកដែលរួមខ្សែលោហិតនឹងគ្នាខាងមាតាឬបិតា : ញាតិ ៧ សន្តាន, ញាតិខាងឪពុក, ញាតិខាងម្តាយ, សាខាញាតិ ... ។

ឧទាហរណ៍ ទី ៤៤

ព្រៃញាតនេះ ពីដើមជាព្រៃរបស់ឪពុកខ្ញុំ, ឥឡូវបានទៅញាតិខ្ញុំម្នាក់នៅភូមិខាងត្បូង ។

" ដ, ដ៏, ដរ "

៤៥– ដ (ន.) ទីចម្លង, កំពង់ចម្លង : កំពង់ដ ; ទូកសម្រាប់ចម្លងនៅកំពង់នោះ ក៏ហៅថាដដែរ : ទូកដ ។

៤៥– ដ៏ (គុ.) ដែល, ដែលជា, ពាក្យជាវិសេសនៈ មានសំឡេងខ្លីកំបុត សម្រាប់និយាយផ្សំនឹងគុណនាម ដែលគួរប្រកបជាមួយផង ; ធម៌ដ៏បវរ, ទ្រព្យដ៏ប្រសើរ ... ។

៤៥– ដរ (ន.) អំពីកេតដែលកើតឡើងដោយប៉ះទង្គិច : ដំបៅដរ, របួសដរ ; និយាយផ្ទុយក៏មាន : ដររបួស, ដរដំបៅ, ដររបួស ... ។

ឧទាហរណ៍ ទី ៤៥

ខ្ញុំចង់ជិះទូកដ យកសំពត់ដ៏មានតំលៃ ទៅជូនជីដូនខ្ញុំ តែពុំទាន់ហើនទៅ ខ្លាចដរដំបៅ ។

" ដា, ដារ "

៤៦– ដា (ន.) បន្ទះថ្មធំរាបដូចក្តារបែន ; និយាយថា ថ្មដា ។

www.budinst.gov.kh www.elibraryofcambodia.org

៤៦- ផារ (ន.) ឈ្មោះបុណ្យមួយក្នុងកម្ពុជរដ្ឋ ជាបុណ្យទក្ខិណានុប្បទាន ឧទ្ទិសចំណែកបុណ្យ ជូនទៅបុព្វបេតបុគ្គល ដែលចែកឋានទៅកាន់បរលោកហើយ : ធ្វើបុណ្យផារ, និមន្តលោកផារ, ស្ងួត្រផារ, ... ។

ឧទាហរណ៍ ទី៤៦

នៅក្រោមដើមពោធិ ក្រោយផ្ទះខ្ញុំមានបព្វជាមួយ ជុំ គេតែងនាំគ្នាទៅធ្វើបុណ្យផារក្រោមដើមពោធិនោះរាល់ ៗ ឆ្នាំពុំដែលខាន ។

"ផុស, ផុះ"

៤៧- ផុស (កិ) ខាត់, រលីង, ពួត ; ជំរះដោយសាប៊ូ : ផុសខោអាវ, ផុសខាត់, ផុសក្អែល... ។

៤៧- ផុះ (កិ.) ផាប់កើត កកើត ; មានពន្លក : មានដើមដុះឡើង ស្រូវផុះ, ពោតផុះ, ដីផុះ ផុះពុកចង្កា ... ។

ឧទាហរណ៍ ទី ៤៧

កុមារម្នាក់អង្គុយផុសខោអាវ ក្បែរមាត់ស្រះមួយ ដែលមានដើមអម្ពិលទាកផុះពន្លកជុំវិញ ។

"ណា, ណា!"

៤៨- ណា? (សព្វ) ពាក្យជាអនិយតសព្វ ប្រាប់សេចក្តីមិនទាន់ទៀង, មិនទាន់ប្រាកដឬមានអាការជាសេចក្តីសង្ស័យ : ទៅណា? មកពីណា? បុរសណា? ... ។

www.budinst.gov.kh www.elibraryofcambodia.org

៤៨– ណាំ! (ឧ.) ពាក្យនិបាតមានសំឡេងវៀងខ្ពស់ស្រួច ឬស្រទន សម្រាប់និយាយបញ្ជាក់សេចក្ដីឲ្យបានច្បាស់ជាងមានអាការៈហាក់ដូចជាធ្ងល់ ; និយាយទៅរកបានចំពោះតែមនុស្សអ្នកតូចជាង ឬដែលស្និតស្នាល, ដែលស្មើគ្នា : នែ! ទៅកុំបានណាំ!, បាត់យំទៅណាំ!, នាងណាំ!; សរសេរបាន ៤ បែប : ណាំ!, ណាំះ! ហ្នាំ!, ហ្នាំះ!, ។

ឧទាហរណ៍ ទី ៤៨

កូនស្រី ម្ដាយនាំទៅណា? ទៅមើលបុណ្យភ្ជុំបិណ្ឌ? ល្ហើយកូន ម្ដាយណាស់ កុំទៅណាំ! នាំណាំ! ។

"ត្រស់, ត្រស្ដិ"

៤៩– ត្រស់ (ន.) ឈ្មោះឈើវនាមមួយយ៉ាង ត្រួយមានរសចត់, ប្រើជាថ្នាំរមាស់កមកំបាន : ដើមត្រស់ ... ។

៤៩– ត្រស្ដិ (ន.) ឈ្មោះរាជពិធីមួយយ៉ាងធ្វើក្នុងវេលាយប់ ១៤ រោចខែផល្គុន; ក្នុងរដ្ឋកាលពីបុរាណ ហៅថាពិធីបញ្ចាន់ត្រស្ដិ, សម័យឥឡូវហៅថាពិធីភាណយក្ខ ; ពាក្យត្រស្ដិនេះក្លាយមកពីភាសាសំស្ក្រឹតថា : "ត្រុដ" ប្រែថាកាត់ផ្ដាច់ : បុណ្យបញ្ចាន់ត្រស្ដិ ។

ឧទាហរណ៍ ទី ៤៩

ខ្ញុំអង្គុយសម្រាកក្រោមដើមត្រស់ ស្រាប់តែឃើញសំឡាញ់ខ្ញុំម្នាក់មកបបួលទៅមើលពិធីបញ្ចាន់ត្រស្ដិ ។

www.budinst.gov.kh www.elibraryofcambodia.org

"ត្អូ, ត្អូរ"

៥០– ត្អូ (ន.) ឈ្មោះឈើធំសាច់ស្វិត ច្រើនដុះនៅទីទំនាប, នៅព្រៃបឹង ឬ មាត់ទន្លេ-ស្ទឹង-ព្រែក ជាឈើសម្រាប់ធ្វើឧស : ឧសត្អូ, ដើមត្អូ, សំបកត្អូ ...។

៥០– ត្អូរ (គុ.ឬកិ.វិ.) ដែលមានមុខធូរសំយ៉ុងចុះ ដោយទាស់ចិត្ត ខុសអធ្យាស្រ័យ : ធ្វើមុខត្អូរ ។

ឧទាហរណ៍ ទី ៥០

*ចោរលួចឧសត្អូគេអុំទូក; ម្ចាស់តាមទាន់: វាក៏ឈរខ្ញាចជាប់ឃុំ ធ្វើមុខត្អូរ ដូចមុខខ្មោច ។*

"ទ, ទរ"

៥១– ទ (ន.) ទ្រនាប់ធ្វើដោយឈើ, ឫស្សី ឬ សង្កសីជាដើម សម្រាប់រង សម្រាប់បង្ហូរទឹក : ទឹកហូរតាមទ ; ផ្ការទឹកភ្លៀងដែលធ្លាក់មកក៏ហៀរទដែរ ។

៥១– ទរ (កិ.) កិនគីដេរ, ស្តីឲ្យ, បន្ទោស, វាយ, ទះ, តប់ ; (ជាពាក្យសាមញ្ញ សម្រាប់និយាយបញ្ចៀងមិនចំពោះដំណើរដេរជាដើមនោះទេ) : ឆ្កែទរបាយអស់, ស្រាប់តែទរខ្ញុំតែម្តង ។

ឧទាហរណ៍ ទី ៥១

*ខ្ញុំក៏ពុនធ្វើទបង្ហូរទឹក ស្រាប់តែឆ្កែទរបាយអស់, លុះឪពុកខ្ញុំមកពីស្រែវិញគាត់ទរខ្ញុំថាឥតគំនិត ។*

www.budinst.gov.kh www.elibraryofcambodia.org

"ទា, ទារ"

៥២- ទា (ន.) ឈ្មោះសត្វស្លាបស្រុកមួយពួក មានម្រាមជើងជាប់គ្នាស្រដៀងនឹងប្រវឹក: ទាកាប៉ា, ទាក្អែក, ទាព្រៃ: ពាក្យប្រៀប: មនុស្សដំណើរទា ។

៥២- ទារ (កិ.) ស្រដីក្រើនយករបស់ដែលគេជំពាក់, ក្រើត, តឿនបន្តឹងយកប្រាក់តាមកំណត់ដែលត្រូវចេញ, ត្រូវបង់: ទារប្រាក់, ទារថ្លៃឈ្នួល, ទារប្រាក់ពន្ធ, ទារបំណាក់ ... ។

ឧទាហរណ៍ ទី៥២

បិទម្នាក់ជំពាក់ប្រាក់ថុទា ១០រៀល, ទៅទារតែ ១ឲ្យតែ៥រៀល ។

"ទិព្វ = ទិព្យ, ទីប"

៥៣- ទិព្វ (គុ.) ដែលជារបស់ទេវតា, ដែលទាក់ទងគ្នានឹងពួកទេវតា, ដែលមាននៅក្នុងទេវលោក: មាត់ទិព្វ, ត្រចៀកទិព្វ, ភ្នែកទិព្វ ... ។

៥៣- ទីប (កិ.) យករបស់អ្វី ៗ ទៅបិទជាគ្រឿងលំអរ, ច្រើនប្រើចំពោះមាសឬប្រាក់ដែលយាទៅកិនឲ្យស្តើង ឬ លំអិតជាកំទេច បិទឬលាបភ្ជាប់នឹងអ្វី ៗ ជាលំអរ: ព្រះទីបមាស, គោកទីបប្រាក់ ... ។

ឧទាហរណ៍ ទី៥៣

ខ្ញុំមានគោកទីបមាសមួយល្អណាស់ ហាក់ដូចជារបស់ទិព្វ ។

www.budinst.gov.kh www.elibraryofcambodia.org

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

## " ទុក, ទុក្ខ "

៥៤— ទុក (កិ.) ដាក់វត្ថុអ្វីក្នុងទីណាមួយដើម្បីឲ្យគង់នៅ ឬរក្សាអ្វី ៗ ដើម្បីឲ្យគង់ : ទុកទ្រព្យ, ទុកមាសឲ្យកូន, ទុកលុយបាយ, ទុកប្រាក់ឲ្យកូន ... ។

៥៤— ទុក្ខ (ន.) សេចក្ដីព្រួយ, សេចក្ដីលំបាក : កើតទុក្ខ, មានទុក្ខ, ទុក្ខព្រោះកូនស្លាប់ ។

ឧទាហរណ៍ ទី ៥៤

*ការព្រាត់ប្រាសចាករបស់ជាទីគាប់ចិត្ត ដែលបានរក្សាការពារទុកមក ជាហេតុឲ្យកើតទុក្ខ ។*

## " ទូ, ទូរ "

៥៥— ទូ (ន.) បំពោះវត្ថុដែលដាក់ជាក្រយាចំណាង ក្នុងល្បែងភ្នាល់និមួយ ៗ, ប្រអប់ធ្វើដោយឈើឬដែកមានសណ្ឋានជាហិប មានទ្វារ មានជើង សម្រាប់ដាក់វត្ថុទាំងពួង : ទូដែក, ទូដាក់សំពត់អាវ ... ។

៥៥— ទូរ (កិ.) សាកគ្នា, ធៀបគ្នា, ផ្ទឹមគ្នាដើម្បីឲ្យឃើញណាប្រសើរជាង : របស់ខ្ញុំទូរនឹងរបស់អ្នកពុំបានទេ, យកទៅទូរគ្នាមើលសិន ... ។

ឧទាហរណ៍ ទី ៥៥

*សម្បត្តិក្នុងផ្ទះខ្ញុំតិចណាស់ មានតែខ្ទមតូចប៉ុណ្ណោះ យកទៅទូរនឹងសម្បត្តិរបស់អ្នកឯណាបាន ។*

www.budinst.gov.kh www.elibraryofcambodia.org

## "ទូត, ទួត"

៥៦- ទូត (ន.ប្ក.) អ្នកដែលគេបញ្ជូន, ដែលគេប្រើទៅ, អ្នកនាំការ នាំដំណឹងពីម្ខាងទៅម្ខាង : ពួកទូត, បញ្ជូនទូត, រាជទូត, ... ។

៥៦- ទូត (ក.) សួរលាន់ចេញពីអ្វីមួយដែលប៉ោង, ដែលខ្ចប់ មានកញ្ចែកប៉ាល់ជាដើម : ឮសួរទូត ... ។

៥៦- ទួត (ន.) ជាតិជាន់ទី៣តាមផ្លូវខ្សែផ្ទាល់ : តាទួត, យាយទួត ចៅទួត ។

ឧទាហរណ៍ ទី ៥៦

ជីតាទួតខ្ញុំមានសំឡាញ់ម្នាក់នៅប្រទេសថៃ គាត់តែងប្រើទូត ឲ្យនាំដំណឹងទៅមកសួរសុខទុក្ខរាល់ៗឆ្នាំ ។

## "ទេ, ទេរ"

៥៧- ទេ (និ.) ពាក្យបដិសេធ ជាទំនាស់ ផ្ទុយគ្នានឹងពាក្យអើ : ទេ, មិនទៅទេ, ពុំព្រមទេ ... ។

៥៧- ទេរ (គុ.) ដែលទ្រេត, ទ្រេត, ទ្រាល : ដើមត្នោតទេរ, ដីទេរ, ប្រាំងទេរ ... ។

ឧទាហរណ៍ ទី ៥៧

អ្នកឯងពុំដឹងទេឬ? ប្រាំងនេះទេរទេតើ! ម្ដេចក៏មិនចុះទៅ ដៃទទេទេ!

www.budinst.gov.kh www.elibraryofcambodia.org

## "ទេស, ទេសន៍"

៥៨- ទេស (ន.) កន្លែងជាទីនៅអាស្រ័យ ; ប្រទេស , ភូមិ : ស្រុកទេស ... ។

៥៨- ទេស (កិ. វិ.) ដែលដើរសាត់ព្រាត់ ឬសាត់អណ្តែតទៅតាមតែប្រទះ : ដើរទេស, ឆ្មាដើរទេស ... ។

៥៨- ទេសន៍ (ន.) ដំណើរសំដែង, ការសំដែង : ស្តាប់ទេសន៍, និមន្តលោកទេសន៍ ... ។

ឧទាហរណ៍ ទី ៥៨

ស្រុកទេសយើងពីចុកណា នៅវេលាមានបុណ្យទានម្តងៗ គេចូលចិត្តនិមន្តលោកទេសន៍ សាស្ត្រាស៊ីតរ៉េត ។

## "ទោ, ទោរ"

៥៩- ទោ (ប. សំ.) ពីរ, ខ្មែរយើងប្រើតាមទម្លាប់ជាប្ញូរណាស់ឲ្យៈ ជាន់ទោ, សម្រាប់ទោ, យ៉ាងទោ ។

៥៩- ទោរ (គុ.) ដែលទ្រេតឈោងទៅខាងណាយ ឬមកខាងអាយៈ ដើមស្វាយទោរ, មនុស្សចាស់ទោរទន់ ... ។

ឧទាហរណ៍ ទី ៥៩

ខ្ញុំនៅពីក្មេងរៀនធម្មវិន័យ ប្រឡងបានសញ្ញាប័ត្រជាន់ទោ, ឥឡូវខ្ញុំចាស់ទោរទន់ណាស់ហើយ បំណោះដែលបានរៀនទាំងប៉ុន្មាន ភ្លេចគាំងអស់ជាច្រើន ។

www.budinst.gov.kh www.elibraryofcambodia.org

"ទំ, ទុំ"

៦០– ទំ (កិ.) ឋិតលើទ្រនំ : ក្អែកទំលើមែកឈើ, កុកទំលើគុប; ឈឺចាប់មិនស្រាកស្រាន្តក៏ហៅថាទំដែរ : ជម្ងឺទំ, រោគទំ; ទាស់ទំ ... ។

៦០– ទំ (គុ.) ដែលជំនៅមិនស្រាក: ទុក្ខទំ គឺទុក្ខដែលមាននៅជាប់ជានិច្ច ។

៦០– ទុំ (គុ.) ទីទៃពីខ្ចីពីចាស់ គឺដែលដល់កំណត់ជិតជ្រុះពីមែកពីទង ស្លឹកឈើទុំ, ស្វាយទុំ; រោគដែលកើតយូរណាស់ហើយក៏ហៅថាទុំដែរ : ឫសដូងបាតទុំ, បូសទុំ, ភក់ទុំ ... ។

៦០– ទុំ (ប.) ពាក្យសម្រាប់និយាយផ្សំនឹងចាស់ : ចាស់ទុំ, អ្នកចាស់អ្នកទុំ ។

ឧទាហរណ៍ ទី ៦០

*សត្វសេកចេះតែមកទំលើដើមស្វាយនេះ ប្រហែលជាចង់ស៊ីស្វាយទុំហើយមើលទៅ ។*

"ធន, ធន់"

៦១– ធន (ន.) ទ្រព្យ, សម្បត្តិ : ទ្រព្យធន, កំសត់គតធន ។

៦១– ធន់ (កិ.) ទ្រាំ, អត់ធ្មត់, ស៊ូ : ធន់ជម្ងឺ, ធន់ក្ដៅ ... ។

ឧទាហរណ៍ ទី ៦១

*យើងជាអ្នកក្រីក្រខ្វះទ្រព្យធន កុំបណ្ដោយតាមចំណង់ ខំអត់ធន់បន្តិចទៅ ។*

www.budinst.gov.kh www.elibraryofcambodia.org

"នប់, នព"

៦២- នប់ (គុ.) កន្ទុប, គ្រមុល, រគុល : ស្លេងនប់, ក្របីនប់, គោនប់, នប់ទឹទុយ ... ។

៦២- នព្វ (ប.សំ.) ប្រាំបួន (៩) : មាសនព្វគុណ ។

ឧទាហរណ៍ ទី ៦២

ខ្ញុំមានក្របីនប់មួយពូកែណាស់, យកមាសនព្វគុណមួយនាបើយកដូរក៏ពុំបានបាន ។

"ន័យ, នៃ"

៦៣- ន័យ (ន.) ការណែនាំ, អធិប្បាយ, សេចក្ដីពន្យល់, ហេតុ, ទំនង, លំនាំ : សូន័យ, មានន័យ ... ។

៦៣- នៃ (អា.ន.) របស់ : សភាពនៃបណ្ឌិត គឺសភាពរបស់បណ្ឌិត ។

ឧទាហរណ៍ ទី ៦៣

កូននៃខ្ញុំកខ្វក់ណាស់ ខ្ញុំសព្វយ៉ាងយាយប្រដៅ ដោយន័យផ្សេងៗជាច្រើន តែកស្លាប់ពុំបាន ។

"នា, នារ"

៦៤- នា (អា.ន.) ឰដ៏, ត្រង់ : នាកាល, នាផ្លូវ ... ។

www.budinst.gov.kh www.elibraryofcambodia.org

៦៤— តារ (កិ.វិ.ប្អូគុ) ដែលមានអាការទេរ ដោយដំណើររត់ ឬ ដោយផ្ដាលស្រួលមិនបោត : រត់ខ្ទងតារ, រត់តារ, ដើរតារ ... ។

ឧទាហរណ៍ ទី ៦៤

ខ្ញុំបានឃើញប្រើសមួយរត់ខ្ទងតារ ចូលទៅក្នុងព្រៃមួយ នា ដើមកំពូលខែ ។

"តាប, តាជ"

៦៥— តាបិ (ន. ប្អូគុ.) អធិបតី, ម្ចាស់, ចៅហ្វាយនាយ, ដែល ជាទីពឹង : តាងតាជ ; (ច្រើនប្រើក្នុងកាព្យឃ្លោង) ។

៦៥— តាជិ (ន.) របាំ : ពួកតាងតាជកំពុងរាំ ។

ឧទាហរណ៍ ទី ៦៥

ព្រះគោតមតាប ពុំមានព្រះទ័យត្រេកអរ ចំពោះរបាំ ដែលនាង អាបសរទាំងឡាយរាំថ្វាយឡើយ ។

"តាល, តាលិ=តាឡិ"

៦៦— តាល (ន.) ឈ្មោះប្រទាលទឹកមួយយ៉ាងដុះលើត្របែ : ប្រទាលតាល ។

៦៦— តាលិ (ន.) ឈ្មោះទម្ងន់ម្យ៉ាងដែលចិន ដែលភាស, ទម្ងន់១៦ តម្លឹង : អង្គរមួយតាលិ ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៦៦

ប្រពាលនាលប្រែនុះលើត្រឹម ពីថ្ងៃមុនខ្ញុំដកបានមើមក់ប្រហែលមួយនាលិ ។

## " នុះ, នោះ "

៦៧ – នុះ (សព្វ.) ហ្នឹង, ពាក្យសម្រាប់និយាយចង្អុលនាមសព្វ ដែលនៅឃ្លាតពីខ្លួន តែមើលទៅឃើញ, ជាពាក្យមានសូរសំឡេងខ្ពស់ស្រួចជាងពាក្យថានោះ : អ្នកណានុះ?, នុះផ្ទះខ្ញុំ, នុះដីតាខ្ញុំ ... ។

៦៧ – នោះ (សព្វ.) ពាក្យសម្រាប់បង្ហាញ, សម្រាប់ចង្អុលអ្វីដែលនៅឆ្ងាយ តែប្រាកដ; ជាពាក្យមានសូរសំឡេងទាបបន្តិចជាងនុះ : ផ្ទះនោះ, អ្នកនោះ, វត្តនោះ, ភូមិនោះ ...។

ឧទាហរណ៍ ទី ៦៧

អ្នកណាដើរនុះ? ឯងត្រូវជាកម្មករគ្រូនៅវត្តខាងកើតនោះឬ?

## " នូវ, នៅ "

៦៨ – នូវ (ទិ.) នឹង, ហើយនឹង : ព្រះជេតនុត្តរៈ នូវអស់ឧបាសកឧបាសិកា ... ។

៦៨ – នូវ (អា.ទិ.) ពាក្យប្រាប់ដំណើរសម្រេចអំពើដែលគេត្រូវធ្វើ : ខ្ញុំធ្វើនូវបុណ្យ, បុណ្យឲ្យនូវផល ... ។

៦៨ – នៅ (កិ.វិ.) ដែលមិនទាន់ : ដែលមានទៀត : អស់ហើយឬនៅ? នៅ, នៅទេ, នៅទៀត ... ។

៦៨ – នៅ (កិ.) ឋិត, ស្ថិត : នៅឯណា? នៅក្នុងវត្ត ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៦៨

វត្តនៅភូមិខ្ញុំ មានព្រះថេរានុត្ថេរៈទូវអស់ឧបាសកឧបាសិកាជាច្រើន ខ្ញុំបានធ្វើទូកុដិមួយខ្នងនៅវត្តនោះ សម្រាប់លោកគង់នៅ ។

" បញ្ចង់, បញ្ចង្គ "

៦៩- បញ្ចង់ (គុ.) ដែលផ្ចង់, ដែលល្អប្រពៃ: ល្អបញ្ចង ។

៦៩- បញ្ចង្គ (គុ.) ដែលមានអង្គប្រាំ; (មើលថាបញ្ចង់) ច្រើនប្រើក្នុងពាក្យកាព្យឃ្លោង ។

ឧទាហរណ៍ ទី ៦៩

ខ្ញុំសូមថ្វាយបង្គំបញ្ចង្គ ចំពោះដល់អង្គព្រះសាស្តា ដែលជាគ្រូធំក្នុងលោក ទ្រង់មានបរិយាយល្អបញ្ចង់ ។

" បញ្ញត្ត, បញ្ញត្តិ "

៧០- បញ្ញត្ត (កិ.ឬគុ.) ដែលគេហាមប្រាមហើយ, តែងតាំងហើយ, តាំងទុកហើយ: ព្រះសម្ពុទ្ធទ្រង់បញ្ញត្តមិនឲ្យធ្វើ, រាជការបញ្ញត្តមិនឲ្យធ្វើ, មានព្រះរាជប្រកាសបញ្ញត្តហើយ ។

៧០- បញ្ញត្តិ (ន.) សេចក្តីហាមប្រាម បំរាម, សេចក្តីដែលគេតែងតាំង-រៀបចំ, ពាក្យដែលគេកំណត់ហៅ: មានបញ្ញត្តិ, ធ្វើខុសនឹងបញ្ញត្តិ: ច្រើនប្រើជាបទសមាស-រៀងខាងចុងសព្ទឯទៀត: ពុទ្ធប្បញ្ញត្តិ, រាជប្បញ្ញត្តិ, នាមប្បញ្ញត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៧០

ព្រះកថាទ្រង់បញ្ញត្ត មិនឲ្យប្រែជាជនបទផ្សេងពីភាសាដើម ។ សេចក្តីបញ្ញត្តិនេះប្រពៃណាស់ ។

" បជ , បត់ , បទ "

៧១ – បជ (ន.) ផ្លាំង, បន្ទះ, ដំបារ, ផ្ទៃ : ព្រះបដ (ផ្លាំងសំពត់ដែលគូររូបពុទ្ធប្បវត្តិ) ។

៧១ – បត់ (កិ.) ត្រឡប់តាមទំនង - តាមផ្លូវដែលមកវិញ , ត្រឡប់ប្រែសប់មុខ : បត់សំពត់, បត់ជើង ... ។

៧១ – បទ (ន.) ឧបាយ, ហេតុ , ទី , ការរក្សា , ចំណែក , ជើង, ផ្លូវ , ស្នាមជើង , ទំនង, ដំណើរទំនង, ក្បាម : លំនាំនៃសំឡេងដែលសូត្រឬដែលច្រៀង : សូត្រធម៌បទ, បែបបទ, អត្ថបទ, ខុសបទ ... ។

ឧទាហរណ៍ ទី ៧១

ព្រះបដនេះល្អណាស់, តាំងណាគូរក៏មានបែបបទល្អម្ល៉េះ ? ខ្ញុំក្រឡេកមើលពីផ្លូវបត់មក ឃើញគួរស្រស់បំព្រង ។

' បរ , បបរ "

៧២ – បរ (កិ.) បញ្ជូន , ដឹក , នាំ , បណ្តេញឲ្យទៅមុខដោយយានិះ, ដោយដើរកាល់ , ដើរអម , តម្រង់ឲ្យត្រង់តាមផ្លូវដែលត្រូវការ : បររទេះ បរដំរី ... ។

៧២ - បបរ (ន.) អាហារការធ្វើពីអង្ករស្ងោរជាដើម : បបរស្ករ បបរសណ្តែក ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៧២

បរវេទ:ឲ្យឆាប់ឡើង ខ្ញុំឃ្លានបបរណាស់ ។

## "បរិសុទ្ធ, បរិសុទ្ធិ"

៧៣– បរិសុទ្ធ (គុ.) ដែលស្អាតឥតសៅហ្មង, ឥតមោះមៃ : ចិត្តបរិសុទ្ធ, មនុស្សបរិសុទ្ធ ... ។

៧៣– បរិសុទ្ធិ (ន.) សេចក្តីស្អាត, ដំណើរឥតមោះមៃ : មនុស្សមានសេចក្តីបរិសុទ្ធិ ... ។

ឧទាហរណ៍ ទី ៧៣

មនុស្សដែលបរិសុទ្ធបាន ដោយមានសេចក្តីបរិសុទ្ធិជាប្រក្រតី ។

## "បរិបូណ៌, បរិបូរណ៍"

៧៤– បរិបូណ៌ (គុ.ម្ពុក.) ដូចគ្នានឹងបរិបូរណ៍ : ភោជនាហារបរិបូណ៌, ខ្ញុំពុំសូវបរិបូណ៌ទេ ..., ឈ្មោះខណ្ឌមួយក្នុងកម្ពុជរដ្ឋ រួមចូលក្នុងខេត្រកំពង់ឆ្នាំង ខណ្ឌបរិបូណ៌ (ជាតាម) ។

៧៤– បរិបូរណ៍ (ន.) ការគ្រប់គ្រាន់, ដំណើរពេញលេញ, សម្បូរណ៍: បរិបូរណ៍ដោយប្រាជ្ញា ជាហេតុឲ្យស្គាល់ការពិត ។

ឧទាហរណ៍ ទី ៧៤

ខ្ញុំបរិបូណ៌ហើយ មានចំណេះវិជ្ជា ទៅខ្វះតែសេចក្តីប្រតិបត្តិឲ្យ ចំរើនប្រាជ្ញា, ព្រោះបរិបូរណ៍ដោយប្រាជ្ញាជាហេតុឲ្យស្គាល់ការពិត ។

www.budinst.gov.kh www.elibraryofcambodia.org

"បា, បារ"

៧៥- បា (ប.) អ្នក, ពាក្យសម្រាប់ហៅកូនប្រុស ឬមនុស្សអ្នកមានអានុភាពតិចជាងខ្លួន ដែលទុកស្មើកូនប្រុសបង្កើត : ម្នាលបា, ហៃបា, នែបា, បាឯងទៅចុះ ... ។

៧៥- បា (ន.) ឪពុក, ពាក្យសម្រាប់ហៅមនុស្សប្រុស ឬសត្វឈ្មោលដែលជាគូនឹងមេ : មេបា, បាគោ, គោបា, បាក្របី, ក្របីបា ... ។

៧៥- បារ (ន.) បីសាចដែលចន្លាចកូនក្មេងឲ្យមមាលឃើញអ្វីៗដែលគួរភ្លាច : បារបន្លាច ។

៧៥- បារ (កិ.) កាយយកចេញ : បារអាចម៍ដី, បារស្រូវពីទូក, បារលាមកពីរបង្គន់ ... ។

ឧទាហរណ៍ទី ៧៥

ល្ងាចមិញបារបន្លាចកូនខ្ញុំឲ្យស្រែកទាល់ព្រឹក, ខ្ញុំស្លេកៗ បាឃើញក្របីបាមួយធំ ដេញជល់កាៗ ខ្ញុំបារអាចម៍ដីហាលក៏ពុំឈ្នះ បានទាក់ស្រែក ។

"បាត, បាត្រ, បាទ"

៧៦- បាត (ន.) ប៉ែកខាងក្រោមនៃដំរៅ : បាតបឹង, បាតស្ទឹង, បាតទន្លេ, បាតខ្ទះ; ផ្ទៃដៃឬជើង : បាតដៃ, បាតជើង ។ គូថ : ឫសគល់បាត, ឈើបាត ។

៧៦- បាត្រ (ន.) ភាជន : ធ្វើដោយដែកឬដោយដីសម្រាប់បព្វជិតប្រើប្រាស់ : បាត្រដី, បាត្រដែក, ស្នោកបាត្រ, ឃោគបាត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

៧៦ - បាទ (ន.) ជើង (ប្រើជាភាជសព្ទ) : ព្រះបាទ ; ឃ្លាសង្កាត់របស់គាថា, របស់កាព្យឃ្លោង : បាទទីមួយ, បាទទី ២ ... ; ឈ្មោះប្រាក់បុរាណដំឡៃ៦០-សេន : ប្រាក់បាទ ។

៧៦ - បាទ (ទិ.) អើ, ពាក្យសម្រាប់បុរសឆ្លើយ : ឆ្លើយបាទ, ខ្ញុំព្រះបាទ, ខ្ញុំបាទ... ។

ឧទាហរណ៍ ទី ៧៦

ខ្ញុំបាទកំពុងតែសរសេរពាក្យកាព្យ បានប្រហែលមួយបាទ ស្រាប់តែគួនខ្ញុំវាយកប្រាក់បុរាណមួយបាទ មកដាក់លើបាតដៃខ្ញុំបាទ ជាភស្តុតាងតបបាតសួន ។

"បាភយ, បាភយណ៍"

៧៧ - បាភយ (កិ.វិ. ប្តុ.) ដែលខូចទៅ, ដែលសាយសុះខូចទៅ: (ខ្មែរយើងច្រើនប្រើភ្ជាប់ជាមួយនឹងពាក្យអាស្រូវ) : អាស្រូវបាភយ គឺអាស្រូវកិត្តិឈ្មោះសុះសាយសព្វទៅ ។

៧៧ - បាភយណ៍ (ន.) ដំណើរខូចទៅ ; ប្រទេសដែលភលល្ហ-ល្ហេវធំធេង ; (ពាក្យខ្មែរប្រើជាឈ្មោះទីតំបន់, ខេត្ត, ស្រុកដែលភលល្ហល្ហេវ) : ភូមិបាភយណ៍, បឹងបាភយណ៍, ស្រុកបាភយណ៍ ។

ឧទាហរណ៍ ទី ៧៧

កាលខ្ញុំទៅលេងបឹងបាភយណ៍ កើតកង្វល់ ដោយបាតចិញ្ចៀនមាសមួយ ខ្ញុំខ្មាសគេណាស់, ព្រោះនាំឲ្យអាស្រូវបាភយកិត្តិឈ្មោះកណ្ដាលស្រុកគេ ។

www.budinst.gov.kh www.elibraryofcambodia.org

## "បិត, បិទ"

៧៨ - បិត (កិ.) កាន់ទប់ដោយដៃទាំងពីរ កួត, ប្រួម, សម្រួច ដោយមុខកាប់បិតបន្ទោះឬកាំបិតឯទៀតក៏បាន : បិតផ្ដៅ, បិតឫស្សី, បិតសម្រួច; បំហុយយកញើសឲ្យស្រក់ចុះក្នុងតម្រង : បិតស្រា... ។

៧៨ - បិទ (កិ.) ដាក់ភ្ជិតភ្ជាប់, ទប : បិទមាស, បិទទ្វារ, បិទបង្អួច .. ។

ឧទាហរណ៍ ទី ៧៨

*គាបាសម្នាក់អង្គុយបិតផ្ដៅក្រោមផ្ទះ, ឯគកកូលស៊ីត្រីអាំងលើផ្ទះអស់, ព្រោះគាត់ពុំបានបិទទ្វារ ។*

## "បុស្ស, បុះ"

៧៩ - បុស្ស (ន.) ឈ្មោះខែទី ២ ខាងចន្ទគតិ : ខែបុស្ស ។

៧៩ - បុះ (កិ.) បុកទល់មុតដល់មានរបួស : ជង្គត់បុះបាតជើង; បុកដោយអ្វី ៗ ដែលស្រួច : បុះរណ្ដៅដាំពោត, បុះមួយកាំបិត; រុកឲ្យជ្រុះ, ឲ្យធ្លាក់ : យកប៉ោលបុះផ្លែឈើ; ពាក្យទ្រគោះមើលងាយថាស៊ីដូចបុះអ្វី ៗ : បុះបុះ , បុះបុះដល់ណាទៀត ។

ឧទាហរណ៍ ទី ៧៩

*កាលពីខែបុស្ស ឥន្ទ្រគុះជើងជាប់ទៅហើយ ឥឡូវរពចង់បុះ ហាច់មាន់ទៀត ចង់ឲ្យវដើរបាទៀតឬ? ។*

www.budinst.gov.kh www.elibraryofcambodia.org

## “បូ, បូរ, បូពិ”

៨០ – បូ (ន.) សំពត់ពណ៌ចងកាច់ជាស្រទាប់ សណ្ឋានស្រដៀងនឹងផ្ការីក ប្រើចងផ្នួងឬកម្រងសក់ ជាគ្រឿងលំអរតាមសម័យ: ចងបូ, សក់ចងបូ... ។

៨០ – បូរ (កិ. ឬ កិ. វិ.) ប្រើភ្ជាប់នឹងពាក្យបាច់, បូរ-បាច់ គឺនិយាយរៀបរាប់ប្រាប់ឲ្យឃើញដើមទងគន្លងតាមរបៀបហូរហែ : និយាយបូរបាច់ប្រាប់ ។

៨០ – បូពិ (គុ.) ខាងដើម; ខាងមុខ: ខាងកើត : ទិសបូពិ ឬថាបូព៌ាក៏បាន ។

ឧទាហរណ៍ ទី ៨០

ព្រឹកមិញ ឃើញនារីម្នាក់សក់ចងបូ ដើរមកពីទិសបូពិ សំដៅមក ផ្ទះខ្ញុំ, មកនិយាយបូរបាច់ពីការរៀនសូត្រប្រាប់ជូនខ្ញុំ ។

## “បួ, បួរ”

៨១ – បួ (ឧ.) ពាក្យសម្រាប់និយាយផ្សំនឹងពាក្យបឹង : បឹងបួ ។

៨១ – បួរ (ន.) សរីរាវយវៈរបស់សត្វពួកខ្លះមានគោជាដើម នៅក្រោមក មានសណ្ឋានយារចុះស្រដៀងនឹងផ្លិតឃ្មុំ : បួរគោ, បួរទន្សោង, បួរពពែ; ឈ្មោះក្បាច់ម្យ៉ាងមានសណ្ឋានស្រដៀងនឹងបួរគោ ដាក់សំយុងជាលំអដោយឡែក: ក្បាច់បួរ, ដាក់បួរសើមជុំវិញ ។

ឧទាហរណ៍ ទី ៨១

កាលពីឆ្នាំមុន នៅរដូវប្រាំងទឹកគោកដីមិនជួររីងស្ងួតអស់; ខ្ញុំបានដើរទៅអង្គុយលេងក្រោមដើមត្រស់ដែលដុះកណ្ដាលបឹង បានឃើញឃ្មុំមួយផែនវែងមានសណ្ឋានដូចបួរគោ ។

www.budinst.gov.kh www.elibraryofcambodia.org

## "បក្ខ = បក្ស, ប៉ាក់"

៨២– បក្ខ (ន.) ចំណែក, ប៉ែក, ចំណែកខែ: ចំអេងស្លាប, ពួក: បក្ខទី១, បក្ខទី២, បក្ខពួក... ។

៨២– ប៉ាក់ (កិ.) ដុលភ្ជាប់រំលេចជាក្បាច់រចនា ឬជារូបអ្វីៗ នៅស្ពាន់ សំពត់ ដោយឱនជាដើម : ប៉ាក់មុងគុ... ។

ឧទាហរណ៍ ទី ៨២

*កាលពីបក្ខទី ២ នៃខែមុន មានបក្ខពួកនារីជាច្រើន នាំគ្នាទៅប៉ាក់ ស្រោមគម្ពីរ ឯវត្តខាងជើង ។*

## "ប្រញប្ត, ប្រញប្តិ, ប្រញាប់"

៨៣– ប្រញប្ត (កិ.) គឺបញ្ញត្ត : ព្រះសម្ពុទ្ធទ្រង់ប្រញប្តសិក្ខាបទ ចំពោះសាវក; (មើលថាប្រញាប់) ។

៨៣– ប្រញប្តិ (ន.) គឺបញ្ញត្តិ : ពុទ្ធប្រញប្តិ, រាជប្រញប្តិ, ប្រព្រឹត្ត ខុសនឹងសេចក្តីប្រញប្តិ; (មើលថាប្រញាប់) ។

៨៣– ប្រញាប់ (កិ. ឬ កិ. វិ. ឬ គុ.) បន្ទំឲ្យប្រញាប់, ធ្វើឲ្យ ប្រញាប់, ឲ្យឆាប់, ឆាប់ : ប្រញាប់ឲ្យទាន់ការ, ការប្រញាប់, កុំប្រញាប់ពេក... ។

ឧទាហរណ៍ ទី ៨៣

*ព្រះសម្ពុទ្ធទ្រង់ប្រញប្តសិក្ខាបទចំពោះសាវក ពុំដូចកាលប្រញប្តិទេ. យើងកល់គ្នាត្រូវប្រញាប់កសាងកុសល ទាន់មានព្រះពុទ្ធសាសនា ។*

www.budinst.gov.kh www.elibraryofcambodia.org

# "ប្រដិស, ប្រតិស្ឋ"

៨៤- ប្រដិស (ន.) រនាបដែលត្បាញខ្វាស់នឹងចម្រឹងញឹក: ប្រដិសឫស្សី, ដញ្ជាំងប្រដិស... ។

៨៤- ប្រតិស្ឋ (កិ.) តាំង, តាំងនៅ, ដម្កល់, សាង, កសាង: ប្រតិស្ឋជាតិ, ប្រតិស្ឋសាសនា; (មើលថាប្រដិស) ។

ឧទាហរណ៍ ទី ៨៤

ខ្ញុំធ្វើការនេះ, បើគ្មានអ្នកធ្វើនាំគ្នាត្បាញប្រដិសលក់ ដើម្បីយកប្រាក់ប្រតិស្ឋជាតិ ប្រតិស្ឋសាសនា ឲ្យមានរុងរឿងតទៅ ។

# "ប្រព្រឹត្ត, ប្រព្រឹត្តិ"

៨៥- ប្រព្រឹត្ត (កិ.) ធ្វើ, ធ្វើតាម, ប្រតិបត្តិតាម, កាន់វត្តប្រតិបត្តិ: កុំប្រព្រឹត្តទុច្ចរិត... ។

៨៥- ប្រព្រឹត្ត (គុ.) ដែលធ្វើ, ដែលធ្វើតាម, ដែលកាន់វត្តប្រតិបត្តិ: ឈ្មោះនេះជាអ្នកប្រព្រឹត្តត្រឹមត្រូវ... ។

៨៥- ប្រព្រឹត្តិ (ន.) ការធ្វើតាម, ការកាន់វត្តប្រតិបត្តិ, ដំណើរ, ហេតុ, ដើមហេតុ, រឿងរ៉ាវ, ពង្សាវតារ: ការប្រព្រឹត្តិ, សចក្ដីប្រព្រឹត្ត.... ។

ឧទាហរណ៍ ទី ៨៥

អ្នកទាំងឡាយចូរប្រព្រឹត្តតាមខ្ញុំ, ព្រោះការប្រព្រឹត្តិរបស់ខ្ញុំសមតាមផ្លូវលោកទាំងផ្លូវធម៌ ជាគតិល្អដែលខ្មែរយូរណាស់បានប្រព្រឹត្តមកហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

# "ប្រមាថ ប្រមាទ"

៨៦— ប្រមាថ (ន.) ការបៀតបៀនគេ, ការញាំញីគេ, ការធ្វើគេឲ្យលំបាក : ការប្រមាថគួរកុំឲ្យមាន ។

៨៦— ប្រមាថ (កិ.) បៀតបៀនគេ, ញាំញីគេ : មនុស្សនេះប្រមាថខ្ញុំ, អ្នកនេះប្រមាថសត្វ... ។ (តាមទម្លាប់ថាមើលងាយក៏បាន)

៨៦— ប្រមាទ (ន.) ការភ្លេចស្មារតី, សេចក្ដីប្រហែសធ្វេស : ការប្រមាទឈ្មោះថាស្លាប់ទាំងរស់ ។

៨៦— ប្រមាទ (កិ.) ភ្លេចស្មារតី, ធ្វេស, ប្រហែសធ្វេស : កុំប្រមាទក្នុងសង្សារ, ចូរញាំងសេចក្ដីមិនប្រមាទឲ្យដល់ព្រម ។

ឧទាហរណ៍ ទី ៨៦

*ព្រះសម្ពុទ្ធសំដែងថា: កុំប្រមាទក្នុងការកុសល, ឲ្យប្រមាទក្នុងអកុសលទាំងឡាយ មានការប្រមាថសត្វតូចធំជាដើម ។*

# "ប្រវញ្ច ប្រវញ្ចន៍"

៨៧— ប្រវញ្ច (កិ.) បញ្ឆោត, បោកប្រាស់ : ប្រវញ្ចទ្រព្យគេ, ប្រវញ្ចគេភ្លាងឯង.... ។

៨៧— ប្រវញ្ចន៍ (ន.) អំពើបញ្ឆោត, ដំណើរបោកប្រាស់ : អំពើប្រវញ្ចន៍នាំឲ្យគេស្អប់... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៨៧

កុំប្រវ័ញ្ចទ្រព្យគេ ប្រយ័ត្នមានទោសធ្ងន់ ព្រោះការប្រវ័ញ្ចន៍ ជាអំពើលាមក កប់បញ្ចូលក្នុងទុច្ចរិត ។

"ប្រសប់, ប្រសព្វ"

៨៨- ប្រសប់ (គុ.) ប្ញិក, ប៉ិន, ប៉ិនខាងស្ទង់លៃ, ត្រូវ : មនុស្សប្រសប់, ប្រសប់ធ្វើការ...។

៨៨- ប្រសព្វ (គុ. ឬ កិ. វិ,) ដែលមានមុខប្រទល់រួមចូលគ្នា: ទន្លេប្រសព្វមុខ, ទឹកហូរប្រសព្វគ្នា ។

ឧទាហរណ៍ ទី ៨៨

លោកគ្រូព្រះមហាថាច់ដំណាលថា មានបុរសម្នាក់នៅភូមិព្រែកប្រសព្វ ប្រសប់ហែលទឹកណាស់ ទោះបីទឹកហូរប្រសព្វមុខគ្នាយ៉ាងណា ក៏ហែលបាន ។

"ប្រាង្គ, ប្រាង្គណ៍"

៨៩- ប្រាង្គ (ន.) ស្តូបឬប្រាសាទដែលមានកំពូលខ្ពស់ស្កិតនៅលើទីលានមានថ្នាក់, ច្រើនតែមានរាងច្រឡោះាំងពីក្រោមដល់កំពូល : ប្រាង្គបាយ័ន..., ។

៨៩- ប្រាង្គណ៍ (ន.) ទីលាន, ទីវាលផាត់, ទីផ្ទៃវាលយ៉ាងដូចទីវាលមុខផ្ទះ មុខប្រាសាទជាដើម : ប្រាង្គណ៍មុខប្រាសាទនគរវត្តក្រាលសុទ្ធតែថ្ម ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ៨៩

ប្រាជ្ញណ៍ព័ទ្ធជុំវិញប្រាជ្ញប្រាយ័ន គុំសួរធំប៉ុនាទទេ ។

"ប្រឹស, ប្រឹស្ឋ, ប្រឹះ"

៩០– ប្រឹស (ន.) មុខទ្រូ ឬលប មានបន្ទោះរួមក្រុំបួចខាងចុង ទុកផ្លូវប្រែហា ល្មមឲ្យត្រីចូលបាន កុំឲ្យចេញមកវិញរួច : ប្រឹសទ្រូ, ប្រឹសលប.... ។

៩០– ប្រឹស្ឋ (ន.) ខ្នង (រាជសព្ទ) : ព្រះប្រឹស្ឋ ។

៩០– ប្រឹះ (គុ.) សូរឮដោយភ្លៀងតិចៗ ឬរលឹមធ្លាក់មកលើដំបូល ប្រក់ស្លឹក ឬស្បូវជាដើម ច្រើនថាជួនគ្នា : ប្រឹះៗ, ភ្លៀងប្រឹះៗ, រលឹមប្រឹះៗ ... ។

ឧទាហរណ៍ ទី ៩០

*ម្សិលមិញ ខ្ញុំធ្មឹប្រឹសលបហើយ ទៅមើលព្រះរាជពិធីរាជាភិសេក, ចួនជាពេលនោះមានភ្លៀងប្រឹះៗ, គេដង្ហែព្រះរាជាចូលទៅកន្លែងព្រះរាជដំណាក់វិញ, ខ្ញុំបានឃើញតែព្រះប្រឹស្ឋព្រះរាជាបន្តិច ។*

"ប្រុស, ប្រុះ"

៩១– ប្រុស (ន.) អ្នកបំពេញចិត្តមាតាបិតា, អ្នកបំពេញចក្ខុស្ត្រី, អ្នកបំពេញកិច្ចការក្នុងប្រទេសដែលខ្លួននៅ, កូនប្រុស, មនុស្សប្រុស, ពិតជាប្រុស... ។

៩២– ប្រុះ (គុ. ឬ កិ. វិ.) ព្រោងព្រាយ, ដែលភ្ជិចំរុះគ្នា : ពន្លឺប្រុះ ភ្លឺប្រុះ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី៩១

ខ្ញុំនិតក្អែកឈូរណាស់ហើយ ពោះថីតន្ទីក្តីប្រះយ៉ាង.យាក៏មើល ពុំឃើញ ការអ៊ឹង បានតែក្មួនប្រុសខ្ញុំទេ ត្រាទជាក្អែកជាប្រមុះ ។

"ផ្លា, ផ្លារ"

៩២– ផ្លា (ន.) ដីជាតទន្លេ-ស្ទឹង-បឹង កាលបើទឹកស្រកទៅ ជាប់គោកមុនគេ, សណ្ឋានទាបៗ មិនខ្ពស់ដូចកោះទេ: ដីកអណ្ដូងលើផ្លា, ផ្លាមុខផ្ទះជាប់គោកណាស់... ។

៩២– ផ្លារ (កិ.) ធ្វើឱ្យមានបន្ទារ, អារផ្លារគឺអារឈើឱ្យបានជាបន្ទារ។

ឧទាហរណ៍ ទី៩២

ពីខែមុនគេយកឈើហុបធំៗ អារផ្លារឱ្យជាបន្ទារតូចធំលើផ្លាមុខផ្ទះខ្ញុំ ។

"ផ្ដែ, ផ្ដែរ"

៩៣– ផ្ដែ (ប.) ពាក្យសម្រាប់និយាយផ្សំនឹងពាក្យផ្ដាច ឬផ្ដាំ: ផ្ដាច់ផ្ដែកូនចៅ, ផ្ដែផ្ដាំ ឬផ្ដាំផ្ដែ... ។

៩៣– ផ្ដែរ (ន.) ក្ដាររនាំងបាំងភាំង បន្ទោះដំបូលដែលមានជាន់ពីរ: ផ្ដែរវិហារ, ផ្ដែរសាលា ។

ឧទាហរណ៍ ទី៩៣

លោកគ្រូគង្គគុនធ្វើវិហារ ស្រាប់តែមានអាពាធជាមួយខ្ញុំ ស្មានមើលទៅពុំជា ក៏ហៅសិស្សឥណាមកផ្ដែផ្ដាំ ឱ្យនាំគ្នាខំធ្វើផ្ដែរវិហារឱ្យបានហើយផង ។

www.budinst.gov.kh www.elibraryofcambodia.org

## “ផ្កា, ផ្សារ”

៩៤– ផ្កា (កិ. ថ្ក ន.) ឈើចាប់ពើតភោលភោលផៀបៗ ដោយមុខ សាស្ត្រ, របួស, ដាច់, រលាត់ ប៉ះពាល់ត្រូវ ប្រទះនឹងជាតិជូរ - ប្រៃ - ហឹល : ឈើផ្សា, ខ្លោចផ្សា... ។

៩៤– ផ្សារ (ន.) ទីប្រជុំលក់ទិញរបស់ផ្សេងៗ គឺប្រជុំផ្ទះឬរានតូចធំដែលគេដាក់ទំនិញលក់ដូរ : ទៅផ្សារ, ផ្សារផ្សេ...; ភ្ជាប់ភ្ជិតដោយទឹករងផ្សារ : ផ្សារឆ្នាំង, ផ្សារទទឹក... ។

ឧទាហរណ៍ ទី៩៤

*ខ្ញុំជិះឡានទៅផ្សារ, ឡានក្រឡាប់ក្បាលខ្ញុំបែកធ្លាយ, ពេទ្យយកថ្នាំមកលាបទៀត ឈឺផ្សាស្ទើរទ្រាំពុំបាន ។*

## “ព, ពរ”

៩៥– ព (កិ.) លើកដាក់លើចង្កេះកៀកនឹងដៃឈរឬដើរ : ពកូន, ពពោ; ពាក្យប្រៀប ពផែនដី គឺគ្រប់គ្រងរក្សាអាណាចក្រនិមួយៗ ។

៩៥– ពរ (ន.) គុណជាតដ៏ប្រសើរ, គុណជាតអ្វីៗ ដែលគួរប្រាថ្នាចង់បាន : សូមពរ, ទទួលពរ, ឲ្យពរ ... ។

៩៥– ពរ (កិ.) លាបប្អូតព្រលាំង ដោយជ័រឲ្យក្រាស់ជិតសាច កុំឲ្យជ្រាបទឹកបាន : បិទពរ, ពរទូក ... ។

ឧទាហរណ៍ ទី ៩៥

*អ្នកឯងពរទូកឲ្យខ្ញុំ ចាំខ្ញុំឲ្យគេឲ្យបានសេចក្ដីសុខ ព្រោះខ្ញុំរវល់ពកូនៗ*

www.budinst.gov.kh www.elibraryofcambodia.org

## "ពណ៌=ព័ណ៌, ព័រ"

៩៦- **ពណ៌** (ន.) សម្បុរ ពណ៌លឿង, ពណ៌ស, ពណ៌ក្រហម... ។

៩៦- **ព័រ** (ន.) មនុស្សបុរាណស្រុកពួកមួយ កើតនៅក្នុងអាណាខេត្តកម្ពុជរដ្ឋ មានភាសាសំដីផ្សេងពីខ្មែរ រាប់បញ្ចូលក្នុងពួកកួយ-រដែ-ស្ទៀង : ជាតិព័រ ។

ឧទាហរណ៍ ទី៩៦

*ជាតិព័រប្រើនពណ៌ខ្មៅជាងខ្មែរ ដូចពួកកួយរដែស្ទៀងទាំងអស់*

## "ពង់, ពង្ស"

៩៧- **ពង់** (កិ.) ប៉ោកោង, បំអិត : ក្បោកពង់, ពង់ឆ្ងូច, ពង់ខ្នង, ពងខ្ទុះ... ។

៩៧- **ពង្ស** (ន.) ពូជ, ត្រកូល. វង្ស : ពង្សបរិត្ត, ពង្សមនុស្ស. ពង្សទេវតា... ។

ឧទាហរណ៍ ទី៩៧

*ពូជពង្សខ្ញុំ សក់ប្រើនដូចក្បោកពង់ សក់នោះបើទុកឲ្យវែង*
*ដើមពីងពង់កំបាន ។*

## "ព័ចន៍=ពេចន៍, ពេជ្រ"

៩៨- **ព័ចន៍** (ន.) ពាក្យ, សំដី (សម្រាប់ប្រើក្នុងកាព្យឃ្លោង) ។

www.budinst.gov.kh www.elibraryofcambodia.org

៩៨- ពេបន៍ (ន.) ពាក្យ, សំដី; ខ្មែរប្រើជាបរិភាសព្ទ សម្រាប់និយាយផ្សំនឹងពាក្យ : ពាក្យពេបន៍... ។

៩៨- ពេជ្រ (ន.) ឈ្មោះត្បូងវិសេស មានសាច់រឹងខ្លាំង មានពន្លឺផ្ទះព្រាត ១ : ត្បូងពេជ្រ, ពេជ្រគ្រាប់... ។

ឧទាហរណ៍ ទី ៩៨

អ្នកបេះពាក្យពេបន៍ ថ្លៃថ្លាជាអ្នកមានមាសមានពេជ្រ ។

"ព័ត, ព័ទ្ធ"

៩៩- ព័ត (កិ.) បក់ (ភាជសព្ទ) ព័តថ្វាយ គឺបក់ថ្វាយ (បក់នឹងផ្លិតឬស៊ែ)។

៩៩- ព័ទ្ធ (កិ.) ចង, ចងវ័ណ្ឌជុំវិញ, រុំជុំវិញ, ហោមជុំវិញ, ហោមស្លាក់ជុំវិញ : វល្លិព័ទ្ធឈើ, ធ្វើរបងព័ទ្ធផ្ទះ; ព័ទ្ធហោរ··· ។

ឧទាហរណ៍ ទី ៩៩

ខ្ញុំកំពុងតែព័តថ្វាយព្រះរាជា ស្រាប់តែពួកមហាជនមកគាល់ព្រះរាជា អង្គុយព័ទ្ធជុំវិញខ្ញុំ ។

"ពន់, ពន្ធ"

១០០- ពន់ (គុ.) ហួស, ក្រៃ, លើសលន់; ពាក្យសម្រាប់និយាយផ្សំនឹងប្រមាណ - ពេក : ពន់ប្រមាណ, ពន់ពេក, ពេកពន់ ។

១០០- ពន្ធ (ន.) សួយ, អាករដែលប្រជាជនត្រូវបង់តាមកំណត់ ពន្ធស្រូវ, ពន្ធទូក, ពន្ធត្រី...; (បុះប្របួបផ្សំពីខាងដើមមកជា ប្រពន្ធ, បពន្ធ, ប្រពន្ធប្តី)។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១០០

ឆ្នាំនេះតារាពន្ធស្រូវ ហួសប្រមាណពន់ពេក ប៉េទារយោជ័ហ៊ួ បានប្រាក់ឯណាបំពាមប្រពន្ធកូន ។

"ពន្ធ. ពាន់"

១០១- ពន្ធ (កិ.) ចង, ជាប់, ជំពាក់, ទាក់ទាក់ព័ន្ធលើគ្នា ព័ន្ធជើង, ព័ន្ធសេចក្តី, ព័ន្ធសំដី...; (បុះប្រែឬបង្កើតខាងដើមមកជា ប្រព័ន្ធ, បព័ន្ធ បងកឹរត្បូត, បងក្រង, បងក្រងជាកាព្យឃ្លោង) ។

១០១- ពាន់ (ប.សំ.) ចំនួន១០០ដប់ដង (១០០ × ១០=១០០០)។

ឧទាហរណ៍ ទី ១០១

ខ្ញុំសព្វថ្ងៃពន្ធសំដីថាទីដួយមនប្រាក់បន់ពាន់រៀល ។

"ពស់, ពស្រ្ត, ពោះ"

១០២- ពស់ (ន.) សត្វពួកទីឃជាតិ អាសិរពិសផ្សេងៗ : ពស់វែក រនាម, ពស់វែកដំបូក, ពស់វែកស្រវែង, ពស់ក្រាយ, ពស់ពញាក់... ។

១០២- ពស្រ្ត (ន.) សំពត់, គ្រឿងស្លៀកដណ្តប់ (ជាភាជសព្ទ): ព្រះពស្រ្ត គឺសំពត់សម្រាប់ក្សត្រិយ៍ទ្រង់ ។

១០២- ពោះ (ន) ប៉ែកភាងកាយដែលមានក្រពះពោះវៀននៅខាង ក្នុង : ឈឺពោះ ហើមពោះ...; ប៉ែកផ្នែខាងក្នុង ឬពីខាងក្រោមទល់គ្នានឹងខ្នង, បណ្តាល ពោះឫស្សី, ពោះផាងត្នោត, ពោះត្រឡាច... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ទី ១០២

ព្រះពស្រ្ដរបស់ព្រះករុណាជាម្ចាស់ព្រះអង្គ មានពណ៌ផ្សេងៗពណ៌ពោះ
ពស់ពព្ញក់ ។

"ពាណិជ, ពាណិជ្ជ = ពាណិជ្យ"

១០៣- ពាណិជ (ន.) អ្នកលក់ដូរ, អ្នកជំនួញ, ឈ្មួញ : ពួក
ពាណិជ...។

១០៣- ពាណិជ្ជ (ន.) ការលក់ដូរ, ជំនួញ : ធ្វើពាណិជ្ជ, របរធ្វើ
ពាណិជ្ជ... ។

ឧទាហរណ៍ ទី ១០៣

មានពាណិជម្នាក់ បញ្ជូនកូនឲ្យទៅរៀនធ្វើពាណិជ្ជនៅប្រទេស
ចិន ។

"ពាត, ពាទ្យ"

១០៤- ពាត (កិ. ឬ កិ.វិ.) ដាក់ពាសខ្វែងពីលើ : បងពាត,
ដាក់ពាត; ភាយពាត ... ។

១០៤- ពាទ្យ (ន.) គ្រឿងភ្លេងប្រគំ, គ្រឿងតន្ត្រីដេញដំផ្លុំកូត ឬ
តន្ត្រីទូទៅគ្រប់យ៉ាង; ខ្មែរប្រើជាបរិវារសព្ទផ្សំនឹងពាក្យពិណ : ពិណពាទ្យ គឺគ្រឿងភ្លេង
ដេញដំផ្លុំកូតមានធាប៉ុនជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១០៤

កាលខ្ញុំទៅមើលល្ខោនព្រះរាជទ្រព្យ មុនដំបូងឮតែសូរចំរៀងនិង ពិណពាទ្យ មួយស្របក់ស្រាប់តែឃើញអ្នកស្លៀកពាក់គ្រឿងប៉ាក់ចង ពាក ចេញមកមុនគេ ។

"ពិណ, ពិន"

១០៥- ពិណ (ន.) ចាប៉ី : ពិណមាស ; ដេញពិណ... ។

១០៥- ពិន (ន.) ស្មៀតសក់ជុក : ក្មេងទុកជុកសៀតពិន ; កំពូល, អ្នកដែលជាកំពូល, ដើម, ចំបងលើគេ : ពិនពិភព (ស្តេចក្រព័ត្តិ ឬរាជាធិរាជ សម្រាប់ប្រើក្នុងពាក្យកាព្យឃ្លោង) ។

ឧទាហរណ៍ ទី ១០៥

មានក្មេងប្រុសម្នាក់ទុកជុកសៀតពិន ចេះដេញពិណយ៉ាង ចំណាន ។

"ពិសោត = ពិសោធ, ពិសោធន៍"

១០៦- ពិសោធ (កិ.) ខ្មែរប្រើចំពោះសេចក្តីជាល្បងមើល, សាក មើល : ចាំពិសោធមើលសិន...។

១០៦- ពិសោធន៍ (ន.) ការល្បងមើល, ដំណើរសាកមើល : ជាប់ ពិសោធន៍, នៅក្នុងពិសោធន៍... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១០៦

*ការនេះនៅកន្លែងពិសោធន៍នៅឡើយ ចាំពិសោធឲ្យឃើញពិត ទើបនិយាយបាន ។*

"ពិសុទ្ធ, ពិសុទ្ធិ, ពិស្សុត"

១០៧— ពិសុទ្ធ (គុ.) ស្អាតវិសេស, ហ្មត់ហ្មង, ឥតមន្ទិល (មកពីវិសុទ្ធ) ច្រើននិយាយផ្សំនឹងពាក្យពិសេស : ពិសេសពិសុទ្ធ... ។

១០៧— ពិសុទ្ធិ (ន.) សេចក្តីស្អាតវិសេស, ហ្មត់ហ្មង, ឥតមន្ទិល: ការពិសេសពិសុទ្ធិ... ។

១០៧— ពិស្សុត (គុ.) ដែលលេចឮកេរ្តិ៍ឈ្មោះសុះសាយ, ល្បីល្បាញ, ដែលមានគេស្គាល់រាប់អានច្រើន : មនុស្សពិស្សុត, មានកេរ្តិ៍ឈ្មោះពិស្សុត... ។

ឧទាហរណ៍ទី ១០៧

*អ្នកមានកេរ្តិ៍ឈ្មោះពិស្សុត មកពីមានសេចក្តីប្រតិបត្តិពិសេសពិសុទ្ធ ចំពោះការពិសេសពិសុទ្ធិ ។*

"ពី, ពីរ"

១០៨— ពី (ធ.ឬ អា.ន.) អំពី, ខាង, ឯ : មកពីណា ? មកពីផ្ទះ, ទៅពីព្រឹក, រួចពីដៃ, ពីមុខ, ពីក្រោយ, ពីលើ, ពីក្រោម ......។

១០៨— ពីរ (ប.សំ.) ចំនួនមួយគួបគ្នា គឺមួយនឹងមួយត្រូវជា (២) : បានពីរ, ឆ្នាំងពីរ, មនុស្សពីរនាក់......។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១០៨

ពីព្រឹកមិញ សិស្សសាលាបាលីជាន់ខ្ពស់ ពីរអង្គចេញពីកុំពេញ ទៅប្រែទេសនាណ្ឌ ។

"ពុត, ពុទ្ធ, ពុធ"

១០៩— ពុត (ន.) ដំណើរបាំងទោសខ្លួន, ដំណើររបិញរបុញ, កិច្ចកលមាយា, ការក្លែងក្លែងដំណើរឲ្យឃ្លាតចាកសេចក្ដីពិត : មានពុត, ពុតអាក្រក់.... ។

១០៩— ពុត (កិ.) ពុតធ្វើជាឈើ, ភិពុតជាថ្នង.... ។

១០៩— ពុទ្ធ (ន.) លោកអ្នកត្រាស់ដឹងធម៌ដែលកំបាំង លោកអ្នកភ្ញាក់រឭក..... : ព្រះពុទ្ធ, ព្រះពុទ្ធជាម្ចាស់..... ។

១០៩— ពុធ (ន.) អ្នកក្រាជ្ញ, អ្នកមានប្រាជ្ញា ; ឈ្មោះថ្ងៃទី ៤ ក្នុងសប្ដាហ៍ : ថ្ងៃពុធ (ហៅតាមឈ្មោះផ្កាយពុធ) ។

ឧទាហរណ៍ ទី ១០៩

ព្រះពុទ្ធជាបរមគ្រូ ព្រះអង្គដេញពុតអវិជ្ជាបាន ដោយ ៗ ពោធិញាណ គង់ថៃពុធពេញបូណ៌មីខែវិសាខឆ្នាំរក ។

"ពុរ, ពុល"

១១០— ពុរ (គុ.) ដែលៈជាវផ្ងាយសាច់ដោយទង្គិច - ប៉ះ - ច្របាច់ : ពុរសាច់, ផ្លែឈើពុរ, ពុរពង..... ។

១១០— ពុល (គុ.) ដែលមានពិស អាចបណ្ដាលឲ្យរង៉ាច់រង៉ើ, ឲ្យក្អួតបង្អោរឬធ្វើទុក្ខខ្លាំងដល់ឈឺស្លាប់ក៏មាន : ផ្សិតពុល, ថ្នាំពុល ; ពុលចាយ, ពុលផ្សិត..... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ទី ១១០

ល្ងាចមិញខ្ញុំពុលផ្សិតក្អួតចង្អោរយ៉ាងខ្លាំង, បងខ្ញុំគាត់ចាប់កោស ឲ្យពុំហាប់អស់ ។

"ពុម្ព, ពុំ"

១១១– ពុម្ព (ន.) គ្រោងអក្សរឬក្បាច់ផ្សេងៗ ដែលគេធ្វើជាគំរូ, ទើបយកក្រដាសឬអ្វីៗទៅផ្ដិតយកពីគំរូនោះមក : ពុម្ពអក្សរ, ពុម្ពក្បាច់, រោងពុម្ព...... ។

១១១ – ពុំ (និ.) មិន, ឥត : ទៅពុំបាន, ធ្វើពុំកើត....... ។

ឧទាហរណ៍ទី ១១១

អក្សរពុម្ព ខ្ញុំមើលពុំសូវស្គាល់ទេ ព្រោះពុំធ្លាប់រៀន ។

"ពូជ, ពួច"

១១២– ពូជ (ន.) រុក្ខជាតិឬធញ្ញជាតិជាដើម ដែលមានកំណើតអាចដុះចេញពន្លក លូតលាស់ទៅទៀត : ពូជឈើ, ពូជស្រូវ; ស្រូវពូជ, សណ្ដែកពូជ; ពូជខ្មែរ, ពូជចិន, ពូជយួន.....។

១១២– ពួច (ន.) ឈ្មោះឈើតូចពួកមួយស្លឹកស្រួចៗ ផ្លែទុំមានរសផ្អែមលាយចត់ បរិភោគបាន, ខ្លះផ្លែធំខ្លះផ្លែតូច : ផ្លែពួច, ពួចធំ, ពួចតូច ។

ឧទាហរណ៍ទី ១១២

នៅព្រៃជើងភ្នំគូលែនសម្បូណ៌ដើមពួចណាស់ ពីខែមុនខ្ញុំបានគាស់មួយកញ្ចប់យកមកធ្វើពូជ ។

www.budinst.gov.kh www.elibraryofcambodia.org

## " តៃ, ពៃរ៍ "

១១៣— តៃ ( ន. ) ឈ្មោះល្អីតូចមួយយ៉ាងរាងភក់ : ស្រូវមួយតៃ, ល្អីតៃ ; ឈ្មោះប្រាក់បុរាណមួយបែប : ប្រាក់តៃ , មួយតៃ , ពីរតៃ... ។

១១៣ - ពៃរ៍ ( ន. ) ពៀរ, ខ្មែរច្រើនប្រើពាក្យនេះ ជាបរិវារសព្ទ និយាយផ្សំនឹងពាក្យទោស : ទោសពៃរ៍ គឺទោសនឹងពៀរ ឬទោសជាពៀរ ។

ឧទាហរណ៍ ទី ១១៣

អ្នកឯងលួចស្រូវគេមួយតៃ ពុំខ្លាចមានទោសពៃរ៍ទេឬ ? ចំណែកខ្ញុំសូម្បីប្រាក់មួយចំហៀងតៃ ក៏ពុំហ៊ានលួច ព្រោះខ្ញុំខ្លាចទោសពៃរ៍ណាស់ ។

## " ពោធិ៍, ពោរ "

១១៤— ពោធិ៍ ( ន. ) ឈើដែលព្រះមហាសត្វ គង់អាស្រ័យក្នុងម្លប ទ្រង់ក៏បានត្រាស់ជាព្រះពុទ្ធ : ដើមពោធិ៍ ។

១១៤— ពោរ ( គុ. ) ដែលដន់ដោរឡើង, ដែលឡើងគំពុង : ទឹកពោរមាត់ច្រាំង, ពេញពោរ... ។

ឧទាហរណ៍ ទី ១១៤

ឆ្នាំនេះទឹកជន់ពោរមាត់ច្រាំង ហូរចូលទៅក្នុងវត្តលិចគល់ពោធិ៍អស់ឥតសល់ ។

www.budinst.gov.kh www.elibraryofcambodia.org

## " ព័ត្រ, ព្រាត់ "

១១៥- ព័ត្រ (ន.) ពួរខ្សែត្រកួញធ្វើដោយស្បែកគោ, ស្បែកក្របី ឬស្បែកម្រឹគណាមួយ : ព័ត្រស្បែកក្របីជាប់ជាងព័ត្រស្បែកគោ, ដ្រាម... ។

១១៥- ព្រាត់ (កិ.) បែកឃ្លាតចាកបុគ្គលជាទីស្រឡាញ់, ឃ្លាតជាច់លែងបានជួបគ្នាទៀត : ព្រាត់កូន, ព្រាត់មិត្រ, ព្រាត់ប្រាស ... ។

ឧទាហរណ៍ ទី ១១៥

*ល្បែងទាញព័ត្រ ជាល្បែងមួយរបស់ខ្មែរជាន់ដើម សម្រាប់លេងកុងដូរប្ដូលគ្នា, ល្បែងនេះសប្បាយណាស់ សូម្បីមានទុក្ខព្រាត់ប្រាសយ៉ាងណាក៏គង់សប្បាយបាន ។*

## " ព្រហ្ម, ព្រំ "

១១៦- ព្រហ្ម (ន.) សេចក្ដីចំរើន, សេចក្ដីរីកចិត្ត, សេចក្ដីប្រសើរ, ទេវតាដែលនៅព្រហ្មលោក ដោយអំណាចផលនៃឈានចិត្ត : ព្រះព្រហ្ម, ឋានព្រហ្ម, ពួកព្រហ្ម... ។

១១៦- ព្រំ (កិ.) ប្រក់ភ្ជិត ឬប្លូកបាយអភ្ជិតត្រង់កន្លែងប្រទល់ក្បាលកណ្ដាប ឬក្បាលក្បឿង : ព្រំផ្ទះ ... ។

១១៦- ព្រំ (ន.) បារីកដី, ទីបំផុតដែនប្រទល់គ្នា : ព្រំចំការ, ព្រំខេត្ត, ព្រំដែន, ព្រំប្រទល់ ...; ឈ្មោះកំរាលវិសេសពួកមួយ វិចិត្រដោយពណ៌និងក្បាច់របនាផ្សេងៗ : ព្រំខ្សែ, ព្រំប្ដូនជ្រុង, ក្រាលព្រំ... ។

www.budihst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១១៦

ខ្ញុំព្រឹទ្ធះហើយ ខិនចូនព្រៃដែនទៅវិញ យកព្រំមួយខ្សែដែលមាន ក្បាច់ដូចបំពង់មហាព្រហ្ម ទៅថែននេភគ្រខ្ញុំ ។

"ព្រាម, ព្រាហ្មណ៍"

១១៧– ព្រាម (ន.) ឈ្មោះស្វាមួយយ៉ាង សម្បុរខ្មៅពក្លក់ រោមត្រង់មុខសម្បុរសប្រផេះស្រមូរ : ស្វាព្រាម... ។

១១៧– ព្រាហ្មណ៍ (ន.) មនុស្សដែលកំណត់តាមលទ្ធិ បុរាណពីព្រេងនាយ ថាមានពូជដើមកើតអំពីព្រះឧស្សព្រហ្ម : ពួកព្រាហ្មណ៍, ជាតិព្រាហ្មណ៍... ។

ឧទាហរណ៍ ទី១១៧

ខ្ញុំបានឃើញព្រាហ្មណ៍ម្នាក់ មុខស្រទូវដូចមុខស្វាព្រាម ។

"ព្រឹក, ព្រឹក្ស"

១១៨– ព្រឹក (ន.) វេលាតាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំ ឬជាបដល់ថ្ងៃត្រង់ក៏នៅហៅព្រឹកបានដែរ : ព្រឹកមិញ, ព្រឹកព្រហាម... ។

១១៨– ព្រឹក្ស (ន.) ឈើ; ពាក្យនេះខ្មែរច្រើនប្រើផ្សំជាបទជាមាសវៀងខាងចុងតាមសព្ទ : ជព្វព្រឹក្ស, ពោធិព្រឹក្ស, និគ្រោធព្រឹក្ស... ។

ឧទាហរណ៍ ទី ១១៨

មានតាចាស់ម្នាក់ជ្រះថ្លាចំពោះដើមពោធិព្រឹក្ស គាត់តែងទៅថ្វាយបង្គំរាល់ៗព្រឹកពុំដែលខាន ។

www.budinst.gov.kh www.elibraryofcambodia.org

## " ព័ត្រ, ព្រាត់ "

១១៥– ព័ត្រ (ន.) ពួរខ្សែត្រកួញធ្វើដោយស្បែកគោ, ស្បែកក្របី ឬស្បែកម្រឹគណាមួយ : ព័ត្រស្បែកក្របីជាប់ជាងព័ត្រស្បែកគោ, ដ្រាម... ។

១១៥– ព្រាត់ (កិ.) បែកឃ្លាតចាកបុគ្គលជាទីស្រឡាញ់, ឃ្លាតបាត់លែងបានជួបគ្នាទៀត : ព្រាត់កូន, ព្រាត់មិត្រ, ព្រាត់ប្រាស ... ។

ឧទាហរណ៍ ទី ១១៥

*ខ្សែទាញព័ត្រ ជាខ្សែមួយរបស់ខ្មែរជាទំដើម សម្រាប់លេងកន្ទុយប្រយុទ្ធ, ខ្សែនេះសប្បាយណាស់ ស្ដាប់ស្ដាយនឹកព្រាត់ប្រាសយ៉ាងណាក៏គង់សប្បាយបាន ។*

## " ព្រហ្ម, ព្រំ "

១១៦– ព្រហ្ម (ន.) សេចក្ដីចំរើន, សេចក្ដីរីកចិត្ត, សេចក្ដីប្រសើរ, ទេវតាដែលនៅព្រហ្មលោក ដោយអំណាចផលនៃឈានចិត្ត : ព្រះព្រហ្ម, វិមានព្រហ្ម, ពួកព្រហ្ម... ។

១១៦– ព្រំ (កិ.) ប្រក់ភ្ជិត ឬប្ញូកបាយអភ្ជិតត្រង់កន្លែងប្រទល់ក្បាលកណ្ដាប ឬក្បាលក្បៀង : ព្រំផ្ទះ ... ។

១១៦– ព្រំ (ន.) បារីកដី, ទីបំផុតដែនប្រទល់គ្នា : ព្រំចំការ, ព្រំខេត្ត, ព្រំដែន, ព្រំប្រទល់ ...; ឈ្មោះកំរាលវិសេសពួកមួយ វិចិត្រដោយពណ៌នឹងក្បាច់របនាផ្សេងៗ : ព្រំខ្សែ, ព្រំបួនជ្រុង, ក្រាលព្រំ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១១៦

ខ្ញុំព្រឹទ្ធះហើយ ខំឆ្ងល់ព្រៃផងទៅវិញ យកព្រំមួយខ្សែដែលមាន

ក្បាច់ដូចបំពត់មហាព្រហ្ម ទៅប៉ះគេនពេកគ្រប់ ។

"ព្រាម, ព្រាហ្មណ៍"

១១៧- ព្រាម (ន.) ឈ្មោះស្វាមួយយ៉ាង សម្បុរខ្មៅពព្លក់ រោមត្រង់

មុខសម្បុរសប្រផេះស្រមូរ : ស្វាព្រាម... ។

១១៧- ព្រាហ្មណ៍ (ន.) មនុស្សដែលកំណត់តាមលទ្ធិ បុរាណពី

ព្រេងនាយ ថាមានពូជដើមកើតអំពីព្រះឧស្មព្រហ្ម : ពួកព្រាហ្មណ៍, ជាតិព្រាហ្មណ៍... ។

ឧទាហរណ៍ ទី១១៧

ខ្ញុំបានឃើញព្រាហ្មណ៍ម្នាក់ មុខស្រអូវដូចមុខស្វាព្រាម ។

"ព្រឹក, ព្រឹក្ស"

១១៨- ព្រឹក (ន.) វេលាតាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺ

ធំ ឬជិតបង្គ្រប់ថ្ងៃត្រង់កំនៅហៅព្រឹកបានដែរ : ព្រឹកមិញ, ព្រឹកព្រហាម... ។

១១៨- ព្រឹក្ស (ន.) ឈើ; ពាក្យនេះខ្មែរច្រើនប្រើផ្សំជាបទជាមាស

វៀងខាងចុងតាមសព្ទ : ជព្ធព្រឹក្ស, ពោធិព្រឹក្ស, និគ្រោធព្រឹក្ស... ។

ឧទាហរណ៍ ទី ១១៨

មានតាតាសម្នាក់ជ្រះថ្លាចំពោះដើមពោធិព្រឹក្ស គាត់តែងទៅថ្វាយ

បង្គំរាល់ៗព្រឹកពាំដែលមាន ។

## " ភប់. ភព "

១២៣– ភប់ (កិ.) ចូប, ប្រទះ, ប្រសព្វ, ច្រើននិយាយថាភប់ប្រសព្វ គឺបានគ្នាជាគូស្រករ...។

១២៣– ភព (ន.) សេចក្ដីចំរើន, ដំណើរកើត, ប្រទេស ឬទីសម្រាប់សព្វសត្វកើតស្លាប់, លោក: ភពបី, ភពតូចភពធំ, ទាំងផែនភព...។

ឧទាហរណ៍ ទី ១២៣

*កើតក្នុងភពណា ៗ សូមឲ្យបានភប់ប្រសព្វតែនឹងព្រះពុទ្ធសាសនា។*

## " ភណ្ឌ, ភ័ន្ត = ភាន់ "

១២៤– ភណ្ឌ (ន.) ទ្រព្យ, របស់, ដើមទុន, គ្រឿងប្រើប្រាស់, អីវ៉ាន់, ប្រដាប់, គ្រឿងប្រដាប់; ច្រើនប្រើផ្សំជាមួយនឹងនាមសព្ទឯទៀត: កសិភណ្ឌ, គរុភណ្ឌ, លហុភណ្ឌ, នានាភណ្ឌ...។

១២៤– ភាន់ (កិ.) ង្វិស, ច្រឡំ, ទោសខុសផ្លូវខុសទំនង: ភាន់គំនិត ភាន់ដំណើរ, ភាន់ផ្លូវ, ភាន់ស្មារតី, ភាន់ច្រឡំ...។

ឧទាហរណ៍ ទី ១២៤

*អ្នកបួសប្រយ័ត្នភាន់ច្រឡំរបស់គរុភណ្ឌ ថាជារបស់ខ្លួន, ការភាន់ច្រឡំយ៉ាងនេះនាំឲ្យមានទោស ។*

www.budhist.gov.kh www.elibraryofcambodia.org

## "ភូម. ភូមិ = ភូមិ៍"

១២៥ – ភូម (ន.) ទេវតាដែលស្ថិតនៅផ្ទាល់លើផែនដី : ព្រះភូម; ខ្មែរហៅចំពោះទេវតាឬបិសាចដែលអាស្រ័យនៅទីស្រែចំការ : សែនព្រះភូម ។

១២៥ – ភូមិ (ន.) ផែនដី, ទីដី, តំបន់, ផ្លូវ, ទី, ជាន់, ថ្នាក់ : ខ្មែរច្រើនប្រើសំដៅទីដែលមានប្រជុំផ្ទះក្នុងតំបន់និមួយ ៗ : ភូមិលំនៅ ភូមិឋាន; អរិយភូមិ... ។

ឧទាហរណ៍ ទី ១២៥

*នៅភូមិឋានខ្លះក្នុងប្រទេសកម្ពុជា ពួកជនច្រើននិយមជឿព្រះភូម ជាអ្នកឲ្យសុខចំរើន ។*

## "ភ្នែន. ភ្នែន"

១២៦ – ភ្នែន (ន.) ល្បត់ខ្លួនពស់ដែលពេន សណ្ឋានដូចរោចង្កាយ ភ្នែនពស់; អ្វី ៗ ដែលគេចាប់បំពេនជាវង់មូលបាន ក៏ហៅថាភ្នែនដែរ : ភ្នែនកណ្ដាប់ ។

– ១២៦ – ភ្នែន (ន.) បែបបទ ឬ បែបភាពដែលពែន, កិរិយាអង្គុយពែនជើង : ផ្គត់ភ្នែន, ពែនភ្នែន... ។

ឧទាហរណ៍ ទី ១២៦

*ព្រះបុទ្ធរូបទ្រង់ផ្គត់ព្រះភ្នែន លើភ្នែនពស់ឈ្មោះមុចលិន្ទនាគរាជ ។*

## "មរ, មរណ៍"

១២៧ – មរ (កិ.) ស្លាប់, (ច្រើនប្រើក្នុងកាព្យឃ្លោង) ។

www.budinst.gov.kh www.elibraryofcambodia.org

## " ភប់. ភព "

១២៣– ភប់ (កិ.) ចួប, ប្រទះ, ប្រសព្វ, ច្រើននិយាយថាភប់ប្រសព្វ គឺបានភ្ជាជាគូស្រករ... ។

១២៣– ភព (ន.) សេចក្ដីចំរើន, ដំណើរកើត, ប្រទេស ឬទីសម្រាប់សព្វសត្វកើតស្លាប់, លោក: ភពបី, ភពតូចភពធំ, ទាំងដែនភព... ។

ឧទាហរណ៍ ទី ១២៣

*កើតក្នុងភពណា ៗ សូមឲ្យបានភប់ប្រសព្វតែនឹងព្រះពុទ្ធសាសនា ។*

## " ភណ្ឌ, ភ័ន្ទ = ភាន់ "

១២៤– ភណ្ឌ (ន.) ទ្រព្យ, របស់, ដើមទុន, គ្រឿងប្រើប្រាស់, អីវ៉ាន់, ប្រដាប់, គ្រឿងប្រដាប់; ច្រើនប្រើផ្សំជាមួយនឹងនាមសព្ទឯទៀត: កសិភណ្ឌ, គរុភណ្ឌ, លហុភណ្ឌ, នានាភណ្ឌ... ។

១២៤– ភាន់ (កិ.) ច្រឡំ, ច្របូក, ខុសឆ្គងខុសទំនង: ភាន់គំនិត ភាន់ដំណើរ, ភាន់ផ្លូវ, ភាន់ស្មារតី, ភាន់ច្រឡំ... ។

ឧទាហរណ៍ ទី ១២៤

*អ្នកបួសប្រយ័ត្នភាន់ច្រឡំរបស់គរុភណ្ឌ ថាជារបស់ខ្លួន, ការភាន់ច្រឡំយ៉ាងនេះនាំឲ្យមានទោស ។*

www.budinst.gov.kh www.elibraryofcambodia.org

## " ភូម, ភូមិ = ភូមិ៍ "

១២៥ – ភូម (ន.) ទេវតាដែលស្ថិតនៅផ្ទាល់លើផែនដី : ព្រះភូម; ខ្មែរហៅចំពោះទេវតាឬបិសាចដែលអាស្រ័យនៅទីស្រែចំការ : សែនព្រះភូម ។

១២៥ – ភូមិ (ន.) ផែនដី, ទីដី, តំបន់, ផ្លូវ, ទី, ជាន់, ថ្នាក់ : ខ្មែរច្រើនប្រើសំដៅទីដែលមានប្រជុំផ្ទះក្នុងតំបន់និមួយ ៗ : ភូមិលំនៅ ភូមិឋាន; អរិយភូមិ... ។

ឧទាហរណ៍ ទី ១២៥

នៅភូមិឋានខ្លះក្នុងប្រទេសកម្ពុជា ពួកជនច្រើននិយមជឿព្រះភូមជាអ្នកឲ្យសុខចំរើន ។

## " ភ្លេន, ភ្លែន "

១២៦ – ភ្លេន (ន.) ល្បាត់ខ្លួនកស់ដែលពេន សណ្ឋានដូចងាចង្កាយ ភ្លេនពស់; អ្វី ៗ ដែលលេចាប់បំពេនងារផ្លូវមូលបាន ក៏ហៅថាភ្លេនដែរ : ភ្លេនកណ្ដាប់ ។

– ១២៦ – ភ្លែន (ន.) បែបបទ ឬ បែបភាពដែលពែន, កិរិយាអង្គុយពែនជើង : ផ្គត់ភ្លែន, ពែនភ្លែន... ។

ឧទាហរណ៍ ទី ១២៦

ព្រះបុត្រទ្រង់ផ្គត់ព្រះភ្លែន លើភ្លេនពស់ឈ្មោះមុចលិន្ទនាគរាជ ។

## " មរ, មរណ៍ "

១២៧ – មរ (កិ.) ស្លាប់, ( ច្រើនប្រើក្នុងកាព្យឃ្លោង ) ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៣១

មនុស្សប្រុលចិត្តបរិភោគទីដាំនគុយទាវ. ព្រឹកៗ ឃើញមនុស្សមើរៗ

ទៅកន្លែងលក់មី ។

## "ម៉ូត, មូត្រ"

១៣២- ម៉ូត (ន.) ឈ្មោះសំពត់មួយយ៉ាងមានសម្បុរសផ្ទេក នាំមកពី

ប្រទេសក្រៅ : សំពត់ម៉ូត ។

១៣២-មូត្រ (ន.) អានថាមូ៉ត(ទឹកនោម) : គោមូត្រ, មូត្រមនុស្ស...។

ឧទាហរណ៍ ទី១៣២

ខ្ញុំកំពុងតែអត់ធ្មត់បន្ទោរមូត្រ ស្រាប់តែស្ត្រីម្នាក់ពាក់អាវសំពត់ម៉ូត

ដើរកៀក្បែរខ្ញុំ ។

## "មូល, មូល្យ"

១៣៣-មូល (ន.) ឫសគល់, មើម, ដើមកំណើត, ដើមចម, ដើម

ទុន, ទីតាំង, ទ្រព្យដើម, ដំឡៃ : កុសលមូល, ពាទមូល, រុក្ខមូល... ។

១៣៣-មូល (កិ.ឬ គុ.វិ.) រួបរួមគ្នា, ជុំគ្នា, មូលកូនចៅ, មូលគ្នា,

នៅមូលគ្នា, ឈមូលគ្នា...។

១៣៣-មូល (គុ.) ដែលមានមណ្ឌលជុំវិញឥតជ្រុងឥតជ្រុងឥតជ្រោង :

តុមូល, ប្រអប់មូល...។

www.budget.gov.kh www.elibraryofcambodia.org

១៣៣- មូល្យ (ន.) ដំឡៃ, ឈ្នួល, បំណាច, ប្រាក់ខែ : ប្រាក់មូល្យខ្ញុំតិចណាស់; (ច្រើនប្រើក្នុងពាក្យកាព្យឃ្លោង)... ។

ឧទាហរណ៍ ទី ១៣៣

ខ្ញុំនៅមូលកូនចៅគ្នាច្រើនណាស់ ដេកពេញផ្ទះរហូតដល់រោងមូល ប្រាក់មូល្យជានមួយពាន់ចាយពុំគ្រាន់ ទិញបានតែពូមូលមួយ ។

"មួ. មួរ"

១៣៤- មួ (កិ.) ក្ដាញ់, ខឹងខ្វល់ក្នុងចិត្ត : មួចិត្ត, មួម៉ៅក្ដៅក្រហាយ, មួហ្មង... ។

១៣៤- មួរ (ន.) ស្រូវដែលដុះពីគ្រាប់ជ្រុះនៅក្នុងស្រែតាំងពីខែចម្រូត : ស្រូវមួរ : ស្រែមួរ, ដកមួរ... ។

ឧទាហរណ៍ ទី ១៣៤

ខ្ញុំមានស្រូវមួរបន្តិចការពារពុំឈ្នះសោះ គោក្របីចេះតែស៊ី នាំឲ្យមួចិត្តៗ

"មោក, មោឃ"

១៣៥- មោក (ន.) ឈ្មោះឈើព្រៃមួយយ៉ាង មានបន្លាតាមដើមនឹងមែក ស្លឹកល្អិតៗ : ដើមមោក... ។

១៣៥- មោឃ (គុ.) ដែលសោះសូន្យ, ឥតប្រយោជន៍, ឥតអំពើ, ទទេ, ពោលល្បៀត : មោឃ ! អាមោក ! ខ្ញុំមោឃសុទ្ធហើយឥតដឹងរឿងអ្វីក្នុងស្រុកទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៣១

មនុស្សប្រុលចិត្តបរិភោគទីផាន់គុយទាវ. ព្រឹកៗ ឃើញមនុស្សមើរៗ

ទៅកន្លែងលក់មី ។

"ម៉ូត, មូត្រ"

១៣២– ម៉ូត (ន.) ឈ្មោះសំពត់មួយយ៉ាងអានសម្បុរសផ្លេក នាំមកពី

ប្រទេសក្រៅ : សំពត់ម៉ូត ។

១៣២– មូត្រ (ន.) អានថាម៉ូត(ទឹកនោម) : គោមូត្រ, មូត្រមនុស្ស...។

ឧទាហរណ៍ ទី១៣២

ខ្ញុំកំពុងតែអង្គុយបន្ទោមូត្រ ស្រាប់តែស្ត្រីម្នាក់ពាក់អាវសំពត់ម៉ូត

ដើរកែក្បែរខ្លួនខ្ញុំ ។

"មូល, មូល្យ"

១៣៣– មូល (ន.) ឫសគល់, មើម, ដើមកំណើត, ដើមចម, ដើម

ទុន, ទីតាំង, ទ្រព្យដើម, ដំឡៃ : កុសលមូល, ជាទមូល, រក្ខមូល...។

១៣៣– មូល (កិ. ឬ កិ. វិ.) រួបរួមគ្នា, ជុំគ្នា, មូលកូនចៅ, មូលគ្នា,

នៅមូលគ្នា, ឈមូលគ្នា...។

១៣៣– មូល (គុ.) ដែលមានមណ្ឌលជុំវិញឥតជ្រុងឥតផតឥតហ៊ោង :

គុមូល, ប្រអប់មូល...។

www.budinst.gov.kh www.elibraryofcambodia.org

១៣៣ — មូល្យ (ន.) ដំឡៃ, ឈ្នួល, បំណោញ, ប្រាក់ខែ : ប្រាក់មូល្យខ្ញុំតិចណាស់; (ច្រើនប្រើក្នុងពាក្យកាព្យឃ្លោង)... ។

ឧទាហរណ៍ ទី ១៣៣

ខ្ញុំនៅមូលកូនចៅគ្នាច្រើនណាស់ ដេកពេញផ្ទះរហូតដល់ក្រុមមូល ប្រាក់មូល្យជាន់មួយពាន់ចាយពុំគ្រាន់ ទិញបានតែតុមូលមួយ ។

"មួ. មួរ"

១៣៤ — មួ (កិ.) ក្នាញ់, ខឹងខ្វល់ក្នុងចិត្ត : មួចិត្ត, មួម៉ៅក្ដៅក្រហាយ, មួហ្មង... ។

១៣៤ — មួរ (ន.) ស្រូវដែលដុះពីគ្រាប់ជ្រុះនៅក្នុងស្រែតាំងពីខែចម្រូត : ស្រូវមួរ : ស្រែមួរ, ដកមួរ... ។

ឧទាហរណ៍ ទី ១៣៤

ខ្ញុំមានស្រូវមួរបន្តិចការពារពុំឈ្នះសោះ គោក្របីចេះតែស៊ី នាំឲ្យមួចិត្ត ។

"មោក, មោឃ"

១៣៥ — មោក (ន.) ឈ្មោះឈើព្រៃមួយយ៉ាង មានបន្លាតាមដើមនិងមែក ស្លឹកល្អិត ៗ : ដើមមោក... ។

១៣៥ — មោឃ (គុ.) ដែលសោះសូន្យ, ឥតប្រយោជន៍, ឥតអំពើ, ទទេ, បោលម្សៀត : មោឃ ! អាមោឃ ! ខ្ញុំមោឃសុទ្ធហើយឥតដឹងរឿងអ្វីក្នុងស្រុកទេ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី១៣៥

អ្នកឯងស្គាល់ដើមមាក្សុរ? ទេ! ខ្ញុំមាយសុទ្ធហើយមាំដើមឈើ ។

" ម្រ័ក្សណ៍ ម្រាក់ "

១៣៦- ម្រ័ក្សណ៍ (ន.) ឈ្មោះជ័រកើតអំពីដើមគ្រើល មាន

សម្បុរខ្មៅ : ឈាបម្រ័ក្សណ៍, ម្រ័ក្សណ៍គោល ...។

៣៦- ម្រាក់ (ន.) ក្មើស្រី គឺក្មើស្រ្តីនឹងស្រ្តី ឬពាក្យប្រុសហៅ

ស្រ្តីជាប្រពន្ធរបស់ក្មើ : ក្មើម្រាក់...។

ឧទាហរណ៍ ទី១៣៦

អ្នកឯងឲ្យម្រ័ក្សណ៍ខ្ញុំមួយចំពង់ ខ្ញុំបុងចិត្តធ្វើក្មើម្រាក់ទីងអ្នកទៅ។

" យន់ យន្ត = យន្រ្ត "

១៣៧- យន់ (កិ.) ជាបបុះ, ទន់, ទនបុះ, ជ្រុលជ្រិប :

យប់យន់, យន់ត្របកភ្នែក, យន់កំលាំង, យន់ដំណោក គឺងុយដេកខ្លាំង...។

១៣៧- យន្ត (ន.) គ្រឿងប្រដាប់ដែលកំរើកបានដោយកំលាំង

ចក្រប្រកបគ្នា : យន្តហោះ, យន្តដើរ, រថយន្ត, កំលាំងយន្ត, ម្ចាស់យន្ត...។

ឧទាហរណ៍ ទី១៣៧

ខ្ញុំអស់កំលាំងណាស់ ព្រោះយប់មិញជិះរថយន្តរាល់ព្រឹក ពុំបាន

សំរាកសោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## "យម, យំ"

១៣៨- យម (ន) សេចក្ដីស្លាប់, អធិបតីនរក : ព្រះយម ។

១៣៨- យំ (កិ.) បញ្ចេញសូរសព្ទព្រមទាំងចេញទឹកភ្នែក ព្រោះសេចក្ដីសោកស្ដាយ អាល័យឬទោមនស្សអាក់អន់ចិត្ត ឬព្រោះឈឺចាប់ខ្លាំង : យំយប់, យំសោក, យំអាល័យ... ។

ឧទាហរណ៍ ទី ១៣៨

*កូនខ្ញុំយប់មិញយំរហូតដល់ព្រឹក ព្រោះវាយល់សប្ដិឃើញព្រះយមដេញកាប់សត្វនរក ។*

## "យុក, យុគ"

១៣៩- យុក (ន.) ឈ្មោះភមរជាតិមួយយ៉ាង ពួកម្រោម តែនៅក្នុងរន្ធដីធ្វើចំពួយសម្រាប់ចេញចូល ចេះធ្វើឃ្មុំដាក់ទឹកបាន ទឹកមានរសផ្អែមស្រដៀងនឹងទឹកឃ្មុំ : សត្វយុក, ទឹកយុក... ។

១៣៩- យុគ (ន.) នឹម, គូ, អាយុ, អាយុពិភពលោក, កាល, គ្រា, សម័យ, ដំណើរកំណត់កាលរបស់ពិភពលោក, តាមលទ្ធិបុរាណថាយុគមាន ៤ យ៉ាង គឺ : ទី១- ក្រឹតយុគ, ទី២- ត្រេតយុគ, ទី៣- ទ្វាបរយុគ, ទី៤- កលិយុគ (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ៧៩៣,) ។

ឧទាហរណ៍ ទី ១៣៩

*យើងសព្វថ្ងៃនៅក្នុងយុគទី៤ គឺកលិយុគ, យុគនេះប្រកបដោយទុក្ខទោសច្រើន សូម្បីទ្រូងនៅក្នុងដីបរិភោគតែរសផ្អែមដូចសត្វយុក ក៏នៅតែមានទុក្ខ ។*

www.budinst.gov.kh www.elibraryofcambodia.org

## " រក្ស, រាក់ "

១៤០- រក្ស (កិ.) រក្សា; ខ្មែរប្រើពាក្យនេះរួមចូលនឹងសព្ទដទៃឲ្យជាបទសមាស : គ្រឹហានុរក្ស = អ្នករក្សាផ្ទះ, អ្នកចាំផ្ទះ, ធម្មានុរក្ស = អ្នករក្សាធម៌ អ្នកកាន់តាមធម៌...។

១៤០- រាក់ (ន.) ទីទេពីជ្រៅ គឺមានដំរៅតិច : ទឹករាក់, គំនិតរាក់, អណ្តូងរាក់, រណ្តៅរាក់... ។

១៤០- រាក់ (ន.) ឈ្មោះឈើតូចម្យ៉ាង ឬឈ្មោះរោគកើតនៅជើងធ្មេញ ឬនៅឧច្ចារមគ្គ : រាក់ស, រាក់ក្រហម; ធ្មេញកើតរាក់; រាក់បាត...។

ឧទាហរណ៍ ទី ១៤០

បុគ្គលណាជាធម្មានុរក្ស, បុគ្គលនោះមានគំនិតពុំរាក់ទេ ដូចបុរសម្នាក់ដែលកើតរាក់បាតជាតួយ៉ាង ។

## " រង់, រង្គ "

១៤១- រង់ (កិ.) បង្អង់ចាំ, ឈប់បង្អង់ : រង់ចាំសិន, រង់បន្តិច... ។

១៤១- រង្គ (ន.) ឈ្មោះជ័រមានសម្បុរលឿងសំរាប់ប្រើជាថ្នាំគំនូរ ឬប្រើជាថ្នាំរម្ងាប់រោគខ្លះក៏បាន : លាមរង្គ, ថ្នាំរង្គ...។

ឧទាហរណ៍ ទី ១៤១

អ្នកឯងទៅណា? ទៅទិញរង្គមកគូរគំនូរឬ? ទើបទៅទិញរង្គ រង់ចាំខ្ញុំផង ខ្ញុំទៅដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

“ រដ្ឋ, រ័តន៍ = រត្ន, ភាត់ ”

១៤២– រដ្ឋ (ន.) ដែន, ប្រទេស : កម្ពុជរដ្ឋ, ពលរដ្ឋ...។

១៤២– រ័តន៍ (ន.) កែវ, ពេជ្រ, ត្បូងគ្រប់យ៉ាង : ព្រះពុទ្ធរ័តន៍, រ័តន៍ ៧ ប្រការ, បល្លង្ករ័តន៍... ។

១៤២– ភាត់ (កិ.ឬ គុ.វិ.) ទាញកន្ត្រាក់ផ្ដាច់ដោយបង្ខំ : ទាញភាត់ផ្ដាច់, ភាយភាត់ គឺភាយរះរះដោយចុងរំពាត់, ភាត់ភាយ គឺភាយរតាត់រតាយ ។

ឧទាហរណ៍ ទី ១៤២

រតនទាំង ៧ ប្រការកើតចំពោះព្រះបរមចក្រពត្តិដែលកើតក្នុងមហារដ្ឋ មិនកើតសាធារណ៍ក្នុងដល់បុគ្គលដទៃជាពលរដ្ឋឡើយ ។

“ រត់, រថ ”

១៤៣– រត់ (កិ.) ស្ទុះដោយល្បឿន : រត់លឿន, រត់បាត, រត់ដោយខ្លាច... ។

១៤៣– រថ (ន.) រទេះទឹមសេះ មានទ្រង់ទ្រាយផ្សេងៗ ទីទៃពីរទេះគោ – រទេះក្របី : រថសេះ, បររថ, ជិះរថ, រថភ្លើង, រថយន្ត... ។

ឧទាហរណ៍ ទី ១៤៣

រថសេះខ្ញុំ រត់មួយថ្ងៃបានចម្ងាយ ៥០ គីឡូម៉ែត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

## " រង្គាស់, រង្គះ "

១៤៤- រង្គាស់ (ន.) ប្រដាប់សម្រាប់រាស់, គ្រឿងរាស់ : រង្គាស់ដី, ឈើរង្គាស់... ។

១៤៤- រង្គះ (ន.) ប្រឡាយវ៉ីដែលរះក្បីឬទំនប់ ជាផ្លូវឲ្យទឹកហូរ : ដីករង្គះទឹក, រង្គះអាត់... ។

ឧទាហរណ៍ ទី ១៤៤

ខ្ញុំដេះបាត់ឈើរង្គាស់មួយត្រង់រង្គះទឹកតាប័ន ។

## " រម្យ, រំ, រុំ "

១៤៥- រម្យ (គុ.) រីករាយ, ដែលគួររីករាយ : សមរម្យ; ច្រើនភ្ជាប់នឹងពាក្យទម : រម្យទម ។

១៤៥- រំ (កិ.) ទទួរគ្របខ្លួនបង្ហប់កំសួលចំហាយផ្សែង, ដែលស្ងោរថ្នាំឲ្យក្ដៅចេញញើស ពីសព៌ាង្គកាយ ដើម្បីឲ្យស្រាលខ្លួនឲ្យជារោគ : រំឲ្យជារោគឫសដូងវិល ។

១៤៥ រុំ (កិ.) ក្រសោបព័ទ្ធជុំវិញ, ចងព័ទ្ធ, មូរព័ទ្ធ : រុំរបួស, រុំខ្សែ, រុំមូ... ។

ឧទាហរណ៍ ទី ១៤៥

មានគ្រូម្នាក់ប្រាប់ថា រោគឫសដូងវិល បានតែយកថ្នាំមកស្ងោរ ហើយរំឲ្យឃូរទើបជា, មើគ្រាន់តែលាបចន់រុំពីក្រៅពុំជាទេ; ពាក្យគេប្រាប់នោះសមរម្យដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

## "រស, រស់"

១៤៦– រស (ន.) សម្ផស្សដែលប៉ះពាល់ដីក្ដាបសាទ ដឹងថាប្រៃ, ផ្អែ, ចត់, ល្វីង, ផ្អែមជាដើម : រសផ្អែ, រសប្រៃ, រសចត់, រសផ្អែម...; (សូមមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ៨៦១ ។

១៤៦– រស់ (កិ.ប្ក គុ.) មានជីវិតនៅ, មិនទាន់ស្លាប់: ដែលមានជីវិតនៅ. ដែលមិនទាន់ស្លាប់ : រស់នៅ, សត្វរស់, មនុស្សរស់; ដែលរស់នៅ... ។

ឧទាហរណ៍ ទី ១៤៦

*ចៀងដ៏យកអាហារម៉ានរសឆ្ញាញ់មកឲ្យជីដូន ។ ជីដូនឲ្យពរ ឲ្យចៅរស់នៅបានសេចក្ដីសុខដរាបដល់ចាស់ កុំឲ្យមានអ្វីមកបៀតបៀន ។*

## "រា, រាហ៊ុ"

១៤៧– រា (កិ.) ហាម, ឃាត់, ថយក្រោយ, បែរចេញ, ទាសចេញ, រួញថយ, ដំទាស់, ប្រកែក : រាដៃ រាទឹក, រាកាំង, រាដំណើរ, រាគន្លង... ។

១៤៧- រាហ៊ុ (ន.) នាមរបស់អសុរម្នាក់ ជាបុត្រនៃវេបចិត្តអសុរិន្ទនឹងនាងសិង្ហិកា, មានខ្លួនដាច់ពាក់កណ្ដាល ដោយត្រូវចក្ររបស់វិស្ណុ : រាហូ ; ខ្មែរច្រើនហៅថា រាហ៊ុ, រាហ៊ុចាប់ចន្ទ្រ, ថ្ងៃមានរាហ៊ុ, ខែរាហ៊ុ, ថ្ងៃរាហ៊ុ... ។

ឧទាហរណ៍ ទី ១៤៧

*ថ្ងៃនេះរាហ៊ុចាប់ចន្ទ្រ យើងកុំទៅព្រៃឆ្ងាយពកដំណើរ ពុំបានសម្រេចការ ។*

www.budinst.gov.kh www.elibraryofcambodia.org

## " រាជ, រាជ, រាជ្យ "

១៤៨— រាជ (កិ.) រាយស្មើ, ដក់ស្មើ, សាយរាយស្មើ : ទឹករាបរាល, រាបពេញស្រែ... ។

១៤៨— រាជ (ន.) ព្រះរាជា, អ្នកគ្រងរាជ្យ ព្រោះមានតេជះក្រៃលែង ; សព្ទនេះប្រើជាបទសមាសបានជាអនេក បើរៀងខាងដើមសព្ទដទៃមើលថារាជៈ បើរៀងខាងចុងមើលថារាជ : ធាតុរាជ, ប្រទេសរាជ, មហារាជ... ; ( ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ៨៨០ ) ។

១៤៨— រាជ្យ (ន.) ភារៈជាព្រះរាជា, សម្បត្តិសម្រាប់ផែនដី, ស្រុកទេសដែលជាសម្បត្តិរបស់ព្រះរាជា; ការគ្រប់គ្រងផែនដី : សោយរាជ្យ, ដណ្ដើមរាជ្យ, ក្សត្រិយ៍ទ្រង់រាជ្យ, ច្រាំរាជ្យមកហើយ ... ។

ឧទាហរណ៍ ទី ១៤៨

*មានរឿងដំណាលថា មាននាគរាជពីរ ទាំងដណ្ដើមរាជ្យគ្នា ក្នុងស្រះអនោតត្ត ទឹកក្នុងស្រះនោះរាបស្មើមកលើគោក ជន់លិចផ្ទះអ្នកស្រុកអស់ ។*

## " រាប, រាពណ៍ "

១៤៩— រាប (គុ.) ដែលមិនរើបរើប, ដែលឥតប៉ោង, ឥតដត, ឥតខ្ពស់ទាប : ដីរាប, សាច់រាប... ។

១៤៩— រាពណ៍ (ន.) នាមរបស់ព្រះបាទទសកណ្ឋឬទសមុខ ( ក្នុងរឿងរាមាយណៈ ) : ពួករាពណ៍ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៤៩

កាលកពណ៌ត្រូវសត្រពះពម ដួលសន្ទុះលើដើមឈើបាក់កបអស់ផុតសល់ ។

## "រាស់, រ៉ះ"

១៥០ រាស់ (កិ.) កាយគាស់ដោយរនាស់ដៃ ឬរនាស់ធំ បង្កួសកិនលើផ្ទៃដី : រាស់សម្រាម, រាស់ស្មៅ... ។

១៥០- រាស់ (កិ. វិ.) តាមតែប្រទះ : ស្លត្រូតមិនរាស់, និយាយរាស់, បន្ទោសរាស់ គឺបន្ទោសរាស់បាត់តាមតែប្រទះ, កាប់រាស់... ។

១៥០- រ៉ះ (កិ. ឬ កិ. វិ.) ចេញពន្លឺត្រឹបៈពីក្នុងស្រទាប់មេឃ នៅវេលាព្រឹកព្រាហម ឬវេលាយប់ : ថ្ងៃរះ, ខែរះ, រះផ្កាយព្រឹក, ភ្លឺរះ, ស៊ីរះទាំងសងខាង... ។

ឧទាហរណ៍ ទី ១៥០

ខ្ញុំរាស់ដីស្រែតាំងពីថ្ងៃរះដល់ថ្ងៃត្រង់បាន ៥ ធ្នារ ។

## "រិស្ត, រ៉ិះ"

១៥១- រិស្ត (ន.) បាប, សេចក្តីលាមក, ដំណើរអាក្រក់, គ្រោះកាច : មានរិស្ត (ច្រើនប្រើក្នុងពាក្យកាព្យ) ។

១៥១- រ៉ិះ (កិ.) គិតពិចារណា, គិតខ្លួន, គិតច្រើន, គិតកាញ់ក្អិតក្អោចគេ : រិះមើល, មិនរិះទេ... ។

១៥១- រ៉ិះ (គុ.) ដែលកាញ់ខ្នេរគេ, ដែលកំណាញ់កំបុតកំប្លុញ : មនុស្សរិះ, រិះគន់, រិះគិត, រិះរេ, រិះរក... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៥១

*ធ្វើការអ្វីៗ ត្រូវតែរិះគិតឲ្យល្អិត ក្រែងណាមានវិស្ថមកកើត ។*

"រី, រីត៏"

១៥២- រី (អា. ទិ.) ពាក្យសម្រាប់ប្រើនាំមុខនាមនាមដែលជាប្រធាន ឬប្រើផ្ដើមសេចក្ដីក្នុងប្រយោគមួយ ៗ : រីបុរសនោះ, រីជនឯណា; រីឯមូលពឹងក្រឡឹង រីឯត្រង់ពឹងបន្ទាត់ កិរិយាពឹងសំពត់ អ្នកបរិសុទ្ធពឹងពឹងសីល...។

១៥២- រីត៏ (ន.) ទំនៀម, សណ្ដាប់, បែប : តាមរីត៏, ដោយរីត៏ គឺដោយបែប ដោយទំនៀម...។

ឧទាហរណ៍ ទី ១៥២

*រីបុរសក្នុងលោក លុះត្រាតែប្រតិបត្តិ តាមរីត៏របស់បណ្ឌិត ទើបហៅថាបុរសប្រសើរ ។*

"រឹត, ឫទ្ធិ = រិទ្ធិ"

១៥៣- រឹត (កិ.) ធ្វើឲ្យតឹង, ទាញឲ្យតឹង : រឹតខ្សែ, បងរឹត, រឹតបំណង, បំរើនឡើង, ភ្ជាប់ឡើង : ដម្ងីរឹត, រឹតរូត, រឹតដៃ, រឹតជាងដើម... ។

១៥៣ រឹត (ន.) ស្លឹកទ្រាំងដែលកាត់ហាលថ្ងៃស្ងួតហើយ សម្រាប់ប្រើការផ្សេងៗ មានចារសាស្ត្រាជាដើម : សាស្ត្រាស្លឹករឹត, ការរុងស្លឹករឹត... ។

១៥៣- ឫទ្ធិ (ន.) សេចក្ដីសម្រេច, ដំណើរកើតការ; អំណាច; សេចក្ដីអស្ចារ្យ, សំបើម : ប្រឡងឫទ្ធិ, ប្រើឫទ្ធិអំណាច, ភេទឫទ្ធិ កាយឫទ្ធិ...។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី១៥៣

មានបុរសកំសត់ម្នាក់ ពាក់ដូនស្មុករគ ចូលទៅប្រមូលឬទ្ធិ ទិញសេះអាជានេយ្យ ។

## “រ៉ញ់, រុញ”

១៥៤— រ៉ញ់ (កិ.) ទញ់, ទញ់តុះ, ទើសត៌និត : រញ់ចិត្ត, រញ់គំនិត, រញ់ពាក្យសំដី.... ។

១៥៤— រ៉ញ់ (គុ.) ខ្ទីទញ់ : ករញ់, រាងរញ់, រញ់រា, គំនិតរញ់...។

១៥៤— រុញ (កិ.) ច្រានទៅមុខ, ច្រានដំរុល : រុញទូក, រុញខស, រុញចុះរុញឡើង...។

ឧទាហរណ៍ ទី១៥៤

ខ្ញុំគ្រាន់តែឃើញព្រៃច្រើនរញ់ចិត្ត ប៉ុន្តែឪពុកខ្ញុំចេះតែរុញឲ្យធ្វើ ហើយ ក៏ពុំហ៊ានប្រកែក ។

## “រេ, រេហ៍”

១៥៥— រេ (កិ.) ងាក, បែរៀយ ១ : រេខ្លួន, រេរា, រេគំនិត, រេរង់, រេរក, រះរេ... ។

១៥៥— រេហ៍ (កិ.) ចៀតចៀន, ពិឃាត ; ច្រើនផ្សំនឹងពាក្យពល ឲ្យក្លាយទៅជានាមសព្ទ : រេហ៍ពលគឺកំឡាំងចៀតចៀន, ពលអ្នកចៀតចៀនឬអ្នកពិឃាត; ពួកយោធា, ពួកទាហ៊ាន, កងទ័ព : កេណ្ឌរេហ៍ពល លើករេហ៍ពល...។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី១៥៥

*កុំបោះវ័យហូរពេក គេណាបេហ៍ពលឲ្យធាច់ៗ ទៅ!*

## " វិញ, វេញ "

១៥៦—វិញ (កិ. វិ.) ដែលហូរតិច, ហូរលើទីភក់ : ទឹកហូរវិញ, ច្រើននិយាយផ្ទួនជាវិញៗ : ទឹកហូរវិញៗ ។

១៥៦—វេញ (គុ.) វេញ, ក្រិស, ល្អិតលាស់ចំរើនមិនរួច : សំទូងវេញ, រាំងវេញ.....។

ឧទាហរណ៍ ទី១៥៦

*ទឹកហូរកន្ទ្រែស្រែវិញៗ នែរ ដូចម្ដេចក៏ស្រូវបេះតែវេញពុំល្អិតលាស់*
*សោះ ចង់តែឆាប់អស់ដូច្នេះ?*

## " ភេច, ភេចន៍ "

១៥៧—ភេច (កិ.) ដាច់កើចហូតទាញយកចេញតែមួយៗ : ភេចភ្លើង, ភេចខស, ភេចផ្កា ..

១៥៧—ភេច (ន.) ថ្ងៃខាងរនោចនៃខែចន្ទគតិ : មួយភេច, ពីរភេច, បីភេច...។

១៥៧—ភេចន៍ (គុ.) ដែលភ្លឺ, ត្រចះ, រុងរឿង, ចិញ្ចាច : ពន្លឺរុងភេចន៍, ភ្លឺរុងភេចន៍....។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី១៥៧

កាលពីថ្ងៃម្សិលមិញ ខ្ញុំឃើញឧសដែលគេកកើងនៅក្រោមផ្ទះ នេះស្គ្រ

ក្លងកើងខែកណ្ដាលថ្ងៃ ។

## " លលា, លលាដ៍ "

១៥៨– លលា (គុ.) ឆ្កួតទឹកមាត់, ល្ងេញល្ងើ, ពភ្លឺពភ្លើ : មនុស្ស លលា, អាលលា; និយាយក្លាយជាលេលាក៏មាន ។

១៥៨– លលាដ៍ (ន.) ឆ្អឹង, ឆ្អឹងក្បាល; ត្រឡោក : លលាដ៍ក្បាល, លលាដ៍ដូង ; និយាយក្លាយជារលាក៏មាន : រលាដូង, រលាក្បាល ។

ឧទាហរណ៍ ទី ១៥៨

ព្រឹកមិញមានមនុស្សលលាម្នាក់កាន់លលាដ៍ដូង ដើរសុំបាយ

គេសិនគ្មាន ។

## " លប់, លុប "

១៥៩– លប់ (ន.) ប្រដាប់រាងសណ្ឋានជាទ្រុងរុំស្លឹកឈើស្រស់ មាន ប៉ែកជាកបក្សីធ្លាក់ មានប៉ែកសំណាញ់ មានគន្លឹះជួស់បាន សម្រាប់ឲ្យដាប់បក្សីព្រៃ ដែល ដើញធ្លាក់ : លប់លលក, លប់ទទា ..។

១៥៩– លុប (កិ. ឬ គុ.) ធ្វើឲ្យបាត់ស្នាម, ឲ្យបាត់គំនូស, ឲ្យបាត់សំអាត, ឲ្យបាត់រូប, ឲ្យបាត់ឈ្មោះ, ឲ្យវិនាស, ឲ្យសូន្យ ; ដែលបំបាត់គុណគេ : លុបឈ្មោះ, លុប អក្សរ, លុបដាន, លុបមុខ, លុបរណ្ដៅ; មនុស្សលុបគុណគេ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៥៩

*មនុស្សលុបគុណគេ តែងបានទទួលសេចក្តីវិនាស ដូចជាបុរសដាក់លប់ទទា ហើយតែងងើបក្រោកពីដេក ពុំបានលុបមុខផង ត្រូវគេចាប់ទៅសម្លាប់ ។*

“ ល័ខ = ល័ក្ខ, លក្ខណ៍ = លក្ស្មណ៍,

លក្ស្មណ៍, លាក់ ”

១៦០– ល័ក្ខ (ន.) ជ័រចេះរឹងកើតអំពីសត្វល្អិតពួកមួបេ មានសម្បុរក្រហម ឬផង់ល្អិត ឬកករឹងជាដុំមានពណ៌ផ្សេង ៗ សម្រាប់ប្រើជាគ្រឿងផ្តិលក់ : ល័ក្ខស្រម៉ី, ល័ក្ខខៀវ, –បៃតង, –ស្វាយ, –លឿង; ឬដំណាំដែលមានសម្បុរដូចល័ក្ខ : ចេកល័ក្ខ, ទៀបល័ក្ខ...។

១៦០– លក្ខណ៍ (ន.) គ្រឿងសំគាល់, គ្រឿងបំណាំ, គុណសម្បត្តិ : ស្ត្រីគ្រប់លក្ខណ៍, មនុស្សខាតលក្ខណ៍...។

១៦០– លក្ស្មណ៍ (ន.) នាមព្រះអនុជ របស់ព្រះរាម : ព្រះលក្ស្មណ៍ ។

១៦០– លាក់ (កិ.) ធ្វើឲ្យមានគន្លាក់ : លាក់ឈើ; បិទបាំង, បំបាំងទុកពុំឲ្យគេឃើញ : លាក់របស់, លាក់ខ្លួន, លាក់ពុត, លាក់កំបួច...។

ឧទាហរណ៍ ទី ១៦០

*ព្រះលក្ស្មណ៍ ជាអនុជរបស់ព្រះរាម តាមរឿងដំណាលថា មានសម្បុរលឿងខ្ចីដូចពណ៌ល័ក្ខ ជាបុរសគ្រប់លក្ខណ៍ ហើយមានចិត្តត្រង់ចំពោះព្រះរាម មើលហេតុអ្វី ៗ ពុំដែលលាក់នឹងព្រះរាមទេ ។*

www.budinst.gov.kh www.elibraryofcambodia.org

## " លស់. លោះ "

១៦១– លស់ (កិ) ធ្វើឲ្យរលស់ គឺបន្ថយចំនួន ឬធ្វើឲ្យតិចចុះ មិនឲ្យនៅតាមចំនួនដើម : ក្នុងចំនួន ១០ លស់ ៣ នៅសល់ ៧; រំលង : គ្រុនលស់ ។

១៦១– លោះ (កិ) ចេញថ្លៃយករបស់ដែលបញ្ចាំ ឬយកមនុស្សមកធ្វើជាទាសៈ ឬទាសី : លោះរបស់, លោះមនុស្សប្រើ; បាញ់ : លោះកាំភ្លើង, លោះស្នា...។

១៦១– លោះ (ន.) ឈ្មោះឈើមួយយ៉ាងស្លឹកធំៗ ស្រដៀងនឹងស្លឹកគគ្រិ ផ្លែមូលសំបកក្រាស់ : ផ្លែលោះ, ដើមលោះ; ខ្លះហៅថាដើមបំពេញភព្ស ។

ឧទាហរណ៍ ទី ១៦១

ផ្លែលោះ ១០ ខ្ញុំលស់ ៥ សល់ ៥ ទុកលក់យកលុយលោះក្អមជល្មោច ព្រោះខ្ញុំត្រូវលស់ជាពីលោះកែកាំភ្លើង ។

## " លាប, លាភ "

១៦២– លាប (កិ.) ធ្វើវត្ថុទប់ រាវឬផង់ឲ្យជិតជាប់. ឲ្យជោក, ឲ្យប្រឡាក់ : លាបថ្នាំ, លាបប្រេង... ។

១៦២– លាភ (ន.) ដំណើរប្រទះលើការបាន, ការបាន, អ្វីៗដែលគួរបាន, បំណាញ : មានលាភ, បានលាភ, ប្រទះលើលាភ...។

ឧទាហរណ៍ ទី ១៦២

យប់មិញខ្ញុំយល់សប្តិឃើញគេលាបប្រេងឲ្យ ព្រឹកឡើងស្រាប់តែមានលាភ បានស្លឹកលៀប ១ ជុំមកធ្វើអន្ទក់ ។

www.budinst.gov.kh www.elibraryofcambodia.org

## " លិច, លេច "

១៦២- លិច (កិ.) លិចចុះបាត់ទៅ, ចូលកប់បាត់ទៅក្នុងទឹកជាដើម : ទូកលិច, សំទូងលិចទឹក, បន្ទាមុគលិច; អស្តង្គត : ព្រះអាទិត្យលិចបាត់ ។

១៦៤- លេច (កិ.) ចេញពីទីកំបាំង : ស្រាប់តែលេចពីក្នុងព្រៃមក, ព្រះចន្ទ្រលេចឡើង; សៀនចេញឬទុលចេញ : គ្រាប់ឈើដុះលេចពន្លក; ផ្កាយឬចេញ, ផ្សាយចេញ : លេចដំណឹង, លេចសំដី, ទឹកលេចពីក្អម...

១៦៣- លេច (ន.) ឈ្មោះដំបៅមួយយ៉ាងកើតនៅបាតជើង ឬកែងជើង សៀនសាច់ចេញមក : ដំបៅលេច ។

ឧទាហរណ៍ ទី ១៦៣

*ព្រះអាទិត្យលិចទៅ ព្រះចន្ទ្រលេចឡើង ។*

## " លួង, ហ្លួង "

១៦៤- លួង (កិ.) ពោលពាក្យទន់ផ្អែមសម្រួលចិត្តអ្នកដទៃ ឲ្យធូរឲ្យស្រួល : ម្ដាយលួងកូន, លួងលោម... ។

១៦៤- ហ្លួង (ន.) ព្រះរាជា : ហ្លួងស្ដេចចេញពីព្រះរាជដំណាក់, ពាក្យផ្ដើមហៅសម្ដេចព្រះអគ្គមហេសី ឬសម្ដេចព្រះមហាឧបរាជផងក៏បាន : ហ្លួងស្រី ហ្លួងឧបរាជ; ហៅនន្ទរស័ក្តិ ឬបណ្ដាស័ក្តិ មន្ត្រីថ្នាក់តូចជាងទីព្រះ ធំជាងទីឃុន : ហ្លួងសេនារក្ស...។

ឧទាហរណ៍ ទី ១៦៤

*ហ្លួងស្ដេចយាងទៅកាន់ដំណាក់ហ្លួងស្រី ដើម្បីលួងលោមព្រះរាជបុត្ររបស់ហ្លួងឧបរាជ ។*

www.budhist.gov.kh www.elibraryofcambodia.org

## "លេង, លែង"

១៦៤– លេង (កិ.) ប្រព្រឹត្ត អំពើជាល្បែង, ប្រព្រឹត្តក្នុងល្បែងកំសាន្តចិត្ត : លេងសី, លេងចត្រង្គ...; សម្រេចកិច្ចឬប្រព្រឹត្តបែបបទ ដោយកំសាន្តសប្បាយ មិនយកជាការមែន : និយាយលេង, ដើរលេង, ដេកលេង, ស៊ីលេង, អង្គុយលេង...។

១៦៥– លែង (កិ.) ឈប់, លើកឈប់ធ្វើ, មិនរវល់, លះស្រឡះ មិនត្រូវការ : លែងឡូ, លែងចោល, លែងធ្វើ, លែងយក, លែងប្រពន្ធ... ។

ឧទាហរណ៍ ទី ១៦៥

*អ្នកឯងលេងអាក្រក់យ៉ាងហ្នឹង ខ្ញុំលែងលេងជាមួយទៀតហើយ ។*

## "លោត, លោទ"

១៦៦– លោត (កិ.) ស្ទុះឡើងលើផុតពីទីប្រក្រតី : លោតកន្ត្រៃ; ស្ទុះផ្លោះរំលង : លោតរំលង... ។

១៦៦– លោទ (ន.) ឈ្មោះឈើមួយប្រភេទ សំបកក្រាស់ស្រដៀងនឹងគគិត ស្លឹកស្រដៀងនឹងត្រើង តែមានរសជូរ : ស្លឹកលោទ, ស្ងោរស្លឹកលោទលាងសំពត់ ។

ឧទាហរណ៍ ទី ១៦៦

*ស្វាលោតពីដើមលៀប ទៅស៊ីស្លឹកលោទ – ឆ្អែតស៊ីហើយលោតមកដេកលើដើមលៀបវិញ ។*

www.budinst.gov.kh www.elibraryofcambodia.org

"រ, ររ"

១៦៧– រ (ន.) យានមួយយ៉ាងមានរ៉ៃ្ត មាននុស្សសែង : ជិះរ, រមាស. (ច្រើនប្រើក្នុងមជ្ឈិមប្រទេស) ។

១៦៧– ររ (កិ.) ទាស់ការ, ទាស់ទំនង : ររហើយ! ររឹក, នាំឲ្យ ររ, កុំររ. រឹករររតិច្រឹប្រូកប្រែបល់ ។

ឧទាហរណ៍ ទី ១៦៧

*អ្នកឯងធ្វើរគេឲ្យខូច តែម្ចាស់គេដឹង ររឹកហើយ! ។*

"វង់, វង្ស"

១៦៨– វង់ (កិ.) ធ្វើឲ្យជារង្វង់, ធ្វើឲ្យមានមណ្ឌលមូល, គួសវាសឲ្យមូល : វង់ភ្នែកក្លោក, វង់វៀន, ឈរវង់...។

១៦៨– វង់ (ន.) មណ្ឌលមូល, ទីមានមណ្ឌលមូល, អ្វីៗ ដែលមានមណ្ឌលមូល : វង់ទេ, វង់ចិញ្ចៀន...។

១៦៨– វង្ស (ន) ពូជ, ចំបូរ, ផ្លូវ, ក្រសែ, រជា, ត្រកូល, តំណត្រកូល : វង្សត្រកូល, ពុទ្ធវង្ស, វង្សានុវង្ស...។

ឧទាហរណ៍ ទី ១៦៨

*អ្នកលេងក្មេងមួយវង់នេះ សុទ្ធតែជាវង្សានុវង្សរបស់ខ្ញុំ ។*

www.budinst.gov.kh www.elibraryofcambodia.org

# "វដ្ដ, វត្ត, វត្សរ៍, វ័ធ, វាត់"

១៦៩– វដ្ដ (គុ.) ដែលវិល; មូល, ដែលដារង់មូល : សង្សារវដ្ដ ; ច្រើន រៀងខាងដើមសព្ទដទៃ : វដ្ដទុក្ខ...។

១៦៩– វត្ត (ន.) ការប្រព្រឹត្ត, សេចក្ដីប្រតិបត្តិ, មុខការ, កិច្ចដែលគួរធ្វើ; សណ្ដាប់ធ្នាប់ : មនុស្សមានវត្ត, សិស្សបកវត្តគ្រូ, ទីដែលមានវត្តប្រតិបត្តិ : វត្តលោក, សាលាវត្ត, ឲ្យកូននៅវត្ត...។

១៦៩– វត្សរ៍ (ន.) ឆ្នាំ : មៀវត្សរ៍ គឺប្រាក់រង្វាន់ឆ្នាំ, សតវត្សរ៍ គឺកាល កំណត់មួយរយឆ្នាំ ...។

១៦៩– វ័ធ (កិ.) ដួសក្ដិះខ្លាំងដោយចុងស្នែង : ក្របីវ័ធ រមាំងវ័ធ, គោ វ័ធ, ទន្សោងវ័ធ...។

១៦៩– វាត់ (កិ. ឬ គុ.) រលាស់ចុងឡើង; ដែលរលាស់ឡើង វាត់សន្ទូច, វាយវាត់; សន្ទូចវាត់, អន្ទាក់វាត់, ឈើវាត់... ។

ឧទាហរណ៍ ទី ១៦៩

សត្វទាំងឡាយក្នុងសង្សារវដ្ដ ដែលមានវត្តល្អ នោះតែងបាន សេចក្ដីសុខ ច្រើនឆ្នាំសតវត្សរ៍ មិនដូចជាបុរសដែលក្របីវ័ធ និងអ្នក អង្គុយវាត់សន្ទូចនោះទេ ។

www.budinst.gov.kh www.elibraryofcambodia.org

# " វ័ណ្ឌ = វ័ណ្ណ = វ័ន, វន "

១៧០— **វ័ណ្ឌ** (កិ.) បងព័ទ្ធ, រុំព័ទ្ធ, ព័ទ្ធព័ន្ធ, ព័ទ្ធជុំវិញ, ស្មៀកដណ្ដប់ព័ទ្ធប៉ុង : វ័ណ្ឌសំពត់, វ័ណ្ឌក, វ័ណ្ឌកន្ទប, វ័ណ្ឌពុង, វ័ណ្ឌប៉ុង... ។

១៧០— **វ័ណ្ណ** (ន.) ភាគ, ចំណែក; ការបងព័ទ្ធ; ទង, ក្បួន: វ័ណ្ណពាង, វ័ណ្ណថាំង, ដែកវ័ណ្ណថាឌិប... ។

១៧០— **វន** (ន.) ព្រៃ, ទឹក, ទីនៅ, ទីអាស្រ័យ, ផ្ទះ, ភូមិលំនៅ : សាលវន, វេឡុវន, មហាវន; (ច្រើនរៀងខាងដើមសព្ទដទៃ : វនបាលី, វនប្បទេស... ) ។

ឧទាហរណ៍ ទី១៧០

ខ្ញុំទោមហារនឃើញស្លឹវ័ណ្ណដើមឈើធំៗ ដូចពស់វ័ណ្ឌគា ។

# " វាត, វាទ "

១៧១— **វាត** (កិ.) ធ្វើឲ្យទូលាយ, ឲ្យធំ; ផ្សាយអំណាច : វាតដី, វាតទី, វាតអំណាច... ។

១៧១— **វាទ** (ន.) ពាក្យ, ពាក្យពោល, ពំនោល : វាទប្បដិវាទ វាទានុវាទ, (ខ្មែរច្រើនប្រើភ្ជាប់នឹងពាក្យអាទិ-អាទ្យ ក្លាយជាកិរិយា : វាតអាទិ សំដៅសេចក្ដីថាវាតយកមុខ យកអំណាច ) ។

ឧទាហរណ៍ ទី ១៧១

ខ្ញុំមិនបេះវាទអាទិចនឹងគេទេ សូម្បីគេវាទយកមុខយកអំណាចពីខ្ញុំ ក៏ខ្ញុំមិនវេរស់ ។

www.budinst.gov.kh www.elibraryofcambodia.org

## "ភ, ភរ"

១៧២– ភ (ស.) គេ, ពាក្យសម្រាប់និយាយដំនួសឈ្មោះមនុស្សដែលក្មេងជាង ឬតូចទាបជាង : កូនភឈឺ, យំរកម្ដាយភ, ភធ្វើអ្វី ?...។

១៧២– ភរ (កិ.) លូនដោយប្រែភ : កូនក្មេងភរ, ស្រមោចភរសោរ; ពោះទងចេញ ឬពោះទងគោងចាប់ : ល្ហៅភរ, ត្រឡាចភរឡើងទ្រើង...។

ឧទាហរណ៍ ទី១៧២

ហេតុអ្វីបានជាកូនភយំ? ប្រហែលជាស្រមោចដែលភរសោរលើក្ដារនេះហើយខាំភ ។

## "ភស់, វះ"

១៧៣– ភស់ (កិ.) ស្ទង់ប្រមាណ, ស្ទង់ខ្នាតដោយរង្វាស់ : ភស់ដី, ភស់កំពស់, ភស់វែង...។

១៧៣– វះ (កិ.) ធ្វើឲ្យមានរង្វះ; ពុះ, កាត់ពន្លះឲ្យដាច់ជារង្វះ ឬហែកចេញ : វះង៉ៀត, វះពោះត្រី, គេឲ្យវះរបួស, វះកាត់, វះប្រៀក...។

ឧទាហរណ៍ ទី១៧៣

ម្សិលមិញខ្ញុំទៅភស់ដីស្រែ ឃើញបុះបាតជើងឥតពុំបានសោះ ទាល់តែគេឲ្យវះទើបដកបាន ។

www.budinst.gov.kh www.elibraryofcambodia.org

## " វិច, វេច "

១៧៤– វិច (កិ.) ស្វាញត្រឡប់ចុងភ្លិតមុខចូលមកវិញ: វិចមាត់ដាល វិចដាយកន្ទេល...។

១៧៤– វេច (កិ.) ធ្វើឲ្យដាចង្អៀច: វេចបាយ, វេចសំពាយ, វេចខ្ចប់...។

ឧទាហរណ៍ ទី១៧៤

វេចបាយយកទៅជូនម្ដាយខ្ញុំ ព្រោះគាត់រវល់វិចដាយកន្ទេល ពុំបានដាំបាយ ។

## " វិហា = វេហាស៍, វិហារ "

១៧៥– វិហា (ន.) ស្ថានសួគ៌; អាកាស: ហោះនាវិហា ។

១៧៥– វិហារ (ន.) ការនៅ, លំនៅ; កុដិធំ; ទីវត្ត: សង់វិហារ, បុណ្យឆ្លងវិហារ...; (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១០៥៩) ។

ឧទាហរណ៍ ទី១៧៥

ពួកទេវតាហោះនាវិហាមកប្រជុំស្ដាប់ធម៌ព្រះសម្មុទ្ធក្នុងវិហារជេតពន។

## " ស, សរ "

១៧៦– ស (គុ. ឬ កិ.) ដែលមានសម្បុរដូចសំឡីកប្បាស; ពាក់

www.budinst.gov.kh www.elibraryofcambodia.org

បុះព្រាវ ៗ ដោយស្ម; សំដែងអាការឲ្យឃើញច្បាស់ : ពណ៌ស, សំពត់ស; សត្រី; សសេចក្ដី... ។

១៧៦– សរ (ន.) ព្រួញ, កាំធ្នូ, កាំស្នា : ត្រូវសរ... ។

១៧៦– សរ (កិ.) រឭក, រឭកឃើញ, នឹកឃើញ : សរជាតិ, ព្រះពុទ្ធទ្រង់សរញាណ ។

ឧទាហរណ៍ ទី ១៧៦

ព្រះសម្ពុទ្ធទ្រង់សរញាណ មើលពួកសត្វដែលត្រូវសរ ស្លាប់ដ៏អ៊ឹមសរពេញផែនដី ឃើញថាសត្វទាំងនោះធ្លាប់សត្រី ។

" ស័ក, ស័ក្តិ = សក្តិ, សាក់ "

១៧៧– ស័ក (ន.) កាល, សម័យ; យុគ; ការរាប់លំដាប់ឆ្នាំ, ខ្មែរប្រើពាក្យនេះចំពោះតែរាប់លំដាប់ឆ្នាំតាំងពីទី ១ ដល់ទី ១០ ត្រឡប់សាមករាប់ពីទី ១ វិញគឺរាប់ថា : ឯកស័ក, ទោស័ក, ត្រីស័ក, ចត្វាស័ក, បញ្ចស័ក, ឆស័ក, សប្តស័ក, អដ្ឋស័ក, នព្វស័ក, សំរឹទ្ធិស័ក ។

១៧៧– ស័ក្តិ (ន.) អំណាច, សេចក្ដីអង់អាច, សេចក្ដីក្លាហាន : អ្នកមានស័ក្តិ, ស័ក្តិតូច, ស័ក្តិធំ... ។

១៧៧– សាក់ (ន.) ស្នាមក្បាច់ក្បូរ ឬរូប, យ័ន្ត, អក្សរដែលចាក់នឹងម្ជុល ឬដែកស្រួចបញ្ចូលទឹកខ្មៅឬទឹកក្រហមឲ្យជាប់នៅក្នុងសាច់ : មនុស្សមានសាក់.. ។

www.budinst.gov.kh www.elibraryofcambodia.org

១៧៧— សាក់ (កិ.) ចាក់ដោយម្ជុលឬដែកស្រួច បញ្ចូលទឹកខ្មៅ ឬ ទឹកក្រហមក្នុងសាច់ ឲ្យជិតជាប់ជាក្បាច់ក្បូរជាដើម : សាក់ដៃ, ខ្ញុំសាក់ខ្លួ, សាក់ខ្សួរ...។

ឧទាហរណ៍ ទី ១៧៧

*កាលពីឆ្នាំកេងទោស័ក មានបុរសម្នាក់សាក់ពេញខ្លួន មកពីស្រុក បាសាក់ ជាអ្នកមានស័ក្តិធំ បានបួលមកនៅក្នុងភូមិខ្ញុំ ។*

*"សត្ត = សត្វ, សត្យ = ស័ត្យ, សាត់"*

១៧៨— សត្វ (ន.) បុគ្គលអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ឬក្នុងបំណង ឲ្យលំដឹកដង្ហើម, ជីវិត, ប្រាណ : សត្វលោក, សត្វគោ, សត្វស្វាប, សត្វចតុប្បាទ...។

១៧៨— ស័ត្យ (ន.) សេចក្តីពិត, ដំណើរទៀង, ទៀងទាត់, ការមែន, ប្រាកដ : និយាយដោយស័ត្យ ដោយធម៌, តាមស័ត្យ តាមធម៌...។

១៧៨— ស័ត្យ (គុ.) ដែលទៀង, ទៀងត្រង់, ពិត, ប្រាកដ, មែន : ពាក្យស័ត្យ, ពាក្យសង្ឃពាក្យស័ត្យ...។

១៧៨— សាត់ (កិ.) បើុង, ហើរតាមខ្យល់ ឬអណ្តែតតាមខ្សែទឹក: សាត់ព្រាត់, សាត់អណ្តែត...។

ឧទាហរណ៍ ទី ១៧៨

*មនុស្សសត្វក្នុងលោក បើមានពាក្យស័ត្យជួបពោធិសត្តកាលជា ព្រះពុទ្ធ មិនសាត់អណ្តែតទៅកាន់ទុក្ខលំបាកឡើយ ។*

www.budinst.gov.kh www.elibraryofcambodia.org

## " ស័ង្ខ, សាំង "

១៧៩- ស័ង្ខ (ន.) ខ្យងសមុទ្រមួយបែប តូចស្រួច មានស្នាមវិលស្រួល សម្បុរស: ជាវត្ថុរវង្គស័ង្ខ, ស្រោចទឹកភ្ញស់ទឹកស័ង្ខ; ឈ្មោះសាភាយសមុទ្រមួយប្រភេទដើមល្អិតល្វន់ សម្បុរស: សាភាយស័ង្ខ ។

១៧៩- សាំង (គុ.) ដែលមិនផ្លាង, មិនឆ្អើល, ដែលងាយឲ្យហាប់ឲ្យកាន់: មាត់សាំង, សេះសាំង, ដំរីសាំង .. ។

ឧទាហរណ៍ ទី ១៧៩

ខ្យងស័ង្ខជាសត្វសាំងកន្ត្រើ, គេយកសាច់វាញុាំទឹកសាភាយស័ង្ខ, ដាក់ម្ជូរគ្រឿងសាំង ។

## " សប់, សព, សព្វ "

១៨០- សប់ (កិ.) ស្លូបដោយស្នប់, ទាញរុញដៃស្នប់រឿយៗ ឲ្យផាយខ្យល់: សប់ចង្កៀង, សប់ទឹក... ។

១៨០- សព (ន.) ខ្មោចស្រស់, រូបបុគ្គលស្លាប់, សាកខ្មោច: បូជាសព, លោកគ្រូព្រះសព .. ។

១៨០- សព្វ (គុ. ឬ កិ. វិ.) ទាំងពួង, ទាំងអស់, ទាំងមូល, ទាំងស្រុង, ទាំងគ្រប់, គ្រប់, ទូ, ទូទៅ, រាល់: បេះសព្វ, ដឹងសព្វ, សព្វកាល, សព្វសរពើ... ។

ឧទាហរណ៍ ទី ១៨០

តាំងពីខ្ញុំបានគប់ប្រសព្វធីលោកគ្រូព្រះសពខ្ញុំនៅវត្តព្រែកប្រសព្វ ឃើញថាលោកគិតប្រសប់ខាងការសប់ចង្កៀងសព្វៗកាល ។

www.budinst.gov.kh www.elibraryofcambodia.org

## " សព្ទ=ស័ព្ទ, សាប់ "

១៨១- សព្ទ (ន.) សូរ, សំឡេង, សំនៀង, ភាសា, ពាក្យ, សំដី, សម្រែក : ឮសូរសព្ទ, ចុះសព្ទ... ។

១៨១- សាប់ (កិ.) កាប់ចិញ្ច្រាំស្រាលៗ ញាប់ៗ ឲ្យជាប់ជាបំណែកតូចៗ ស្ដើងៗ : សាប់ល្ពុង, សាប់ស្វាយ, សាប់ពាសក់; អំបូរថែវទូកញាប់ៗ : សាប់ច្រវា, សាប់ចែវ ។

ឧទាហរណ៍ ទី១៨១

*ខ្ញុំកំពុងតែអង្គុយសាប់ពាសក់ ស្រាប់តែឮសូរស័ព្ទមាត់គេហៅក្រៅៗ, មើលទៅឃើញគេប្រណាំងទូកកំពុងសាប់ចែវញាប់ស្អេក ។*

## " សា, សារ "

១៨២- សា (ន. ឬ កិ.) ស្រូវឬដំណាំពូកខ្លះ ដែលដុះលូតលាស់គពីគល់ចាស់ ឬពីដញ្ចាំងស្រស់ : សាស្រូវ, សាឪឡឹក; ប្រើដូចជាគុណកិរិយា; ស្រូវសា, ឪឡឹកសា, និយាយបែកសា, សាសំពត; (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១១៧៦) ។

១៨២- សារ (ន. ឬ គុ.) ខ្លឹម; សេចក្ដីខ្ជាប់ខ្ជួន, មាំមួន, រឹងប៉ឹង, ការសំខាន់ : ខ្លឹមសារ, សំដីឥតសារ, ផ្ញើសារ; ដំរីស្ទា ឬដំរីមានភ្លុកធំ : ដំរីសារ (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១១៩១) ។

ឧទាហរណ៍ ទី១៨២

*ខ្ញុំសាសំពត់ហើយ ទៅច្រូតសាស្រូវឲ្យដំរីសារស៊ី ពុំតែមាត់អ្នកនាំសារ និយាយបែកសាឥតខ្លឹមសារសោះ ។*

www.budinst.gov.kh www.elibraryofcambodia.org

## " សាស្ត្រ, សាសន៍ "

១៨៣– សាស្ត្រ (ន.) គម្ពីរ, ច្បាប់, ក្បួន; តម្រា, វិជ្ជា, ការសិក្សា, ពាក្យណែនាំ, ពាក្យពន្យល់, ពាក្យបង្គាប់ : ប្រវត្តិសាស្ត្រ, វិទ្យាសាស្ត្រ, សិល្បសាស្ត្រ... ។

១៨៣– សាសន៍ (ន.) ពាក្យបណ្ដាំ, ពាក្យផ្ដាំផ្ញើ, ពាក្យប្រៀនប្រដៅ, សាសនា, លទ្ធិ : ពុទ្ធសាសន៍, កុលសាសន៍, សាសន៍ព្រាហ្មណ៍... ។

ឧទាហរណ៍ ទី ១៨៣

*មានសាសន៍ព្រាហ្មណ៍ម្នាក់ចេះប្រវត្តិសាស្ត្រយ៉ាងជំនាញ បាន ចូលមកកាន់ពុទ្ធសាសន៍ នាំទាំងសាសន៍ជាច្រើនចូលទៀតផង ។*

## " សិង, សិង្ហ, សឹង "

១៨៤– សិង (កិ.) ដេក: ខ្មែរប្រើចំពោះតែជាសមណស័ក្តិ : លោកសិង, ក្រោកពីសិង ។

១៨៤– សិង្ហ (ន.) សីហៈ ឬគោ; អ្នកខ្លះយល់ថាសិង្ហដោយខ្លួន គោដោយខ្លួន ប្អូនកាលហៅរួមថាសិង្ហគោ យល់ថាមិនមែនទីទៃពីគ្នា : សត្វសិង្ហ, គោសិង្ហ ។

១៨៤– សឹង (ទ.) រកកល់, រកកល់នឹង, ស្ទើរនឹង : ដូច្នេះវិញក៏សឹងបាន, ទៅរៀនទៀតក៏សឹងបាន... ។

ឧទាហរណ៍ ទី ១៨៤

*អាត្មាមិនយល់ចិត្តហាក់ដូចជាយល់សព្វ ឃើញគោសិង្ហ, ក្មេងរៀនគ្រូសួរ, ទីនជាតែយល់សព្វដូច្នេះវិញក៏សឹងបាន ។*

www.budinst.gov.kh www.elibraryofcambodia.org

## " សិរ = សិរស៍ = សិរ្ស = សិរ្ស, សេ "

១៨៥- សិរ (ន.) ក្បាល (រាជស័ព្ទ) : ព្រះសិរ, រងព្រះសិរ; កំពូល, ចុងខ្ពស់, ចុងប្ញូច; ខ្មែរហៅសាច់ដុះជាពក ឬជាបន្ទះលើក្បាលសត្វពួកខ្វះ មាន់មានដើមថាសិរដែរ : សិរមាន់...។

១៨៥- សេ (កិ.វិ.ម្ភុត.) សិញ, ស្អេក, ស្អេកស្កះ : ដើរញាប់សេ, ញាក់សេ; ដំណើរសេ...។

ឧទាហរណ៍ ទី ១៨៥

មាន់គកខ្ញុំមួយមានសិរខ្ពស់, មាន់នេះដើរលឿនណាស់ ដំណើរញាប់សេ ។

## " សិល្ប = សិល្ប៍, សីល "

១៨៦- សិល្ប៍ (ន.) សិប្បៈ : រៀនសិល្ប៍, អ្នកសិល្ប៍, សិល្ប៍-សាស្ត្រ; ខ្មែរហៅសំដៅមនុស្សក្បត់ផែនដី ដែលប្រកាសខ្លួនថាជាអ្នកខ្លាំងពូកែ ។

១៨៦- សីល (ន.) វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តិល្អដោយកាយវាចា មិនប្រព្រឹត្តកន្លងសិក្ខាបទឬវិន័យបញ្ញត្តិ : រក្សាសីល, សីល ៥ សីល ៨...។

ឧទាហរណ៍ ទី ១៨៦

ខ្ញុំរក្សាសីល ៥សីល ៨ មកយូរហើយ ឲ្យខ្ញុំទៅធ្វើជាអ្នកសិល្ប៍ដើររបាំនអ្នកគងទៃពុំសមទេ ។

www.budinst.gov.kh www.elibraryofcambodia.org

## " សុក, សុក្រ, សុខ "

១៨៧– **សុក** (ន.) អាការៈមួយយ៉ាងជាស្រោមស្រោបកូន ដែលនៅក្នុងផ្ទៃម្ដាយ ក្នុងពោះមេ : សុកមនុស្ស, សុកគោ, សុកក្របី... ។

១៨៧– **សុក្រ** (ន.) ឈ្មោះផ្កាយទី ៦ គឺផ្កាយប្រចាំទិប ឬផ្កាយព្រឹក : ផ្កាយសុក្រ; ឈ្មោះថ្ងៃទី ៦ : ថ្ងៃសុក្រ... ។

១៨៧– **សុខ** (គុ. ឬ ន.) ដែលសប្បាយ, ងាយ, ស្រួល; សេចក្ដីសប្បាយ, ដំណើរងាយ, ដំណើរស្រួល : មានសុខ, បានសុខ... ; (ចូរមើលក្នុងវចនានុក្រម ភាគ ២ ទំព័រ ១២២១) ។

ឧទាហរណ៍ ទី ១៨៧

*កូនកើតថ្ងៃសុក្រ តាមចំណាំថាឲ្យយកសុកទៅកប់នៅទិសខាងកើត ដើម្បីឲ្យបានសេចក្ដីសុខ ។*

## " សូ, សូរ, សូរ្យ, សូល៍ "

១៨៨– **សូ** (ន.) ខ្សែមាសឬខ្សែប្រាក់ មានសណ្ឋានជាប្រវាក់ : ខ្សែសូ, សូមាស, សូប្រាក់... ។

១៨៨– **សូរ** (ន. ឬ គុ.) ស័ព្ទ, សំឡេង; ក្លៀវក្លា, អង់អាច, ក្លាហាន, អាចហាន; ដែលមានចិត្តមុះមុត : សូរភ្លេង, សូរផ្គរ, សូរសីហនាទ, សូរសៀង... ។

១៨៨– **សូរ្យ** (ន.) ព្រះអាទិត្យ : សូរ្យសែង, សូរ្យគ្រាស, សូរ្យរស្មី ។

www.budinst.gov.kh www.elibraryofcambodia.org

១៨៨- ស្ងួល (ន.) ពេបឺឬដែកមូលវែងស្រួចខាងចុង , ឈើ អណ្ដោត : ឈើស្ងួល, ដែកស្ងួល...។

ឧទាហរណ៍ ទី ១៨៨

កាលពីព្រេងនាយ មានទេវតាម្នាក់ពាក់ខ្សែស្ងួ មានពន្លឺក្លៀបេញ ពីកាយដូចស្ងួរស្ងែង កាន់ឈើស្ងួលហោះនាអាកាស ស្រែកព្រៀន បញ្ចេញសូរសៀងជិតកោះ ហាក់ដូចជាស្ងួរផ្សួរផ្ទុំ ។

"ស្ងួ, ស្ងួរ, ស្ងួគិ"

១៨៩- ស្ងួ (កិ.) ដើរលើស្ងួ ឬលើអ្វីៗ ដែលមានគ្រៀងពោងផង : ស្ងួស្ងួ, ស្ងួស្ពាន, ស្ងួមែកឈើ...។

១៨៩- ស្ងួរ (កិ.) ពោលពាក្យឆ្ពោះទៅរកអ្នកដទៃឲ្យគេឆ្លើយតប ឲ្យគេប្រាប់ : ស្ងួរដំណឹង, ស្ងួរនាំ...។

១៨៩- ស្ងួគិ (ន.) ទេវលោក, លោកទិព្វ, ស្ថានទេវតា : ស្ថានស្ងួគិ, ទៅស្ងួគិ, ផ្លូវស្ងួគិ...។

ឧទាហរណ៍ ទី ១៨៩

មានតាព្រឹទ្ធាចារ្យម្នាក់ស្ងួរថាខ្ញុំ, សំដីគាត់រវើររវាមមើលតែគេស្ងួ រនោចបាក់, ស្ងួរយ៉ាងហ្នឹង ព្រះឥន្ទ្រទៅស្ថានស្ងួគិកំដ្រើមាតុំរូប ។

"សេក, សេក្ខ=សេខ"

១៩០- សេក (ន.) បក្សីពួកមួយសម្បុរបៃតងចំពុះខ្ទឹបខុប : សត្វសេក, សេកយារ, សេកសោម, សេកអាត់, សេកក្រិស...។

www.budinst.gov.kh www.elibraryofcambodia.org

១៩០— សេក្ខ (ន.) អ្នកដែលនៅកំពុងសិក្សា, អ្នករៀន; ខ្មែរបុរាណហៅក្មេងដែលនៅរៀនអក្សរក្នុងវត្ត : សេក្ខលោក, កូនសេក្ខលោក ។

ឧទាហរណ៍ ទី ១៩០

កាលពីខែមុន ខ្ញុំបានឃើញសេក្ខលោកម្នាក់ ជាប់បានសេកសោមពីរ ដែលកំពុងសសិតស្លាបលើមែកត្រសេក ។

" សៅ, សៅរ៍ "

១៩១— សៅ (គុ.) ដែលមានសម្បុរមិនបរិសុទ្ធ, ដែលអន់ឬខូចសម្បុរ : សម្បុរសៅ, សៅសម្បុរ... ។

១៩១— សៅរ៍ (ន.) ឈ្មោះផ្កាយនព្វគ្រោះទី ៧ : ផ្កាយសៅរ៍; ឈ្មោះថ្ងៃទី ៧ នៃសប្តាហ៍ : ថ្ងៃសៅរ៍ ។

ឧទាហរណ៍ ទី ១៩១

កាលពីថ្ងៃសៅរ៍ ខ្ញុំទៅលេងស្រុកស្រែ ឃើញមនុស្សម្នាក់ឈ្មោះសៅរ៍ កំពុងស្ទូចត្រីកណ្តាលថ្ងៃក្តៅសៅសម្បុរអស់ ។

" សំណុស, សំណុះ "

១៩២— សំណុស (ន.) អ្វីៗដែលសុស, ដែលអប់រសជាតិ : សំណុសឱស, សំណុសឃ្មុំ... ។

១៩២— សំណុះ (គុ.) ដែលបុះតាមទឹកស្រែក : ត្រីសំណុះ ត្រីដែលបុះតាមទឹកស្រែក, អ.ណើកសំណុះ ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៩២

មរិលមិញ ខ្ញុំទៅចាប់ត្រីសំណុះឯចុងព្រែក ត្រឡប់មកវិញរើស បានសំណុលឃុំមួយ ។

" សំរិត = សម្រិត, សំរឹទ្ធ = សំរឹទ្ធិ "

១៩៣- សំរិត (គុ.) ដែលស្រិតរួចហើយ : អង្ករសំរិត...។

១៩៣- សំរិត (កិ.) ធ្វើឲ្យស្អាត, ឲ្យបរិសុទ្ធ; សិតទឹក ឬដាត់ទឹក សម្រេងមិនឲ្យដោយកករជាដើម : សំរិតទឹក, សំរិតប្រេង, សំរិតស៊ាំង... ។

១៩៣- សំរឹទ្ធ (ន.) សេចក្ដីសម្រេច, សេចក្ដីចំរើន, ការលូតលាស់ ឱ្យះធាល, ផលសម្រេច; វត្ថុហៅលោហធាតុមួយប្រភេទ កើតអំពីការលាយផ្សំលោហធាតុផ្សេងៗ មានដែកស្ពាន់ជាដើម : ព្រះសំរឹទ្ធិ, ផ្តិលសំរឹទ្ធ; ថាសសំរឹទ្ធ... ។

ឧទាហរណ៍ ទី ១៩៣

ខ្ញុំចុកអង្ករសំរិត ខំសំរិតស៊ាំងបានមួយផ្តិលសំរឹទ្ធ ទុកយកទៅចូលបុណ្យទីនគេ ស្រាប់តែមិញ ផ្កាស៊ុបហ្វុត ពុំសំរឹទ្ធដូចប្រាថ្នាសោះ ។

" ស្កា, ស្ការ "

១៩៤- ស្កា (ន) ឈ្មោះល្បែងមួយយ៉ាង ពួកចត្រង្គ គេមានមេតីរហៅថាតៅ មានសណ្ឋាន ៤ ជ្រុង មានរន្ធ ៦ សម្រាប់លើកទម្លាក់លើក្ដារ, មានកូន ២៤ ឬ៣០ : ល្បែងស្កា, លេងស្កា; (ក្លាយមកពីបាស្កា)...។

១៩៤- ស្ការ (ន.) សត្វចតុប្បាទពួកមួយ មុខស្រួចដូម ជើងខ្លីៗ សម្បុរត្នោត, ស្រដៀងនឹងសំពោច, ជាពួករន្ធកសត្វ : សត្វស្ការ...។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ១៩៤

កាលខ្ញុំទៅលេងស្ដាណាចមិញ ឃើញស្ការកំពុងកន្ទុយមួយពេកកាត់មុខ ។

"ស្កា, ស្ការ"

១៩៥- ស្គា (ន.) ឈ្មោះស្មៅមានដើមរឹង, មានពីរយ៉ាងគឺ ស្គាក្រអូប, ស្គាធំ ឬស្គាព្រៃ...។

១៩៥- ស្គារ (គិ.) ធ្វើមេចុំនសេរិន: (បំពោះតែខាងសត្វ ឬទីយជាតិ): ពស់ស្គារញ្ញា, អន្លង់ស្គារញ្ញា ... ។

ឧទាហរណ៍ ទី ១៩៥

ព្រឹកមិញខ្ញុំឃើញពស់ស្គារញ្ញា ក្បែរគុម្ពស្គាខាងកើតភូមិ ។

"ស្គុស, ស្គុះ"

១៩៦- ស្គុស (គុ.) សប្បាស់, សក្បុស, សសុទ្ធ: សំឡីសស្គុស; ប្រើភ្ជាប់នឹងពាក្យស្គាយក៏មាន: ស្គុសស្គាយ ។

១៩៦- ស្គុះ (ន.) ឈ្មោះស្គន់មួយប្រភេទ ដើមសណ្ឋានជាជ្រុង ៗ មានឫសត្រង់ថ្នាំង ប្រើជាបន្លែ ឬជាអន្លក់បាន : អន្លក់ស្គុះ ហៅថាស្គន់ស្គុះក៏បាន...។

ឧទាហរណ៍ ទី ១៩៦

សំពត់នេះសស្គុស ដូចជាឫសស្គន់ស្គុះ នៅក្រពាំងជិតភូមិស្គុះ ។

www.budinst.gov.kh www.elibraryofcambodia.org

"ស្និត. ស្និទ្ធ"

១៩៧– ស្និត (ន.) ប្រដុំឫសលំផ្ទៃចេក ដែលនៅជាប់នឹងស្នូង ឬ ដែលពន្លះចេញពីស្នូងមកមិនឲ្យរបេះដាច់ពីគ្នា : ចេកមួយស្និត; ក្រាសស្និតសក់មួយយ៉ាង មានធ្មេញទាំងពីរខាង ស្និតញឹកជិត : ស្និតសិតសក់...។

១៩៧– ស្និទ្ធ (គុ. ប្តុក. ប្តុក. វិ.) ដែលជាទីស្រឡាញ់, ជាទី ពេញចិត្ត; ស្និត, ខាប់, ធ្លាញ់, ស្និតល្អ, ស្រឡាញ់ស៊ប់, ទុកចិត្តស៊ប់ : ខ្ញុំមិនសូវ ស្និទ្ធនឹងគេទេ, បរិភោគស្និទ្ធ, ស្និទ្ធស្នាល ស្នេហ៍ស្និទ្ធ...។

ឧទាហរណ៍ ទី ១៩៧

សំឡាញ់ខ្ញុំរកស៊ីចេកមួយកស់មួយស្និត ដែលមានផ្លែញឹកដូចស្និត សិតសក់, ចំណែកខ្ញុំខ្វល់មានពុំស្និទ្ធទេ ព្រោះខ្លាចឈឺពោះ ។

"ស្មើ. ស្មើរ"

១៩៨– ស្មើ (កិ.) សួរឲ្យដឹងសិន, ពិគ្រោះឬប្រឹក្សាមុនសិន : ស្មើ ការ, ទូលស្មើ...។

១៩៨– ស្មើរ (ន.) ស្រទាប់, សង្កាត់ដែលកើឡើងជាន់ដោយងាយ : ស្មើរមួ, ស្មើរក្រដាស, វត្តស្មើរ ។

ឧទាហរណ៍ ទី ១៩៨

កាលខ្ញុំទៅស្មើការនឹងលោកយាយគ្រែ, ឃើញថែពន្លោកពិសា មួយយាំពេចអស់ចំស្មើរ ។

www.budinst.gov.kh www.elibraryofcambodia.org

## " ស្រាប, ស្រាពណ៍ "

១៩៩- ស្រាប (ន.) ជើងពានមានមាត់ជែកៗ ឬផារំពត់ក្របាប់ៈ ជើងស្រាប, ពារីមួយស្រាប ...។

១៩៩- ស្រាពណ៍ (ន.) ឈ្មោះខែទី៩នៃចន្ទគតិៈ ខែស្រាពណ៍។

ឧទាហរណ៍ ទី ១៩៩

*ស្រាបដែលដាក់ពារីនេះ មិនមែនមានស្រាប់ទេ, ស្រាបនេះខ្ញុំទិញ ឆ្នាំទៅហើយដែរ ទិញតាំងពីខែស្រាពណ៍ ឆ្នាំមុនម្ល៉េះ ។*

## " ស្រាស់, ស្រះ "

២០០- ស្រាស់ (កិ.) បិទ. បាំង, រាំងដោយសម្រាស់ៈ ស្រាស់របង, ស្រាស់ប្រឹកៈ (ពាក្យបុរាណថា : ដាក់ទ្រូស្រាស់បន្លា អារសាប់ដូចខ្លាទើបនៅស្រុកបាន) ...។

២០០- ស្រះ (ន.) ទីដក់ទឹកធំ ដែលកើតពីជីក ឬកើតឯងក៏មានៈ ជាតស្រះ, ស្រះបោក្ខរណី, ស្រះស្រង់ ... ។

ឧទាហរណ៍ ទី ២០០

*បើចង់ឲ្យទឹកស្រះថ្លាល្អ ត្រូវស្រាស់របងព័ទ្ធជុំវិញ កុំឲ្យគោក្របីដាដើមចូលបាន ។*

www.budinst.gov.kh www.elibraryofcambodia.org

## "ស្រុស, ស្រុះ"

២០១— ស្រុស (កិ.) ដាក់របស់ស្រស់នៅក្នុងទឹកកំពុងពុះឬទឹកក្ដៅ មិនឲ្យយូរហួសប្រមាណ : ស្រុសអន្ទក់ស្ងោ... ។

២០១— ស្រុះ (កិ.វិ.ឬគុ.) ដែលព្រមព្រៀងគ្នាឥតខុសទាក់, ដែលស្រាក់ស្រទេញព្រមៗគ្នា : ធ្វើការស្រុះគ្នា, ស្រុះស្រួល, ស្រុះដៃ, ស្រុះសំដី... ។

ឧទាហរណ៍ ទី ២០១

*ពួកពិសេសស្រុះគ្នាណាស់ ខ្លះដាំបាយ ខ្លះចិតបន្លែ ខ្លះស្រុសអន្ទក់ ។*

## "ស្រែស, ស្រែះ = ស្រេះ"

២០២— ស្រែស (គុ.) ស្រួយខ្លាំង, ស្រួយក្រៃពេក : ស្រួយស្រែស, សំដីស្រួយស្រែស ។

២០២— ស្រែះ (កិ.ឬគុ.) បាក់បេសប្រទាក់ធ្លាក់ញឹកដាក្រឡាស្អិតៗ : ស្រេះសំពត់, បំពាក់បាក់ស្រែះ ; អាវស្រែះ, កន្សែងស្រែះ, ផ្សិតស្រែះគឺផ្សិតដែលពុល ។

ឧទាហរណ៍ ទី ២០២

*ខ្ញុំមានកុយម្នាក់សំដីស្រួយស្រែស ប៉ុនប្រមប់មានវិធីដេរបាក់ មានស្រេះសំពត់អាវងាដើម, ការស្រេះស្រោមនាលិកាល្អដូចផ្សិតស្រេះ ។*

## "ស្មេស្មុ = ស្មេស្មុ, ស្មេះ = ស្មែះ"

២០៣— ស្មេស្មុ (ន.) ទឹករំអិលដែលចេញមកតាមបំពង់ក : ស្មេស្មុការ, ស្មេស្មុខាប់, ធ្លាក់ស្មេស្មុ... ។

www.budinst.gov.kh www.elibraryofcambodia.org

២០៣- ស្ងែះ (កិ.) ឈប់បង្អង់ទុកដោយខ្សែក ឬដោយអនេ្ទើសិន: ស្ងែះទុកសិន, ស្ងែះតែប៉ុណ្ណេះ, ស្ងែះទុកដោយខ្សែក...។

ឧទាហរណ៍ ទី២០៣

ស្ងែះរឿងក្ដីនេះទុកសិន ព្រោះខ្ញុំទេវតែឆ្ពាក់ស្ទស្ទ និងនិយាយឲ្យបចប់ពុំបាន ។

## "ហត្ថ, ហាត់"

២០៤- ហត្ថ (ន.) ដៃ, ប្រវែងមយដំរី, ផ្នូងសក់ : ប្រវែងមួយហត្ថ ហត្ថក្រពុំ, ហត្ថដាងឈើ; (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១៣៧១) ។

២០៤- ហាត់ (កិ.) ធ្វើឲ្យជំនាញ, រៀនឲ្យស្ទាត់, ហ្វឹក : ហាត់សរសេរ ហាត់មើល, ហាត់ប្រាណ...។

ឧទាហរណ៍ ទី ២០៤

មានឧបាណពម្នាក់ហាត់លោត បានកំពស់ប្រាំហត្ថ ។

## "ហា, ហារ"

២០៥- ហា (កិ.) របើកហើបក្របហឡើង, ធ្វើឲ្យរបើកហើបឡើង, ហើបមាត់ប្រហាឡើង : ហាមាត់, មនុស្សហាមាត់, ក្រពើហា...។

២០៥- ហារ (គុ.) ដែលរបើកហើបឡើង, ដែលប្រេះហើបប្រហ : សៀសហាលខ្ទេហា, ផ្លែសំរោងទុំប្រេះហា, ក្ដាររបើកហា...។

www.budinst.gov.kh www.elibraryofcambodia.org

២០៥- ហារ (ន. ឬ កិ.) ការនាំយកអ្វីៗទៅ, អ្វីៗដែលល្មមនាំយកទៅបាន; ខ្សែជាគ្រឿងប្រដាប់ក; ចែក, បែងជាចំណែក, រកឱ្យឃើញជាចំណែក (ពាក្យប្រើក្នុងក្បួនគណិត) : ហារលេខ, លេខហារ, កែវមុក្តាហារ ឬ មុក្តាហារ... ។

ឧទាហរណ៍ ទី ២០៥

មាននារីម្នាក់ពាក់កែវមុក្តាហារ បេះលេខហារយ៉ាងជំនាញ និយាយអ្វីប្រើនហាមាត់ធំៗ ដូចក្រពើហា ។

" ហៀ, ហៀរ "

២០៦- ហៀ (គុ.) ស្ទើងណាស់ : ស្ទើងហៀ...។

២០៦- ហៀរ (កិ. ឬ គុ.) កំពប់ហូរចេញព្រោះពេញខ្លាំងហួសប្រមាណ : ហូរហៀរ, ទឹកហៀរភ្នែ, សំបោរហៀរ, ហៀរតាមមាត់...។

ឧទាហរណ៍ ទី ២០៦

ចិត្តទ្រទង់ស្ទើងហៀយ៉ាងហ្នឹង មុខជាទឹកភ្នែកហូរហៀរលិចស្រូវអស់ជាពុំខាន ។

" ហោ, ហោរ "

២០៧- ហោ (កិ.) ខ្ទប់ដោយក្រដាសជាកញ្ចប់ខ្ពស់ប្រវែងឬជាកងបួនជ្រុង : ហោស្លា : ហោសព គឺ រុំសពឥស្សរជនទាំងឡាយ មានក្សត្រជាដើម ។

២០៧- ហោ (ន.) កញ្ចប់ដែលខ្ទប់ជាកងប្រវែងឬកងបួនជ្រុង : ឈើគូសមួយហោ, អំបោះមួយហោ...។

www.budinst.gov.kh www.elibraryofcambodia.org

២០៧- ហោ (គុ.) ដែលមានសាច់ហ៊ោងឬផ្ទៃញខ្វះដោយអន្ទើមិនរាបស្មើ: ដើរប្រយ័ត្នកុំឲ្យហោ, សំពត់ឡើងសាច់ហោ...។

២០៧- ហោរ (ន.) អ្នកចេះហោរាសាស្ត្រ ឬអ្នកចេះតារាសាស្ត្រ: ក្បួនហោរ, ទំនាយហោរ...។

ឧទាហរណ៍ ទី ២០៧

ស្អែកខ្ញុំគិតយកឈើគូសមួយហោ ទៀនមួយគូទៅរកហោរមើលគូព្រេងឲ្យកូនខ្ញុំ ។

"អ, អរ"

២០៨- អ (ន.) ឈ្មោះប៉ីមួយយ៉ាងធ្វើដោយដើមបបុស ឬដើមពកៈ ប៉ីអ ។

២០៨- អរ (កិ.) មានអំណរ, មានសោមនស្ស, រីករាយចិត្តៈ ត្រេកអរ, អរគុណ, អបអរ...។

ឧទាហរណ៍ ទី ២០៨

ខ្ញុំត្រេកអរនឹងអ្នកណាស់ ព្រោះអ្នកយកប៉ីអមកឲ្យខ្ញុំ ។

"អក, អក៏"

២០៩- អក (កិ.) ជាប់ចំណីអាហារត្រៀម ផង់ ឬភេសជ្ជៈ ស្ទួតផង់ជាដើម ពេញទូកដៃ ហាមាត់ធំដើយពមៈ អកប្រអូស; អកអំបុក...។

www.budinst.gov.kh www.elibraryofcambodia.org

២០៩— អក (ឧ.) អង្ស៊ុជាតកសត្វមួយប្រភេទ សម្បុរខ្លួនខ្មៅស្រអាប់ មានឆ្អឹងកន្ទុលបន្តិចដាងកុក : សត្វអក; ប្រដាប់សម្រាប់ដាក់កំពោរ : អកកំពោរ ។

២០៩— អករ៍ (ទ.) អ្នកមិនធ្វើការអ្វី, ពាក្យសម្រាប់ហៅស្ត្រីមានអាយុច្រើន ដែលព្រះករុណាជាម្ចាស់ជីវិតទ្រង់ព្រះមេត្តាប្រោស តាំងឲ្យមានយស់ធំដាងយាយចាស់ទាំងពួង : យាយអករ៍, លោកព្រះអករ៍ចមក្សត្រ...; (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១៤២៣) ។

ឧទាហរណ៍ ទី ២០៩

ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់ព្រះរាជតាំងអកកំពោរមាសមួយ ដែលមានរចនាក្បាច់ជារូបសត្វអកដល់លោកព្រះអករ៍ចមក្សត្រ ។

" អង់, អង្គ "

២១០— អង់ (កិ.) រង់, រង់ចាំ, ឈប់ចាំ : អង់បន្តិចសិន, អង់មួយស្របក់, អង់ចាំ... ។

២១០— អង្គ (ន. ម្ក បុ.) តាក់, រូប, ខ្លួន, ទ្រង់, លោក : ព្រះពុទ្ធមង្គ, លោកសង្ឃពីរអង្គ, ល្អអស់អង្គ...; (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១៤៣៨) ។

ឧទាហរណ៍ ទី ២១០

អង់មួយស្របក់សិន ចាំសាមណេរពីរអង្គផង ព្រោះលោកខ្លាចក្មេង ។

www.budinst.gov.kh www.elibraryofcambodia.org

# " អយ៉, អថ៌ "

២១១— អយ៉ (គុ.) ដែលមានដីឡូ, ថ្លៃ, ថ្លៃថ្លា : សម្ដេចព្រះអយ៉អគ្គមហេសី គឺព្រះអគ្គមហេសីថ្លៃថ្លា...; (ប្រើជាអាយ៉អគ្គក៏បាន) ។

២១១— អថ៌ (ន.) អត្ថ : ធម៌អថ៌ គឺធម៌នឹងអត្ថ ឬបាលីនឹងអដ្ឋកថា ឬក៏បាលីព្រមទាំងសេចក្ដីអធិប្បាយ ; (ប្រើក្លាយជាអាថ៌ក៏បាន) ។

ឧទាហរណ៍ ទី ២១១

ព្រះអយ៉អគ្គមហេសីអង្គនេះ ចេះធម៌អថ៌យ៉ាងជំនាញ

# " អ័ព្ទ = អ័ព្រ, អាប់ "

២១២— អ័ព្ទ (ន.) ពពក, ពពកខាប់, មេឃ, មេឃមីរៈ ចុះអ័ព្ទពេញទន្លេ; ប្រើជាពាក្យប្រៀបក៏បាន : ធូលីហុយអ័ព្ទ, ងងឹតអ័ព្ទ... ។

២១២— អាប់ (គុ.) ដែលអន់ឬតិចពន្លឺ, អន់សម្បុរ, ថយលំអរ, មិនរុងរឿង, ថោក, ទន់ទាប, ទន់ខ្សោយ, ដែលឥតគេរាប់ : អាប់សម្បុរ, អាប់គំនិត, អួអាប់, អាប់ឱន, អាប់ឥត... ។

២១២— អាប់ (កិ.) ដាក់លុយឲ្យទៅអ្នកវិញ : ត្រូវអ្នកអាប់ ១៥ សេនឲ្យខ្ញុំវិញ; (ពាក្យទំនើបថ្មី) ។

ឧទាហរណ៍ ទី ២១២

ថ្ងៃនេះចុះអ័ព្ទពេញវាល រកទៅធ្វើការអ្វីពុំកើតសោះ នាំឲ្យអាប់គំនិតនិតទៅណាក៏ពេញរួច ។

www.budinst.gov.kh www.elibraryofcambodia.org

"អា. អារ"

២១៣— អា (ឧ.) ពាក្យទាបឥតគួរសម និយាយចំពោះមនុស្ស ប្រុសឬសត្វឈ្មោល, ប្រើជាពាក្យស្និទ្ធស្នាលនឹងគ្នាក៏មាន : អាក្មេង, អានាង, អានេះ, អានុះ អាឯង, អាច្រមក់, អាភី. . ។

២១៣— អា (គុ.) ដែលមានគូស្រករតែពុំមានកូន : ស្ត្រីអា, មេគោអា... ។

២១៣— អារ (កិ.) កាត់, បំបែក, ច្រៀក, កាត់ផ្ដាច់, តម្រឹម : អារឈើ, អារកាត់, អារពន្ធ... ។

ឧទាហរណ៍ ទី ២១៣

*អាក្មេងអារឈើឡើង ! ប្រពន្ធអាក្មេងនឹងពិតជាអាហើយមើលទៅ មានជាគ្មានកូន* ។

"ឥដ្ឋ, ឥត"

២១៤— ឥដ្ឋ (ន.) ដីស្អិតដែលធ្វើជារាងសណ្ឋានផ្សេងៗ ហើយកោលថ្ងៃឲ្យស្ងួតឬដុតឲ្យឆ្អិន : ផ្ទះឥដ្ឋ, ឡឥដ្ឋ, កំពែងឥដ្ឋ...; បន្ទះកម្រាលដែលធ្វើដោយស៊ីម៉ង់ត៍ ក៏ហៅថាឥដ្ឋដែរ : ឥដ្ឋពណ៌... ។

២១៤— ឥត (និ.) មិន, ពុំ, អត់ : ឥតដឹង, ឥតបានឮ... ។

២១៤— ឥត (គុ.) ដែលមិនមាន : មនុស្សឥតគួរឥតសម, បុគ្គលឥតភ័ព្វ, មនុស្សឥតកំណើត... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី ២១៤

ខ្ញុំឥតបានគិតថាផ្ទះនេះមានឥដ្ឋពណ៌ណាគេទេ! នោះបើគិតកុំវិញ ព្រោះម្ចាស់ផ្ទះជាមនុស្សឥតគួរឥតសម ។

## "ឱស = អុស, ឱះ = អុះ"

២១៥- ឱស (ន.) ឈើសម្រាប់ដុត: រកឧស, ទិញឧស, ពំនរឧស, ឧសគ្គ, ឧសសង្កែ... ។

២១៥- ឱះ (ឧ.) ពាក្យលាន់មាត់ដោយខ្លាចក្រែងដួល, ក្រែងធ្លាក់ ឬដោយនឹកស្ដាយជាដើម: ឱះឱ! ឱះ! មែនអីចាះ, ឱះ! ស្លាប់ហើយ... ។

ឧទាហរណ៍ ទី ២១៥

ឱះឱ! ចាស់ម្នាក់អើយ ឪពុកអ្នកស្លាប់ទៅហើយ បានគេរកដង ទឹករកឧសមិញ ។

## "អូ! អូរ"

២១៦- អូ! (ឧ.) ពាក្យលាន់មាត់ដោយការអស់ឆ្ងល់, ដោយការយល់សេចក្ដីជាក់ជាដើម: អូ! មែន, អូ! ឃើញហើយ, អូ! ដូច្នោះទេ ... ។

២១៦- អូរ (ន.) ផ្លូវលង់នូវទឹកតូចជាងស្ទឹងបន្តិច: ទឹកអូរ, មាត់អូរ, ព្រៃអូរ... ។

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ទី២១៦

អូ! ពីចាំមុខខ្ញុំបានមកងូតទឹកអូរនេះម្តងដែរ ។

" ឧដ្ឋ = អូដ្ឋ, អូត "

២១៧- អូដ្ឋ (ន.) សត្វចតុប្បាទ ពួកសត្វរើអៀង មានពីរប្រភេទគឺ អូដ្ឋបូកពីរ អូដ្ឋមានកំពូកខ្ពស់សណ្ឋានជាបូកមួយតួមុខក្រោយ នៅលើខ្នងមានរោមក្រាស់សកុល ; អូដ្ឋបូកមួយ អូដ្ឋមានកំពូកខ្ពស់តែមួយត្រង់កណ្តាលខ្នង មានរោមបន្តិចបន្តួច ស្ទើរតែស្បែកទទេ ; សត្វអូដ្ឋ ។

២១៧- អូត (កិ) យំ. យំសោក; សំដែងអាការធ្វើដូចជាយំសោក ; (ច្រើនប្រើក្នុងល្បែងល្ខោន) ។

២១៧- អូត (ន.) ឈ្មោះដំណើរភ្លេងពិណពាទ្យមួយបទ សម្រាប់លេងត្រង់ថ្នាក់ល្ខោនអូត : ភ្លេងអូត, បទអូត ។

ឧទាហរណ៍ ទី២១៧

កាលខ្ញុំជិះអូដ្ឋឆ្លងសមុទ្រខ្សាច់ - ព្រះសូរ្យសំដៅរៀងសត្វយំព្រួចអាកាស

ហាក់បីដូច ក្រែងអូត ។

" អ្នក, នាក់ "

២១៨- អ្នក (ស.) ពាក្យប្រើជំនួសឈ្មោះបុគ្គល ដែលត្រូវនិយាយទៅរកក្នុងទីចំពោះមុខ, សម្រាប់ប្រើជាធនហៅគ្នាដោយសេចក្តីគួរសម : អ្នកប្រុស, អ្នកស្រី, អ្នកអញ្ជើញទៅណា ?... ។

www.budinst.gov.kh www.elibraryofcambodia.org

២១៨— អ្នក (ឧ.) បុគ្គល, ជន, មនុស្ស: ពាក្យសម្រាប់នាំមុខសព្វនាម, ប្រើបានតាមគួរដល់ការប្រកប · អ្នកមុខអ្នកការ, អ្នកក្រុង, អ្នកស្រែ ..; (ចូរមើលក្នុងវចនានុក្រមភាគ ២ ទំព័រ ១៧១៦) ។

២១៨— នាក់ (សំខ្យា.ព.) ពាក្យសម្រាប់ផ្សំជាមួយនឹងសំខ្យាសព្ទដែលរាប់ចំនួនមនុស្ស: ពីរនាក់, បីនាក់, ... ។

ឧទាហរណ៍ ទី ២១៩

*ម្សិលមិញ អ្នកឯងឃើញអ្នកស្រែពីរនាក់យកស្រូវមកលក់ ឬទេ? ថ្ងៃក្រោយបើអ្នកឃើញ សូមប្រាប់ខ្ញុំផង ព្រោះអ្នកស្រែពីរនាក់នោះជំពាក់ស្រូវខ្ញុំ ។*

បប់ដោយសង្ខេប

*ទុកជាទីរឭក*

*ចំពោះជនអ្នកស្នេហាភាសាជាតិ*

www.budinst.gov.kh www.elibraryofcambodia.org

# ឈ្មោះនិងតម្លៃសៀវភៅរបស់បណ្ណាគារ សុមនសុវត្ថិ

| ឈ្មោះសៀវភៅ | ឈ្មោះអ្នកតែង | តម្លៃ |
|---|---|---|
| ១ វេយ្យាករណ៍បាលី | បណ្ឌិតមហា ឈឹម–ស៊ុម | ២៥ ៛ ០០ |
| ២ ប្រស្នាវិន័យ ភាគទី ១ | ព្រះវិន័យធរ ឯក–ញឹម | ២៥ ៛ ០០ |
| ៣ ភិក្ខុបាតិមោក្ខបាលី-ប្រែ | ព្រះគ្រូ ប៊ុណ្យ–សម្អាង | ២៥ ៛ ០០ |
| ៤ ពុទ្ធប្បវត្តិកថា | បណ្ឌិតមហា ឈឹម–ស៊ុម | ២២ ៛ ០០ |
| ៥ អធិប្បាយគាថាធម្មបទ ភាគទី ១ | " ឈឹម–ស៊ុម | ២២ ៛ ០០ |
| ៦ ឧភយពាក្យវិលាសិនី ភាគទី ១ | " ឈឹម–ស៊ុម | ២២ ៛ ០០ |
| ៧ សរណគមនកថា | លោកគ្រូអាចារ្យសេក | ១៥ ៛ ០០ |
| ៨ វិន័យវិនិច្ឆ័យ | សម្តេចព្រះធម្មលិខិតស្វី - ឯម | ១៣ ៛ ០០ |
| ៩ ភាណវារបាលី ភាគទី ៨ | របស់បុរាណ | ៤ ៛ ០០ |
| ១០ ទសជាតក | ព្រះគ្រូ អ៊ូ–ឧបរ | ២២ ៛ ០០ |
| ១១ អប្បមាទកថា | ព្រះគ្រូ គង់–ស៊ឹម | ៨ ៛ ០០ |
| ១២ រចនប្រទីប | ព្រះបាឡាត់ សុង–ស៊ីវ | ២០ ៛ ០០ |

## ( មានលក់ដុំនិងលក់រាយ )

### សៀវភៅដែលនឹងបោះពុម្ពតទៅ

| | | |
|---|---|---|
| ១៣ ជាតកក្នុងធម្មបទ | បណ្ឌិតមហា ឈឹម–ស៊ុម | – ៛ – |
| ១៤ អធិប្បាយគាថាធម្មបទ ភាគទី ២-៣-៤ | " ឈឹម–ស៊ុម | – ៛ – |
| ១៥ ប្រស្នាវិន័យ ភាគទី ២-៣-៤ | " ឈឹម–ស៊ុម | – ៛ – |
| ១៦ ឧភយពាក្យវិលាសិនី ភាគទី ២ | " ឈឹម–ស៊ុម | – ៛ – |
| ១៧ រឿងបល័ង្កទិព្វ | ក្រុមការរ៉ាយ–ប៊ុក | – ៛ – |
| ១៨ កម្មបថកថា នានានិទាន | បណ្ឌិតមហា ឈឹម–ស៊ុម | – ៛ – |
| ១៩ ពុទ្ធគុណកថា | " ឈឹម–ស៊ុម | – ៛ – |
| ២០ អនុស្សតិកម្មដ្ឋាន | " ឈឹម–ស៊ុម | – ៛ – |
| ២១ វិធុរភាទ | " ឈឹម–ស៊ុម | – ៛ – |

www.budinst.gov.kh www.elibraryofcambodia.org

| ឈ្មោះសៀវភៅ | ឈ្មោះអ្នកតែង | ថ្លៃ |
|---|---|---|
| ២២ វិជ្ជាគុណកថា | បណ្ឌិតមហា ឈឹម-ស៊ុម | –៛– |
| ២៣ វិធីសម្ពន្ធសង្ខេប | " " " | –៛– |
| ២៤ វចនសង្គហៈ (ភាសាបាលី-ខ្មែរ-បារាំង) | " " " | –៛– |
| ២៥ សង្គីតិប្រវត្តិ | " " " | –៛– |
| ២៦ ពុទ្ធឃោសប្រវត្តិ | " " " | –៛– |
| ២៧ ទំនុកជាតិនិយម (ភាគ១-ដើម) | " " " | –៛– |
| ២៨ វន្តកវិន័យសង្ខេប | " " " | –៛– |
| ២៩ អនុបុព្វីកថា | លោកគ្រូអាចារ្យ គឹម-ឡាយ | –៛– |
| ៣០ មធរភាព | ក្រមការ ភ៊យ-ប៊ុក | –៛– |


បណ្ណាគារ សុមនសុវត្ថិ លេខ ៩៥
វិថីឋាង់វី-វុស្សីយេរ ខាងអគ្នេយ៍វត្តកោះ
ក្រុងភ្នំពេញ

បានទិញសៀវភៅអក្សរខ្មែរ, អក្សរបារាំង ពីកន្លែងឯទៀត ១ មកលក់ជាច្រើនមុខ
សូមនិមន្ត-អញ្ជើញចូលទៅពិចារណាដោយសេចក្ដីស្មោះចំពោះជាតិ

ឈឹម-ស៊ុម


www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ស្រែរកិរ្តិ | ស្រែកិរ្តិ | ២៦ | ១៩ |
| គហ៍ | គេហ៍ | ២៧ | ៦ |
| នោះកំហោក្ទិង្គ | នោះកំហោក្ទិង្គ | ២៩ | ៧ |
| នៅស្រុកក្ទិង | នៅស្រុកកិង្គ | ៣០ | ២ |
| គថ្ន | គរថ្ម | ៣១ | ៩ |
| ពុំអាចគួ | ពំអាចគួរ | ៣៣ | ១២ |
| ស្មុះស្មើ ទប់ | ស្មុះស្មើរទប់ | ៣៥ | ៣ |
| គឺស្បៀសដែល | គឺស្បៀកដែល | ៣៥ | ៨ |
| អាវុធមួយ បប | អាវុធមួយបែប | ៣៦ | ៤ |
| បរិបូរ | បរិបូណ៌ | ៤២ | ៧ |
| ហៅ ក្មង | ហៅក្មេង | ៤៤ | ២ |
| ល្ងូត្រដារ | ស្លូត្រដារ | ៤៧ | ៣ |
| គឺសភាពរបស | គឺ.ភាពរបស់ | ៥៥ | ១១ |
| ដោយន័យដា | ដោយន័យដា | ៥៥ | ១៤ |
| ល្អបញ្ចូង | ល្អបញ្ចូង់ | ៥៨ | ៥ |
| ដាងណា | ដាំងណា. | ៥៩ | ១៣ |
| សាយសុះទូទៅ | សាយសុសទូទៅ | ៦២ | ១១ |
| កិរ្តិឈ្មោះសុះសាយ | កិរ្តិ៍ឈ្មោះសុសសាយ | ៦២ | ១២ |
| បិតផៅ | បិតផ្អៅ | ៦៣ | ៣ |
| ដំបោមង | ដំបោម្ដង | ៦៣ | ១៦ |
| គ្រឿងលំអរ | គ្រឿងលំអ | ៦៤ | ៣ |
| បឹងបួរ | បឹគបួ | ៦៤ | ១៧ |
| តើគភល | តើគភេល | ៧១ | ២ |
| ដិតសាប | ដិតសាប់ | ៧១ | ១៦ |

www.elibraryofcambodia.org

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ថ្ងៃធ្ន | ថ្ងៃថ្ងូរ | ៧៣ | ៦ |
| ផលឈើស្វាប់ | ផល់ឈើស្វាប់ | ៧៨ | ១៩ |
| ក្នុងម្ហូប | ក្នុងម្ហូប់ | ៨០ | ១២ |
| ផ្សំផាបទផាមាស់ | ផ្សំផាបទសមាស | ៨២ | ១៤ |
| ព្រឹកពំដេលខាន | ព្រឹកពុំដែលខាន | ៨២ | ១៨ |
| ប្រែត្រឡប | ប្រែត្រឡប់ | ៨៣ | ១៥ |
| ភកដែលកើត | ភក់ដែលកើត | ៨៧ | ៤ |
| មណាលជុំវិញ | មណ្ឌលជុំវិញ | ៨៩ | ១៦ |
| ស្រូវដែលផះ | ស្រូវដែលផុះ | ៩០ | ៩ |
| កលាំងយន្ត | កំលាំងបន្ត | ៩១ | ១៤ |
| បល្លង្ករ័តន៍ | បល្លង្ករ័តន៍ | ៩៤ | ៤ |
| រត់បាត | រត់បាត់ | ៩៤ | ១១ |
| ត្រងរង្វះទឹក | ត្រង់រង្វះទឹក | ៩៥ | ៧ |
| លើផ្ទៃដី | លើផ្ទៃដី | ៩៨ | ៦ |
| ដែករណ្ដាបាឌិប | ដែករ័ណ្ដាផាឌិប | ១០៩ | ៥ |
| ដើមឈើធំៗ | ដើមឈើធំៗ | ១០៩ | ១០ |
| សាសំពត | សាសំពត់ | ១១៥ | ១៣ |
| ទីយជាតិ | ទីយជាតិ | ១២២ | ៧ |
| ភាសីបេកមងអស់ | ភាស៊ីបេកម្ដងអស់ | ១២៣ | ៩ |
| ដូចផ្សិតស្រែះ | ដូចផ្សិតស្រែះ | ១២៥ | ១៥ |
| ចយលំអរ | ចយលំអ | ១៣០ | ១១ |
| ហោក | ហ៊ោក | ១៣០ | ១២ |
| អាប់ផ តិ | អាប់ជាតិ | ១៣០ | ១៣ |
| មាតអួរ | មាត់អួរ | ១៣២ | ១៥ |

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org